ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE


## សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ របស់អគ្គនាយកដ្ឋានពន្ធដារ

# PROCEDURES TO PREVENT TAXPAYER OFFENSES OF THE GENERAL DEPARTMENT OF TAXATION

## ជំនាញ គណនេយ្យ


រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

ក្រសួងអប់រំ យុវជន និងកីឡា

MINISTRY OF EDUCATION YOUTH AND SPORTS

វិទ្យាស្ថាន វ៉ាន់ដា

VANDA INSTITUTE

# សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ

# នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ របស់អគ្គនាយកដ្ឋានពន្ធដារ

# PROCEDURES TO PREVENT TAXPAYER OFFENSES OF THE GENERAL DEPARTMENT OF TAXATION

សាស្ត្រាចារ្យណែនាំ ៖ យាន ដារ៉ា

ជំនាញ គណនេយ្យ

រាជធានីភ្នំពេញ-ឆ្នាំ២០២៤

PHNOM PENH-2024

**គណៈកម្មការត្រួតពិនិត្យសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រជំនាន់ទី២១**
**ប្រធានបទ៖ នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ**

គណៈកម្មការវាយតម្លៃទី១

បេក្ខបណ្ឌិត ស្រេង ផល្លា

សាស្ត្រាចារ្យណែនាំ

យាន ដារ៉ា

គណៈកម្មការវាយតម្លៃទី៣

បេក្ខបណ្ឌិត យ៉ាក វុទ្ធី

គណៈកម្មការវាយតម្លៃទី២

បេក្ខបណ្ឌិត មាស សំណាង

ប្រធានគណៈកម្មការវាយតម្លៃ និងជាប្រធានមជ្ឈមណ្ឌលស្រាវជ្រាវ

បណ្ឌិត សេង សំអឿន

គណៈកម្មការវាយតម្លៃទី៤

បេក្ខបណ្ឌិត យ៉ែម សុខហៀក

**នាយកវិទ្យាស្ថាន**

**បណ្ឌិត ហេង វ៉ាន់ដា**

នាយិការងអចិន្ត្រៃយ៍

បណ្ឌិត ហ៊ូ គុជគន្ធលីនណា

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ គណនេយ្យនៅវិទ្យាស្ថាន វ៉ាន់ដា អស់រយៈពេល៤ឆ្នាំសិក្សារួចមក ក្រុមយើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ពាក់ព័ន្ធនឹងមុខវិជ្ជាគណនេយ្យ ជាពិសេសក្រុមយើងខ្ញុំយល់ច្បាស់ថា ជំនាញគណនេយ្យ គឺជាជំនាញមួយមានសារៈសំខាន់មួយដែរសម្រាប់ទីផ្សារបច្ចុប្បន្ន ក្នុងនោះស្ថាប័នរដ្ឋក្តី ឯកជនក្តី ឬអង្គការក្រៅរដ្ឋាភិបាលក្តី សុទ្ធតែត្រូវអនុវត្តកិច្ចការធនាគារដូចគ្នា។ ដោយឡែកដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែមានគុណភាពខ្ពស់ វិទ្យាស្ថាន វ៉ាន់ដា បានបញ្ចូលនូវមុខជំនាញសំខាន់ៗដែលពាក់ព័ន្ធនឹងការងារ គណនេយ្យនិងហិរញ្ញវត្ថុនិងធនាគារ តាមកម្មវិធីសិក្សាក្នុងឆ្នាំសិក្សាទីមួយ រហូតដល់ឆ្នាំសិក្សាទី៤។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែមានសារៈសំខាន់ក្នុងការត្រួសត្រាយផ្លូវនិស្សិតឱ្យយល់ច្បាស់ ពីការអនុវត្តការងារធនាគារពីការចាប់ផ្តើមរៀបចំផែនការ ការអនុវត្ត ការបញ្ចប់ និងត្រួតពិនិត្យ វាយតម្លៃព្រមទាំងផ្តល់ជាអនុសាសន៍នៅក្នុងការងារធនាគារ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រង នៅក្នុងស្ថាប័នខ្លួនក្នុងន័យឆ្លើយតបឱ្យបានល្អប្រសើរនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ។ ដោយក្រុមយើងខ្ញុំសង្កេតឃើញថា កិច្ចការងារមួយនេះមានសារៈសំខាន់ខ្លាំងស្របពេល នៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្របានមកដល់ ទើបក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសនូវប្រធានបទមួយស្តីពី "**នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ**" យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងក្នុងគោលបំណងឱ្យអ្នកស្រាវជ្រាវទាំងអស់ ឱ្យយល់កាន់តែស៊ីជម្រៅពីការរៀបចំសារណា និងប្រសិទ្ធភាពនៃការផ្តល់ឥណទានរបស់ធនាគារ។ ក្រុមយើងខ្ញុំសង្ឃឹមថា ការរៀបចំសារណានេះនឹងបានចូលរួមចំណែក ក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកស្រាវជ្រាវដ៏ទៃទៀត ដែលមានបំណងសិក្សាស្វែងយល់ពីកិច្ចការនេះ។

ជាទីបញ្ចប់ក្រុមយើងខ្ញុំ សូមមេត្តាខន្តី អភ័យទោស ពីសំណាក់លោកគ្រូ អ្នកគ្រូ រៀមច្បង និងអ្នកអានទាំងអស់នូវរាល់កំហុសឆ្គង ដែលកើតមានដោយអចេតនា នៅក្នុងសារណានេះ ហើយក្រុមយើងខ្ញុំរីករាយនឹងទទួលយករាល់ការរិះគន់ក្នុងន័យស្ថាបនា ដើម្បីឱ្យការរៀបចំលើកក្រោយទៀតមានភាពន់តែល្អប្រសើរ។

# រចនាសម្ព័ន្ធក្រុម



**អ៊ុន សុខលីន**
ID: SP21/049



**សុវណ្ណ វឌ្ឍនា**
ID: B21/596



**ពន មុនីពេជ្រ**
ID: B21/802



**ទាសនា ណារី**
ID: B21/393

# សេចក្តីថ្លែងអំណរគុណ

ក្រុមយើងខ្ញុំជានិស្សិតនៃវិទ្យាស្ថាន វ៉ាន់ដា ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២១ ជំនាញគណនេយ្យ

**សូមសំដែងនូវការគោរពដឹងគុណ និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ**

ក្រុមគ្រួសារដែលបានជួយឧបត្ថម្ភ គាំទ្រ ទាំងសម្ភារៈ ថវិកា និងស្មារតី ជំរុញលើកទឹកចិត្តដល់ក្រុមយើងខ្ញុំ ក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះដឹងរហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះក្រុមយើងខ្ញុំសូមសំដែងនូវការគោរព និងកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុត ដល់អ្នកមានគុណ ដែលបានផ្តល់កំណើតដល់នាងខ្ញុំគ្រប់រូប និងសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់បណ្ឌាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានបណ្តុះបណ្តាលក្រុមយើងខ្ញុំនាពេលកន្លងមក។

ក្រុមយើងខ្ញុំ សូមសំដែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅ ដល់ឯកឧត្តមបណ្ឌិត **ហេង វ៉ាន់ដា** នាយកនៃវិទ្យាស្ថាន វ៉ាន់ដា ដែលបានផ្តល់ទីកន្លែងបណ្តុះបណ្តាល ព្រមទាំងផ្តល់បទពិសោធន៍យ៉ាងច្រើនដល់យើងខ្ញុំ។

សូមគោរពថ្លែងអំណរគុណចំពោះសាស្ត្រាចារ្យ **ឃាន ដារ៉ា** ជាសាស្ត្រាចារ្យណែនាំ ដោយបានជួយជ្រោមជ្រែង បង្ហាត់បង្ហាញសព្វបែបយ៉ាង ដើម្បីជួយដល់ក្រុមយើងខ្ញុំបញ្ចប់កិច្ចការសារណានេះជាស្ថាពរ។

សូមគោរពថ្លែងអំណរគុណដល់សាស្ត្រាចារ្យ និងបុគ្គលិកនៃវិទ្យាស្ថានវ៉ាន់ដាទាំងអស់ ដែលបានខិតខំប្រឹងប្រែងក្នុងការបង្ហាត់បង្ហាញ លើកទឹកចិត្ត អនុគ្រោះដល់ក្រុមយើងខ្ញុំ រហូតធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ឆ្លៀតក្នុងឱកាសនេះដែរ ក្រុមយើងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់បុគ្គលទាំងអស់ខាងលើឱ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## **អំណះអំណាង**

ក្រុមយើងខ្ញុំ ជានិស្សិតបរិញ្ញាបត្រ ជំនាញគណនេយ្យ នៃវិទ្យាស្ថាន វ៉ាន់ដា ជំនាន់ទី២១៖

សូមធានាអះអាងថា ខ្លឹមសារសារណាក្រោមប្រធានបទ «នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ» នេះគឺជាស្នាដៃរបស់ក្រុមយើងខ្ញុំ ដោយគ្មានការពាក់ព័ន្ធនឹងរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ទិន្នន័យ និងលទ្ធផលនៃការស្រាវជ្រាវ ដែលលើកឡើងនេះ ជាអត្ថបទស្រាវជ្រាវថ្មីសុទ្ធសាធ ដែលពុំធ្លាប់មានជនណាម្នាក់យកទៅប្រើប្រាស់ក្នុងការស្រាវជ្រាវពីមុនឡើយ។

ថ្ងៃ. .............. ខែ.......... ឆ្នាំ............. ព.ស.២៥៦....

ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២....

**ហត្ថលេខាតំណាងក្រុម**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសមួយដែលប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស ជាក់ស្តែងកម្ពុជាបានខិតខំស្វះស្វែង និងពុះពារគ្រប់ឧបសគ្គជាច្រើនក្នុងគោលដៅប្រែក្លាយខ្លួន ទៅជាប្រទេសអភិវឌ្ឍមួយនាថ្ងៃអនាគត។ យ៉ាងណាមិញ រដ្ឋបាលសារពើពន្ធកម្ពុជាបានដើរតួយ៉ាងសំខាន់ ក្នុងការប្រមូលពន្ធជូនរដ្ឋពីមួយឆ្នាំទៅមួយឆ្នាំដោយរដ្ឋបាលសារពើពន្ធកម្ពុជា បានខិតខំរិះរកគ្រប់មធ្យោបាយ ដើម្បីអភិវឌ្ឍនូវសមត្ថភាពរបស់ខ្លួនឆ្លើយតបទៅនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ព្រមទាំងសម្រេចបាននូវសមិទ្ធផលជាវិជ្ជមាន និងដ៏ថ្លៃថ្លាជាប្រវត្តិសាស្រ្ត នៃកំណើនលទ្ធផលប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទជាមធ្យមប្រមាណ២០% ក្នុងមួយឆ្នាំៗជាប់ៗគ្នា។ ក្នុងនោះទៀតសោត ប្រទេសកម្ពុជាក៏បានបង្កើតឱ្យមាននូវប្រព័ន្ធពន្ធដារឡើង គឺក្នុងគោលបំណងប្រមូលពន្ធពីប្រជាពលរដ្ឋ ដើម្បីលើកស្ទួយដល់សេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើន។

ការបង់ពន្ធ គឺជាកាតព្វកិច្ចរបស់អ្នកជាប់ពន្ធក៏ពិតមែន ប៉ុន្តែ ក៏នៅមានបុគ្គលមួយចំនួនបានគេចវេះពន្ធដោយចេតនាទៅលើបទប្បញ្ញត្តិស្តីពីពន្ធដារ និងមានការធ្វេសប្រហែសក្នុងការមិនបង់ពន្ធ ទោះបីជាដឹងថា អំពើទាំងនោះអាចប្រឈមនឹងមុខច្បាប់ក៏ដោយ។ ក្រៅពីបទល្មើសទាំងពីរ យើងក៏ឃើញមានការប្រព្រឹត្តនូវអំពើមួយចំនួន ដែលបង្កឱ្យរាំងស្ទះដល់ការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលបង្កឱ្យមានការឃឹតយ៉ាវដល់មន្ត្រីពន្ធដារ។ ទន្ទឹមនឹងមានបុគ្គលមួយចំនួនធ្វើការគេចវេះពន្ធ អគ្គនាយកដ្ឋានពន្ធដារក៏មានវិធានការ ក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធផងដែរ គឺការស៊ើបអង្កេតលើបទល្មើសពន្ធដារ ដើម្បីបង្កើនជំនឿទុកចិត្តពីសាធារណៈចំពោះប្រព័ន្ធពន្ធដារកម្ពុជា។ ម្យ៉ាងវិញទៀតអគ្គនាយកដ្ឋានពន្ធដារបានចាត់វិធានការនានា តាមច្បាប់ជាធរមានដើម្បីស្វែងរកបុគ្គល ដែលបានប្រព្រឹត្តបទល្មើសមកផ្តន្ទាទោសតាមច្បាប់ ដើម្បីពង្រឹងនូវការអនុវត្តន៍ច្បាប់ និងធានាបាននូវតម្លាភាពនៃការប្រកួតប្រជែងក្នុងកិច្ចការធុរកិច្ច ហើយអគ្គនាយកដ្ឋានពន្ធដារ ក៏បានស្នើសុំសាធារណជន និងធុរជនទាំងអស់ រួមទាំងបុគ្គលដែលត្រូវបានគេជួលឱ្យឈរឈ្មោះជំនួសសហការផ្តល់ព័ត៌មាន អំពីសកម្មភាពប្រព្រឹត្តបទល្មើសគេចវេះ និងបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

ដូច្នេះ រដ្ឋបាលសារពើពន្ធមានមុខងារស៊ើបអង្កេតបទល្មើសពន្ធដារ ដែលមានតួនាទីស៊ើបអង្កេត និងស្រាវជ្រាវឱ្យឃើញ នូវរាល់បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ និងឈានទៅដល់ការចាត់វិធានការតាមផ្លូវតុលាការ ដើម្បីទប់ស្កាត់និងលុបបំបាត់ការគេចវេះពន្ធ និងអំពើរាំងស្ទះដល់ការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ ដែលធ្វើឱ្យបាត់បង់ធំធេងនូវចំណូលពន្ធដារដែលត្រូវប្រមូលចូលថវិកាជាតិ។ ដើម្បីជៀសវាងនូវទោសទណ្ឌដែល អាចកើតមានឡើងពីការប្រព្រឹត្តបទល្មើសទាំងនេះ អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថាសាធារណជន លោក-លោកស្រីជាប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ឬជាកម្មសិទ្ធិករនៃសហគ្រាសទាំងអស់ ជៀសវាងនូវការប្រព្រឹត្តបទល្មើសខាងលើ និងចូលរួមយកចិត្តទុកដាក់ក្នុងការអនុវត្តន៍ច្បាប់ស្តីពីសារពើពន្ធឱ្យមានប្រសិទ្ធភាពខ្ពស់។

# មាតិកា

ទំព័រ

អារម្ភកថា ........ i

រចនាសម្ព័ន្ធក្រុម ........ ii

សេចក្តីថ្លែងអំណរគុណ ........ iii

អំណះអំណាង ........ iv

សេចក្តីសង្ខេបនៃការស្រាវជ្រាវ ........ v

**ជំពូកទី១: សេចក្តីផ្តើម**

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២

១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ៣

១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ៣

១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ៣

១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

**ជំពូកទី២: នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ**

២.១ លក្ខណៈទូទៅនៃការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ ........ ៥

២.១.១ និយមន័យអ្នកជាប់ពន្ធ ........ ៥

២.១.២ ប្រវត្តិអគ្គនាយកដ្ឋានពន្ធដារ ........ ៦

២.២ កាតព្វកិច្ច និងសិទ្ធអ្នកជាប់ពន្ធ ........ ១០

២.២.១ និយមន័យកាតព្វកិច្ច ........ ១០

២.២.២ កាតព្វកិច្ចប្រជាពលរដ្ឋទូទៅ ........ ១១

២.២.៣ កាតព្វកិច្ច និងសិទ្ធរបស់អ្នកជាប់ពន្ធតូច ........ ១៤

២.២.៤ កាតព្វកិច្ច និងសិទ្ធរបស់អ្នកជាប់ពន្ធមធ្យម ........ ១៦

២.២.៥ កាតព្វកិច្ច និងសិទ្ធរបស់អ្នកជាប់ពន្ធធំ ........ ១៧

២.៣ នីតិវិធីក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ ........ ១៨

២.៣.១ និយមន័យនីតិ ........ ១៨

២.៣.២ ចំណាត់ថ្នាក់នៃនីតិ ........ ១៩

២.៣.៣ និយមន័យនៃបទល្មើស ........ ១៩

២.៣.៤ ចំណាត់ថ្នាក់នៃបទល្មើស ........ ២០

## ជំពូកទី៣: នីតិវិធីក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ របស់អគ្គនាយកដ្ឋានពន្ធដារ


៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ ............ ២២
៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ ............ ២២
៣.១.២ ទស្សនវិស័យ បេសកកម្ម គុណតម្លៃ និងតួនាទីនិងភារកិច្ច របស់អគ្គនាយកដ្ឋានពន្ធដារ ២៤
៣.១.៣ និមិត្តសញ្ញារបស់អគ្គនាយកដ្ឋានពន្ធដារ ............ ២៥
៣.១.៤ រចនាសម្ព័ន្ធគ្រប់គ្រង (តួនាទី និងភារកិច្ច)អគ្គនាយកដ្ឋានពន្ធដារ ............ ២៦
៣.២ កាតព្វកិច្ច និងសិទ្ធរបស់អ្នកជាប់ពន្ធ ............ ២៩
៣.២.១ កាតព្វកិច្ចអ្នកជាប់ពន្ធ ............ ២៩
៣.២.២ សិទ្ធរបស់អ្នកជាប់ពន្ធ ............ ៣១
៣.២.៣ បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ............ ៣២
៣.៣ នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ ............ ៣៣
៣.៣.១ មុនពេលបើកការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ............ ៣៤
៣.៣.២ អំឡុងពេលធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ............ ៣៤
៣.៣.៣ ក្រោយពេលស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ............ ៣៥
៣.៣.៤ ទណ្ឌកម្មព្រហ្មទណ្ឌតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ ............ ៣៦
៣.៣.៥ វិធានការនៃការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ ............ ៣៧


## ជំពូកទី៤: ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ


៤.១ ការវិភាគលើចំណុចខ្លាំង ............ ៤០
៤.២ ការវិភាគលើចំណុចខ្សោយ ............ ៤០


## ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍


៥.១ សេចក្តីសន្និដ្ឋាន ............ ៤២
៥.២ ការផ្តល់អនុសាសន៍ ............ ៤៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# ជំពូកទី១
# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

គ្រប់បណ្តាប្រទេសនៅលើពិភពលោកទាំងអស់ ត្រូវការចំណូលពីគ្រប់វិស័យ ដើម្បីចូលរួមក្នុងការបែងចែកចំណាយក្នុងប្រទេសគួរឱ្យកត់សម្គាល់ប្រទេសកម្ពុជា គឺជាប្រទេសវ័យចំណាស់ ដែលស្ថិតនៅឧបទ្វីបឥណ្ឌូចិន ដែលសម្បូរទៅដោយសម្បត្តិវប្បធម៌ដ៏ខ្ពង់ខ្ពស់ ប៉ុន្តែ ជាប្រទេសដែលបានទទួលរង នូវសង្គ្រាមអូសបន្លាយអស់រយៈពេលជាច្រើនទសវត្សកន្លងមក ដែលបានធ្វើឱ្យខឿនសេដ្ឋកិច្ចជាតិមានការធ្លាក់ចុះជាខ្លាំង។ ប្រទេសកម្ពុជា ជាប្រទេស ដែលមានប្រជាជនប្រមាណ១៥លាននាក់ គ្រប់គ្រងដោយរបបប្រជាធិបតេយ្យសេរីពហុបក្ស ជាក់ស្តែងព្រះរាជាណាចក្រកម្ពុជាបានខិតខំស្វះស្វែង និងពុះពារគ្រប់ឧបសគ្គជាច្រើនក្នុងគោលដៅប្រែក្លាយខ្លួនទៅជាប្រទេសអភិវឌ្ឍមួយនាថ្ងៃអនាគត។ យ៉ាងណាមិញ រដ្ឋបាលសារពើពន្ធកម្ពុជាបានដើរតួយ៉ាងសំខាន់ ក្នុងការប្រមូលពន្ធជូនរដ្ឋពីមួយឆ្នាំទៅមួយឆ្នាំ ដោយរដ្ឋបាលសារពើពន្ធកម្ពុជាបានខិតខំរិះរកគ្រប់មធ្យោបាយ ដើម្បីអភិវឌ្ឍនូវសមត្ថភាពរបស់ខ្លួនឆ្លើយតបទៅនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ព្រមទាំងសម្រេចបាននូវសមិទ្ធផលជាវិជ្ជមាន និងដ៏ថ្លៃថ្លាជាប្រវត្តិសាស្ត្រនៃកំណើនលទ្ធផលប្រមូលចំណូល ពន្ធ-អាករគ្រប់ប្រភេទជាមធ្យមប្រមាណ២០% ក្នុងមួយឆ្នាំៗជាប់ៗគ្នា។ ជាមួយគ្នានោះផងដែរ ប្រភពចំណូលក្រៅពីសារពើពន្ធ គឺបានមកពី វិស័យជាច្រើន មានដូចជាវិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យទេសចរណ៍ ដែលជាវិស័យចម្បងក្នុងការលើកកម្ពស់សេដ្ឋកិច្ចឱ្យមានការរីកចម្រើន។ ជាមួយគ្នានេះផងដែរ ប្រទេសកម្ពុជាមានការរីកចម្រើនដូចពេល បច្ចុប្បន្ន ដោយសារមានគោលនយោបាយពីរ ដែលធ្វើប្រតិបត្តិការទន្ទឹមគ្នាគឺ គោលនយោបាយសារពើពន្ធ និងគោលនយោបាយរូបិយវត្ថុ។ ក្នុងនោះទៀតសោតប្រទេសកម្ពុជាក៏បានបង្កើតឱ្យមាននូវប្រព័ន្ធពន្ធដារឡើង គឺក្នុងគោលបំណងប្រមូលពន្ធ ពីប្រជាពលរដ្ឋដើម្បីលើកស្ទួយដល់សេដ្ឋកិច្ចជាតិឱ្យមានការរីកចម្រើន។ ម្យ៉ាងវិញទៀតយើងសង្កេតឃើញថា ប្រព័ន្ធពន្ធដារនៅកម្ពុជា ក៏មានការប្រែប្រួលទៅតាមសម័យកាលដឹកនាំផ្សេងៗគ្នាដែរ តួយ៉ាងនៅក្នុងសម័យកាលអាណានិគមនិយមបារាំង ដែលបានយកពន្ធទៅលើមនុស្ស សត្វពាហនៈ ដីធ្លី ស្រែ ចម្ការ ផ្ទះសម្បែងជាដើម។

ជាក់ស្តែងគោលនយោបាយសារពើពន្ធ គឺជាគោលនយោបាយមួយប្រភេទដែលបង្កើតឡើង និងគ្រប់គ្រងដោយអគ្គនាយកដ្ឋានពន្ធដារ ក្នុងគោលបំណងតាមដានចំណូល ចំណាយរបស់រាជរដ្ឋាភិបាល តាមរយៈការប្រមូលពន្ធពីប្រជាពលរដ្ឋ សហគ្រាស ឬក្រុមហ៊ុនជាដើម។ ការប្រមូលពន្ធទាំងនេះ មានពន្ធលើប្រាក់ចំណូល ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ ពន្ធអប្បរមា ពន្ធកាត់ទុក ពន្ធលើប្រាក់បៀវត្ស អាករលើតម្លៃបន្ថែម អាករពិសេសលើទំនិញ និងសេវាមួយចំនួន ពន្ធលើផលរបរ ពន្ធលើឈ្នួលផ្ទះ ពន្ធតែម ពន្ធប៉ាតង់ ពន្ធប្រថាប់ត្រា ពន្ធដីធ្លីមិនបានប្រើប្រាស់ ពន្ធសត្តឃាត ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយាន្តជំនិះគ្រប់ប្រភេទ អាករស្នាក់នៅ អាករបំភ្លឺសាធារណៈ និងពន្ធលើអចលនទ្រព្យ។ ម្យ៉ាងវិញទៀតពន្ធដារ ក៏មានតួនាទីយ៉ាងសំខាន់ផងដែរ ក្នុងការរួមចំណែកបង្កើនថវិកាជាតិ សម្រាប់ធានាឱ្យបាននូវសេចក្តីត្រូវការ និងចំណាយសាធារណៈដែលកាន់តែកើនឡើង ពីមួយឆ្នាំទៅមួយឆ្នាំទៀត។ ថ្វីត្បិតតែការគណនា និងការប្រមូលពន្ធ គឺជាការងារស្នូល តែការប្រមូលចំណូលពន្ធមិនអាចប្រមូលបាន ដោយគ្រាន់តែមានច្បាប់ពន្ធដារតែ

ប៉ុណ្ណោះទេ គឺអ្នកជាប់ពន្ធក៏ត្រូវចូលរួមចំណែកយល់ដឹងពីសារៈសំខាន់នៃពន្ធដារ ព្រមទាំងយល់ពីច្បាប់ពន្ធដារ ហើយរាយការណ៍ និងបង់ពន្ធជូនរដ្ឋដោយស្មោះត្រង់នោះទើបរដ្ឋអាចទទួលយកប្រាក់ចំណូលបានយ៉ាងពេញលេញ។

ការបង់ពន្ធជូនរដ្ឋ គឺជាកាតព្វកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូប ដើម្បីចូលរួមចំណែកក្នុងការកសាងសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានានៃប្រទេសកម្ពុជា។ បើនិយាយពីការរស់នៅប្រចាំថ្ងៃវិញ ពលរដ្ឋម្នាក់ៗ អាចទទួលបាននូវផលប្រយោជន៍ពីការបង់ពន្ធហើយពេលខ្លះទាំងមិនដឹងខ្លួន គឺតាមរយៈសេវាសាធាណៈ ឬហេដ្ឋារចនាសម្ព័ន្ធ ដែលគេប្រើប្រាស់ជារៀងរាល់ថ្ងៃដូចជា ស្ពាន ថ្នល់ សាលារៀន និងមន្ទីរពេទ្យ។ ដើម្បីធានានូវសេវាសាធារណៈអស់ទាំងនេះដូចជាការសាងសង់ ជួសជុលថែទាំ ស្ពាន ថ្នល់ អគារ សាលារៀន និងមន្ទីរពេទ្យ ការបើកប្រាក់បៀវត្សដល់គ្រូបង្រៀន និងគ្រូពេទ្យរដ្ឋត្រូវការចំណាយថវិកា ហើយប្រភពចំណូលដ៏ធំបំផុតនៃថវិការបស់រដ្ឋ គឺបានមកពីការបង់ពន្ធ។ អ្នកបង់ពន្ធខ្លះ អាចនឹងរអ៊ូថាផលប្រយោជន៍ដែលខ្លួនទទួលបានមានចំនួនតិចបើធៀបនឹងទំហំពន្ធដែលខ្លួនបានបង់។ ប៉ុន្តែគេក៏មិនត្រូវភ្លេចដែរថា ការបង់ពន្ធមិនមែនធ្វើឡើង ដោយសម្លឹងមើលតែផលប្រយោជន៍ដែលត្រូវទទួលបានមកវិញនោះទេ។ គោលការណ៍ដ៏សំខាន់មួយ នៃការបង់ពន្ធគឺ«សាមគ្គីភាព»និង«សមធម៌»។ បន្ទុកបង់ពន្ធត្រូវតែសមាមាត្រទៅតាមលទ្ធភាពរបស់ពលរដ្ឋម្នាក់ៗ ក៏ប៉ុន្តែសេវាសាធារណៈ ដែលកើតចេញពីការបង់ពន្ធនេះ ត្រូវបានជាប្រយោជន៍ដល់សមូហភាពទាំងមូល។ អ្នកដែលរកចំណូលបានច្រើន ត្រូវបង់ច្រើនហើយបើទោះបីជា ផលប្រយោជន៍ដែលគេទទួលបានមកវិញ មានតិចជាងទំហំពន្ធដែលគេបានបង់ ក៏ប៉ុន្តែគេបានចូលរួមចំណែកជួយដល់ប្រជាពលរដ្ឋដែលខ្វះខាត។ អាស្រ័យហេតុនេះ ទើបក្រុមយើងខ្ញុំបានលើកយកប្រធានបទ **«នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ»** យកមកស្រាវជ្រាវ និងរៀបចំជារបាយការណ៍បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

អគ្គនាយកដ្ឋានពន្ធដារ មិនត្រឹមតែជាប្រភពចំណូលដ៏សំខាន់របស់ថវិការដ្ឋតែមួយមុខប៉ុណ្ណោះនោះទេ ប៉ុន្តែពន្ធដារបានផ្សារភ្ជាប់ជាមួយបញ្ហាទាំងឡាយ អំពីការបង្កើនល្បឿនអភិវឌ្ឍសេដ្ឋកិច្ចអំពីសមាសភាពក្នុងការបែងចែកនិងស្ថេរភាពសង្គម។ ប្រសិនបើ គោលនយោបាយពន្ធខុសឆ្គងអាចនាំឱ្យមានភាពអន់ថយដល់ខឿនសេដ្ឋកិច្ចសង្គមផ្ទុយទៅវិញ បើគោលនយោបាយពន្ធត្រឹមត្រូវនាំឱ្យមានភាពរុងរឿងសម្បូរ និងមានស្ថេរភាពយូរអង្វែងឱ្យប្រទេសជាតិយើង។ យើងដឹងហើយថាការបង់ពន្ធ គឺជាកាតព្វកិច្ចមួយដ៏ចាំបាច់របស់អ្នកជាប់ពន្ធ។ ឯពន្ធក៏មានច្រើនប្រភេទខុសៗគ្នា អត្រាក៏ខុសគ្នាហើយវាអាចនឹងមានការពិបាកនិងភាពស្មុគស្មាញដល់អ្នកជាប់ពន្ធក្នុងការអនុវត្តបង់ពន្ធ។ តែបើមានការប្រព្រឹត្តិនូវមធ្យោបាយខុសឆ្គង ដើម្បីកាត់បន្ថយប្រាក់ពន្ធនោះ វានឹងក្លាយទៅជាការគេចពន្ធ ហើយវាជាអំពើខុសច្បាប់បើយោងទៅតាមច្បាប់ស្តីពីសារពើពន្ធ។ ដើម្បីឱ្យកាន់តែយល់ច្បាស់អំពីនីតិវិធី បទប្បញ្ញត្តិ និងវិធីសាស្ត្រ ក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធយើងបានចោទជា សំណួរដូចខាងក្រោម៖

១. អ្នកជាប់ពន្ធមានកាតព្វកិច្ច និងសិទ្ធិអ្វីខ្លះ?

២.តើអគ្គនាយកដ្ឋានពន្ធដារមាននីតិវិធីដូចម្តេចខ្លះ ក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ដើម្បីបង្កើនភាពងាយស្រួល និងជាគន្លឹះសម្រាប់ការសិក្សាស្រាវជ្រាវឱ្យកាន់តែមានប្រសិទ្ធភាពក្នុងការកំណត់យកនូវគោលបំណងសំខាន់ៗដូចតទៅ៖

- យល់ដឹងពីស្ថានភាពទូទៅនៃអគ្គនាយកដ្ឋានពន្ធដារ
- យល់ដឹងអំពីការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ
- យល់ដឹងអំពីកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ
- យល់ដឹងអំពីមូលហេតុដែលនាំឱ្យមានការបង្កើតបទល្មើសរបស់អ្នកជាប់ពន្ធក្នុងការបង់ពន្ធជូនរដ្ឋ
- ផលប៉ះពាល់ពីការគេចវេះ ការធ្វេសប្រហែស និងធ្វើឱ្យមានការរាំងស្ទះ ក្នុងការប្រមូលពន្ធ
- យល់ដឹងអំពីនីតិវិធី ក្នុងការទប់ស្កាត់ និងវិធានការ ចំពោះបទល្មើសអ្នកជាប់ពន្ធ
- សិក្សាទៅលើការណែនាំ និងលើកកម្ពស់វប្បធម៌បង់ពន្ធ ដល់ប្រជាពលរដ្ឋ ដែលរួមចំណែកយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍន៍ជាតិ។

## ១.៤ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវលើប្រធានបទ «**នីតិវិធីក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ**» នៅអគ្គនាយកដ្ឋានពន្ធដារដែលមានទីតាំងនៅ អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី(១១០) និងម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

### ១.៤.២ វិសាលភាពនៃការសិក្សាស្រាវជ្រាវ

ចំណែកដែនកំណត់ នៃការស្រាវជ្រាវផ្តោតទៅលើនីតិវិធីក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ ១ ឆ្នាំចុងក្រោយនេះគឺចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២១។

## ១.៥ វិធីសាស្រ្តនៃការស្រាវជ្រាវ

ការប្រមូលទិន្នន័យនៃការស្រាវជ្រាវគឺ ក្រុមនាងខ្ញុំបានស្រាវជ្រាវនៅក្នុងបណ្ណាល័យនៃវិទ្យាស្ថាន វ៉ាន់ដា និងតាមរយៈប្រព័ន្ធអ៊ីនធើណេត។

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះនឹងផ្តល់នូវអត្ថប្រយោជន៍ជាច្រើនដល់ខ្លួនឯង និស្សិតដទៃទៀត និងសង្គម ដែលរួមមានដូចជា៖

**ចំពោះខ្លួនឯង**

- ផ្តល់ចំណេះដឹង និងបទពិសោធន៍ការងារល្អៗ
- ផ្សាភ្ជាប់រវាងទ្រឹស្តី និងការអនុវត្តន៍ជាក់ស្តែងដែលពាក់ព័ន្ធនិងការធ្វើកម្មវិធីសិក្សាចំណេះដឹងផ្សេងៗ
- ធ្វើឱ្យយើងខ្ញុំចេះប្រមូលផ្តុំព័ត៌មាននិងការរៀបចំឱ្យមានសណ្តាប់ធ្នាប់និងធ្វើជាភ័ស្តុតាងប្រកបដោយភាពឈ្លាសវៃ។
- ចែករំលែកចំណេះដឹងផ្នែកបច្ចេកវិទ្យាដែលជាវិជ្ជាយ៉ាងសំខាន់សម្រាប់បំពេញនូវកិច្ចការផ្សេងទៀត។
- យល់ដឹងពីព័ត៌មានថ្មីៗជាច្រើន

- មានការយល់ដឹងបន្ថែមទាក់ទងនឹងច្បាប់សារពើពន្ធ

**និស្សិតជំនាន់ក្រោយ**

- ជាឯកសារតម្កល់ក្នុងបណ្ណាល័យសម្រាប់និស្សិតជំនាន់ក្រោយស្វែងយល់ បង្កឱ្យមានភាពសម្បូរបែបឯកសារជាភាសាខ្មែរ
- ជាឧបករណ៍សម្រាប់យកមកធ្វើជាឯកសារយោង ឬដើម្បីស្រាវជ្រាវបន្ថែម លើកស្ទួយការបង្កើតថ្មីនិងការសិក្សាស្រាវជ្រាវបន្ថែមដើម្បីការអភិវឌ្ឍន៍សង្គមជាតិ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវត្រូវចែកចេញជា ៥ ជំពូកដូចខាងក្រោមៈ

ជំពូកទី១ ៖ សេចក្តីផ្តើមៈ លំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហា គោលបំណង ដែនកំណត់វិសាលភាព វិធីសាស្ត្រនៃការស្រាវជ្រាវ និងសារៈសំខាន់នៃការស្រាវជ្រាវ។

ជំពូកទី២ ៖ រំលឹកទ្រឹស្តីៈ លក្ខណៈទូទៅនៃការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ កាតព្វកិច្ចអ្នកជាប់ពន្ធ បទល្មើសអ្នកជាប់ពន្ធបានប្រព្រឹត្ត។

ជំពូកទី៣ ៖ លទ្ធផលនៃការស្រាវជ្រាវៈ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ កាតព្វកិច្ចអ្នកជាប់ពន្ធ នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ។

ជំពូកទី៤ ៖ ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយៈ ការវាយតម្លៃលើចំណុចខ្លាំងនិងចំណុចខ្សោយរបស់នីតិវិធីក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ ។

ជំពូកទី៥ ៖ សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ៈ ធ្វើការសន្និដ្ឋានទៅលើគ្រប់ចំណុចទាំងអស់ និងផ្តល់ជាយោបល់អនុសាសន៍ទៅលើចំណុចដែលត្រូវកែលម្អ ឯកសារយោង និងឧបសម្ព័ន្ធនៃការស្រាវជ្រាវ។

# ជំពូកទី២
# រំលឹកទ្រឹស្តី

# ជំពូកទី២
# នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ

## ២.១ លក្ខណៈទូទៅនៃការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ

### ២.១.១ និយមន័យអ្នកជាប់ពន្ធ

- **អ្នកជាប់ពន្ធ** គឺជាបុគ្គល ឬសហគ្រាស ឬក្រុមហ៊ុនទាំងឡាយណាដែលមានកាតព្វកិច្ចចុះបញ្ជីពន្ធដារ ដាក់លិខិតប្រកាសពន្ធបង់ពន្ធតាមការកំណត់ និងគោរពតាមបទប្បញ្ញត្តិស្តីពីពន្ធដារផ្សេងៗទៀត ព្រមទាំងមានសិទ្ធិផ្តល់សេវាប្រកបដោយវិជ្ជាជីវៈ និងយល់ពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារ នីតិវិធីសារពើពន្ធ និងការអនុវត្តន៍កាតព្វកិច្ចសារពើពន្ធ[1]។
- **អ្នកជាប់ពន្ធឬអ្នកបង់ពន្ធ** សំដៅលើរូបវន្តបុគ្គល ឬអង្គភាពអាជីវកម្ម នីតិបុគ្គលដែលមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ។ នៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារនៃព្រះរាជាណាចក្រកម្ពុជាមានចែងថា អ្នកជាប់ពន្ធ គឺជាបុគ្គលទាំងឡាយ ដែលមានកាតព្វកិច្ចត្រូវបង់ពន្ធ[2]។
- **អ្នកជាប់ពន្ធ** គឺជាបុគ្គល ឬអង្គការ (ដូចជាក្រុមហ៊ុន) ដែលត្រូវបង់ពន្ធ។ អ្នកបង់ពន្ធទំនើបអាចមានលេខអត្តសញ្ញាណ ដែលជាលេខយោងដែលចេញដោយរដ្ឋាភិបាលដល់ប្រជាពលរដ្ឋ ឬក្រុមហ៊ុន។ ពាក្យ "អ្នកជាប់ពន្ធ" ជាទូទៅកំណត់លក្ខណៈអ្នកដែលបង់ពន្ធ។ អ្នកជាប់ពន្ធគឺជាបុគ្គល ឬអង្គភាពដែលមានកាតព្វកិច្ចធ្វើការទូទាត់ទៅឱ្យភ្នាក់ងារពន្ធក្រុង ឬរដ្ឋាភិបាល។ ពន្ធអាចមានក្នុងទម្រង់ជាពន្ធលើប្រាក់ចំណូល និងពន្ធលើអចលនទ្រព្យដែលដាក់លើម្ចាស់អចលនទ្រព្យ (ដូចជាផ្ទះ និងយានជំនិះ) រួមជាមួយនឹងទម្រង់ផ្សេងៗទៀតជាច្រើន។ មនុស្សអាចបង់ពន្ធនៅពេល ដែលពួកគេបង់ថ្លៃទំនិញ និងសេវាកម្មដែលត្រូវបង់ពន្ធ។ ពាក្យថា «អ្នកជាប់ពន្ធ» ច្រើនតែសំដៅលើកម្លាំងពលកម្មនៃប្រទេសដែលចំណាយសម្រាប់ប្រព័ន្ធ និងគម្រោងរបស់រដ្ឋាភិបាល តាមរយៈការបង់ពន្ធ។ លុយរបស់អ្នកជាប់ពន្ធក្លាយជាផ្នែក នៃមូលនិធិសាធារណៈដែលរួមមានប្រាក់ទាំងអស់ដែលបានចំណាយ ឬវិនិយោគដោយ រដ្ឋាភិបាលដើម្បីបំពេញតម្រូវការបុគ្គល ឬសមូហភាពឬដើម្បីបង្កើតអត្ថប្រយោជន៍ នាពេលអនាគត។ សម្រាប់គោលបំណងពន្ធ អង្គភាពអាជីវកម្មក៏ជាអ្នកជាប់ពន្ធផងដែរ ដោយធ្វើឱ្យចំណូល និងចំណាយរបស់ពួកគេត្រូវបង់ពន្ធ[3]។
- **អ្នកជាប់ពន្ធ** ជាបុគ្គល ឬអង្គភាពអាជីវកម្ម ដែលមានកាតព្វកិច្ចបង់ពន្ធទៅឱ្យសហព័ន្ធរដ្ឋ ឬរដ្ឋាភិបាលក្នុងតំបន់។ ពន្ធពីបុគ្គលនិងអាជីវកម្ម គឺជាប្រភពចំណូលចម្បងសម្រាប់រដ្ឋាភិបាល។ នៅសហរដ្ឋអាមេរិក អ្នកជាប់ពន្ធបុគ្គលជាធម្មតាតម្រូវឱ្យដាក់ឯកសារ និងបង់ពន្ធសហព័ន្ធ និងរដ្ឋជារៀងរាល់ឆ្នាំ។

---

1 https://www.kakcent.com/classification%E2%80%8B-o%E2%80%8Bf%E2%80%8B-%E2%80%8Btaxpayer%E2%80%8Bs/

2 https://www.tax.gov.kh/en/glossary

3 https://en.wikipedia.org/wiki/Taxpayer

អាជីវកម្មក៏ត្រូវតែដាក់របាយការណ៍ប្រចាំឆ្នាំផងដែរ ប៉ុន្តែជាធម្មតារៀបចំផែនការ និងការបង់ពន្ធប៉ាន់ស្មានជាប្រចាំពេញមួយឆ្នាំ[4]។

### ២.១.២ ប្រវត្តិអគ្គនាយកដ្ឋានពន្ធដារ

លោក Günter Dreyer អ្នកបុរាណវិទូសញ្ជាតិអាឡឺម៉ង់ ដែលជាអ្នកសិក្សាស្រាវជ្រាវប្រចាំតំបន់អេស៊ីប បុរាណ បានធ្វើការសន្និដ្ឋានថា ឯកសារពន្ធដំបូង បានធ្វើឡើងតាំងពីរជ្ជកាលស្តេច Scorpion ទីមួយ (King Scorpion I) នៃអេស៊ីបលើ (Upper Egypt) ចន្លោះពីឆ្នាំ៣២០០ ដល់ ៣៣០០ មុនគ្រិស្តសករាជ តាមរយៈការរកឃើញការចារឹកនៅលើបន្ទះដីឥដ្ឋ ពាង និងថូ ដែលយកចេញពីផ្នូររបស់ស្តេច Scorpion ទីមួយ។ បន្តមក ដល់យុគកណ្តាល ការប្រមូលពន្ធបានក្លាយជារឿងពេញដ៏និយមមួយ ដោយសារតែការចាប់ផ្តើមយកពន្ធរបស់បណ្តាប្រទេសមានឧស្សាហកម្មរីកចម្រើនជឿនលឿនមួយចំនួន តាមរយៈការដាក់ចេញនូវគោលការណ៍នៃការព្រមព្រៀងគ្នាក្នុងការបង់ពន្ធ នៅក្នុងឆ្នាំ ១២១៤ ក្នុងរជ្ជកាលរបស់ព្រះមហាក្សត្រ Jean Sans Terre ឬ Jonh នៃប្រទេសអង់គ្លេស។ បន្ទាប់មកបានបន្តរីកដុះដាលយ៉ាងខ្លាំងរហូតដល់ឆ្នាំ ១៧៨៩ ប្រទេសបារាំងបានលើកយកគោលការណ៍នៃការយកពន្ធទៅចែងក្នុងមាត្រា១៤ នៃសេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្ស និងពលរដ្ឋ។

ចំណែក ពន្ធដារប្រទេសកម្ពុជា ត្រូវបានបង្កើតឡើងក្រោមរបបអាណានិគមនិយមបារាំង តាមព្រះរាជប្រកាសចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៨៩៧ ស្របគ្នានឹងការបង្កើតច្បាប់ស្តីពីការរៀបចំរាជការទូទាំងព្រះនគរ ហើយត្រូវបានធ្វើការកែប្រែជាបន្តបន្ទាប់។ ដើម្បីនឹងទារប្រមូលពន្ធពីប្រជារាស្ត្របាន លុះត្រាតែមានបញ្ញត្តិអំពីពន្ធ ពោលគឺ ពន្ធមួយមុខឬថ្លៃអ្វីមួយមុខ ដែលនឹងទារបាននោះ លុះត្រាតែ ក្រសួងរាជការដែលមានអំណាចក្នុងការតាំងបង្កើតពន្ធ ឬថ្លៃ បានតាំងបង្កើតឡើងឱ្យបានត្រឹមត្រូវតាមគន្លងច្បាប់ជាមុនសិនទើបអាចទារបាន។ ន័យម្យ៉ាងទៀត គឺពន្ធមួយមុខ ឬថ្លៃអ្វីមួយមុខនឹងទារ ឬនឹងដកហូតបាន លុះត្រាតែក្រសួងរាជការរដ្ឋបាលបានតាំងបង្កើតឱ្យមានឡើងដោយត្រឹមត្រូវតាមគំនាបច្បាប់ នោះទើបនឹងទារ ឬដកហូតបាន។ រីឯពន្ធ ដែលរាជការក្រសួងពុំបានសម្រេចសេចក្តីទេនោះ អ្នកជាប់ពន្ធមានអំណាចនឹងប្រកែកពុំព្រមបង់ពន្ធបាន ព្រោះទុកជាបទរំលោភ និងអំណាចដោយហួសនឹងមុខងារ។ លើសពីនេះទៀតក្នុងសម័យអាណានិគមនិយមបារាំងបានកំណត់ពន្ធជាពីរប្រភេទរួមមានពន្ធផ្ទាល់ខ្លួន និងពន្ធប្រយោលដែលប្រមូលពីប្រជារាស្ត្រទូទាំងប្រទេសសម្រាប់បង់ចូលឃ្លាំងប្រាក់រាជការសម័យនោះ ហើយក៏គ្មានប្រជារាស្ត្រណាម្នាក់មិនបង់ពន្ធឡើយ។ ពន្ធសម័យនោះមានជាអាទិ៍ ពន្ធថ្លៃរាជការខ្លួន ពន្ធកំណែន ពន្ធចំការ ពន្ធទាសករ ពន្ធម្រេច ពន្ធស្រូវ ពន្ធទូក ពន្ធឈើគូស ពន្ធស្រា ពន្ធដីស្រែ ពន្ធប៉ាតង់ ពន្ធតែ ពន្ធប្រថាប់ត្រា។

ការប្រមូលពន្ធបានបន្តអនុវត្តដដែល នៅក្នុងសម័យក្រោយឯករាជ្យថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ គឺសម័យសង្គមរាស្ត្រនិយម(១៩៥៣ ដល់ ១៩៧០) និងសម័យសាធារណរដ្ឋខ្មែរ(១៩៧០ ដល់ ១៩៧៥) ប៉ុន្តែ ពន្ធត្រូវបានរំលាយបាត់រូបរាងពីសង្គមខ្មែរក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ (សម័យប៉ុលពត ឬខ្មែរក្រហម)។ ក្រោយពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម បានដួលរលំរដ្ឋាភិបាលថ្មីពេលនោះបានខិតខំបង្កើតឱ្យមានឡើងវិញ នូវច្បាប់ស្តីពីពន្ធដារនៅឆ្នាំ១៩៨១ សម្រេចឱ្យក្រសួងហិរញ្ញវត្ថុ អនុវត្តកិច្ចប្រតិបត្តិការចុះ

4https://www.investopedia.com/terms/t/taxpayer.asp

ឈ្មោះអាជីវកម្ម និងធ្វើការប្រមូលពន្ធអាជីវកម្ម។ ជាមួយគ្នានោះក្រសួងហិរញ្ញវត្ថុ បានចូលរួមកែប្រែនូវក្រឹត្យច្បាប់នៃពន្ធ ដើម្បីដាក់ឱ្យអនុវត្តក្រឹត្យច្បាប់ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៨២ ស្តីពីពន្ធអាជីវកម្ម ដែលបានប្រកាសដោយក្រុមប្រឹក្សារដ្ឋ ដើម្បីរួមចំណែកត្រួតពិនិត្យសកម្មភាពធ្វើអាជីវកម្មរបស់ប្រជាជន លើកកម្ពស់ផលិតកម្ម និងរួមចំណែកក្នុងថវិការដ្ឋ ។

ចាប់តាំងពីដើមឆ្នាំ២០១៦ មកគេឃើញមានកំណែទម្រង់ការដាក់ចេញបទប្បញ្ញត្តិមួយចំនួន ដែលមានបំណងធ្វើ ដូចជាការលុបចោលនូវពន្ធតាមរបបម៉ៅការ មកជាការបែងចែកប្រភេទអ្នកជាប់ពន្ធ តាមរបបស្វ័យប្រកាស មានកំណែទម្រង់នីតិវិធីនៃការចុះបញ្ជីពន្ធដារ ការកំណត់វិធានគណនេយ្យដែលមានលក្ខណៈសាមញ្ញសម្រាប់អ្នកជាប់ពន្ធតូច ការដំឡើងកម្រិតពន្ធលើប្រាក់បៀវត្សអប្បបរមា និងការអនុគ្រោះមិនយកអាករលើតម្លៃបន្ថែមលើសម្ភារៈឧស្សាហកម្ម ដែលបម្រើឱ្យវិស័យស្រូវអង្ករ និងសេវាសាធារណៈ។

បច្ចុប្បន្ន ប្រព័ន្ធពន្ធដារនៃព្រះរាជាណាចក្រកម្ពុជាមានរបបពន្ធតែមួយ គឺរបបស្វ័យប្រកាស។ អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស ត្រូវបានបែងចែកជាបីប្រភេទ គឺអ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម និងអ្នកជាប់ពន្ធធំ។ របបស្វ័យប្រកាសតម្រូវឱ្យអ្នកជាប់ពន្ធ ដែលបានចុះបញ្ជីពន្ធដារធ្វើការគណនាប្រាក់ពន្ធ ដាក់លិខិតប្រកាសសារពើពន្ធ និងបង់ប្រាក់ពន្ធដោយខ្លួនឯងឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធ។ ដើម្បីបញ្ជាក់ថាការប្រកាសពន្ធរបស់អ្នកជាប់ពន្ធមានភាពត្រឹមត្រូវ និងដើម្បីពង្រឹងអនុលោមភាពសារពើពន្ធ រដ្ឋបាលសារពើពន្ធមានអំណាចនិងកាតព្វកិច្ច ក្នុងការពិនិត្យវិភាគ ផ្ទៀងផ្ទាត់ និងកំណត់ពន្ធឡើងវិញ អនុលោមតាមមាត្រា១៩៤ មាត្រា២០៩ និងមាត្រា២១០ នៃច្បាប់ស្តីពីសារពើពន្ធ។

យោងតាមបទប្បញ្ញត្តិដែលចែងក្នុងផ្នែកទី១ នៃជំពូកទី១៨ នៃច្បាប់ស្តីពីសារពើពន្ធ ការគេចវេះពន្ធ គឺជាអំពើណាមួយដែលបានប្រព្រឹត្តឡើងដោយចេតនា និងរៀបចំទុកជាមុនដែលនាំឱ្យបាត់ប្រាក់ពន្ធ ដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យបង់។ ការគេចវេះពន្ធ គឺជាប្រភេទនៃបទល្មើសមួយ នៃបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។ ម្យ៉ាងវិញទៀត សកម្មភាពមួយចំនួននៃអំពើរាំងស្ទះដល់ការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ ក៏ត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារដែរ ហើយសកម្មភាពទាំងពីរខាងលើនេះជាកម្មវត្ថុនៃទណ្ឌកម្មព្រហ្មទណ្ឌតាមច្បាប់ជាធរមាន។ ដើម្បីឱ្យមានតម្លាភាព និងធានាបាននូវការប្រកួតប្រជែងស្មើភាពគ្នា និងដើម្បីបង្កឱ្យមានការជឿទុកចិត្តពីសាធារណជន ចំពោះប្រព័ន្ធពន្ធដារ អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ច ស៊ើបអង្កេត ស្រាវជ្រាវ បទល្មើស និងប្តឹងចោទប្រកាន់អ្នកប្រព្រឹត្តបទល្មើសទៅតុលាការស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃ ព្រះរាជាណាចក្រកម្ពុជា។

អគ្គនាយកដ្ឋានពន្ធដារ ត្រូវបានផ្តល់អំណាចគ្រប់គ្រាន់ក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ ក្នុងករណីដែលរកឃើញនូវភ័ស្តុតាង ឬបទល្មើសជាក់ស្តែងដែលបញ្ជាក់ថា ពិតជាមានអំពើគេចវេះពន្ធដោយចេតនា ឬបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារផ្សេងទៀត ដូចមានចែងនៅក្នុងមាត្រាទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ។ ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ គឺជាតួនាទីនិងភារកិច្ចរបស់ អគ្គនាយកដ្ឋានពន្ធដារ ដូចមានចែងនៅក្នុងមាត្រា១៩៥ មាត្រា២២៨មាត្រា២២៩ និងមាត្រា២៣០ នៃច្បាប់ស្តីពីសារពើពន្ធ អនុក្រឹត្យលេខ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រកាសលេខ១២៣២

សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ និងការកែសម្រួលជាបន្តបន្ទាប់ និងប្រកាសលេខ២៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ស្តីពីសវនកម្មពន្ធដារ ប្រកាសលេខ១០២ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២២ ស្តីពីការកែសម្រួលប្រកាសលេខ ១២៣២ សហវ.ប្រក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីបំពេញបន្ថែមភារកិច្ចនិងរចនាសម្ព័ន្ធឱ្យនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ។




លទ្ធផលការងារសំខាន់ៗសម្រេចបានក្នុងឆ្នាំ២០២០ ដែលអគ្គនាយកដ្ឋានពន្ធដារសម្រេចបានមានដូចខាងក្រោម៖

- បានធ្វើបច្ចុប្បន្នភាពនិងកែសម្រួលប្រកាស ស្តីពីពន្ធលើប្រាក់ចំណេញដែលមានអាយុកាលប្រមាណជា១៧ឆ្នាំ តាមរយៈការដាក់ចេញនូវប្រកាសស្តីពីពន្ធលើប្រាក់ចំណូល ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ និងដោះស្រាយបញ្ហាប្រឈមនានាលើកឡើងដោយវិស័យឯកជន
- បានធ្វើការកែទម្រង់ការគ្រប់គ្រងប្រមូលបំណុលពន្ធដារ តាមរយៈការដាក់ចេញនូវប្រកាសស្តីពីការគ្រប់គ្រងបំណុលពន្ធដារ ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការគ្រប់គ្រង ប្រមូលចំណូល ពន្ធ ដោះស្រាយបញ្ហាប្រឈមផ្តល់ភាពច្បាស់លាស់ និងត្រឹមត្រូវក្នុងការកត់ត្រាតាមដាន ឥណទេយ្យពន្ធ និងអ្នកជាប់ពន្ធងាយស្រួលតាមដាន និងអនុវត្តកាតព្វកិច្ចសារពើពន្ធ
- បានដាក់ឱ្យអនុវត្ត ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ(E-Filing) ដោយភ្ជាប់ជាមួយមុខងារទូទាត់ប្រាក់ពន្ធតាមរយៈប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធធនាគារ ដើម្បីពង្រឹងនូវប្រសិទ្ធភាព តម្លាភាព និងសុក្រឹតភាព នៃការគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធ ព្រមទាំងជាការផ្តល់ភាពងាយស្រួល ជូនអ្នកជាប់ពន្ធដោយកាត់បន្ថយពេលវេលា និងបញ្ហាប្រឈមផ្សេងៗ ក្នុងការបំពេញការដាក់លិខិតប្រកាស និងការទូទាត់ប្រាក់ពន្ធបានចូលរួមរៀបចំ និងអនុវត្តនូវយន្តការចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

(IT Platform) និងបានពង្រឹងយន្តការចុះបញ្ជីពន្ធដារ តាមរយៈប្រកាសស្តីពីការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ

- បានចូលរួមរៀបចំ និងអនុវត្តប្រកាសអន្តរក្រសួងលេខ២៦៤ ប្រក.សក.ដជគ ស្តីពីបែបបទនិងនីតិវិធីនៃការផ្ទេរកម្មសិទ្ធិយានយន្ត រវាងក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលផ្តល់នូវយន្តការផ្តល់សេវាបង់ពន្ធប្រថាប់ត្រា លើការផ្ទេរកម្មសិទ្ធិយានជំនិះ ដោយផ្តល់ជម្រើសបន្ថែមជូនប្រជាពល រដ្ឋអាចដាក់ពាក្យ និងបង់ប្រាក់ពន្ធតាមប្រព័ន្ធអនឡាញ
- បានដាក់ឱ្យប្រើប្រាស់សាកល្បង នូវប្រព័ន្ធស្វ័យប្រវត្តិកម្ម ចែករំលែកទិន្នន័យព័ត៌មាន រវាងអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាបានចូលរួមរៀបចំ និងអនុវត្តវិធានការរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងផ្នែកពន្ធដារ ដើម្បីគ្រប់គ្រងផលប៉ះពាល់លើវិស័យសំខាន់ៗ នៃសេដ្ឋកិច្ចក្នុងបរិការណ៍នៃវិបត្តិជំងឺកូវីដ-១៩
- បានដាក់ឱ្យអនុវត្តនូវគោលការណ៍ នៃកម្មវិធីកែទម្រង់ធនធានមនុស្ស ជាពិសេសគោលការណ៍កំណត់ចំណាត់ថ្នាក់នៃកម្រិតប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ប្រធានអង្គភាព (Merit and Demerit System)
- បានបន្តធ្វើទំនើបកម្ម ប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានក្នុងគោលដៅពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងការផ្តល់សេវាជូនអ្នកជាប់ពន្ធដោយក្នុងឆ្នាំ២០២០ បានអភិវឌ្ឍប្រព័ន្ធចំនួន១៨ កម្មវិធីចំនួន៤ និងបានធ្វើបច្ចុប្បន្នភាពប្រព័ន្ធ និងកម្មវិធីចំនួន២៣ ហើយ គិតចាប់ពីឆ្នាំ២០១៤-២០២០ មានប្រព័ន្ធ និងកម្មវិធីដែលបានអភិវឌ្ឍសរុបចំនួន៨៦
- បានរួមចំណែកអនុវត្តដោយជោគជ័យ និងប្រសិទ្ធភាព សម្រាប់ផែនការឆ្នាំ២០២០ ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ កៀរគរចំណូល ២០១៩-២០២៣ និងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល
- ក្នុងបរិការណ៍នៃស្ថានភាពសេដ្ឋកិច្ចសកល ក៏ដូចជាសេដ្ឋកិច្ចកម្ពុជាមិនទាន់មានភាពប្រាកដប្រជា
- ជាពិសេសការទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីការរីករាលដាលនៃជំងឺកូវីដ១៩ បានអនុវត្តការគ្រប់គ្រងប្រមូលចំណូលគ្រប់ និងលើសផែនការច្បាប់ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០២០ និងបានចូលរួមរៀបចំច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១។
- បន្តជំរុញបញ្ចប់ការរៀបចំ ធ្វើបច្ចុប្បន្នភាពច្បាប់ស្តីពីសារពើពន្ធ ដើម្បីឆ្លើយតបនឹងការរីកចម្រើននៃសេដ្ឋកិច្ចជាតិ ធានាភាពច្បាស់លាស់ ប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព នីត្យានុកូលភាព និងសង្គតិភាពនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ
- ត្រៀមអនុវត្តយន្តការគ្រប់គ្រង ប្រមូលចំណូលពន្ធលើវិស័យផលិតស្រាបៀរ ដោយកែសម្រួលការគ្រប់គ្រង ប្រមូលចំណូលពន្ធ ដោយប្រើប្រាស់ឧបករណ៍ទំនើបស្វ័យប្រវត្តិ

- បន្តពង្រឹងការគ្រប់គ្រងប្រមូលចំណូលពន្ធលើវិស័យ ដែលនៅមានសក្តានុពល ដើម្បីធានាបាននូវតម្លាភាព និងមានភាពប្រកួតប្រជែងជាអាទិ៍វិស័យទូរគមនាគមន៍ វិស័យស្រាបៀរ និងភេសជ្ជៈ វិស័យថ្នាំជក់ និងបារី
- បន្តធ្វើទំនើបកម្ម លើប្រព័ន្ធគ្រប់គ្រងបំណុលពន្ធ ដែលនឹងកត់ត្រានិងរក្សាប្រវត្តិបំណុលពន្ធច្បាស់លាស់ មានការវិភាគនូវហានិភ័យបំណុលពន្ធត្រឹមត្រូវ និងផ្តល់លទ្ធភាពខ្ពស់ដល់រដ្ឋបាលសារពើពន្ធក្នុងការគ្រប់គ្រងប្រមូលបំណុលពន្ធ
- ត្រៀមដាក់ឱ្យប្រើប្រាស់នូវកម្មវិធីបង់ប្រាក់ពន្ធ លើអចលនទ្រព្យតាមទូរស័ព្ទ ដែលនឹងផ្តល់ភាពងាយស្រួលជូនអ្នកជាប់ពន្ធ ក្នុងការពិនិត្យព័ត៌មានអចលនទ្រព្យរបស់ខ្លួន និងបង់ពន្ធលើអចលនទ្រព្យតាមទូរសព្ទដៃតែម្តង
- ត្រៀមដាក់ឱ្យអនុវត្តកម្មវិធីបង់ពន្ធ លើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទតាមអនឡាញ ដែលនឹងផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធអាចបង់ប្រាក់ពន្ធ តាមអនឡាញ ហើយរដ្ឋបាលសារពើពន្ធនឹងបញ្ជូនសាលបត្របញ្ជាក់ការបង់ប្រាក់ពន្ធ ដល់គេហដ្ឋានរបស់អ្នកជាប់ពន្ធតែម្តង
- បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធីតាមរយៈការអភិវឌ្ឍន៍ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធ និងកម្មវិធីថ្មីៗ
- បន្តពង្រឹងការផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារព្រមទាំងកំណែទម្រង់ និងទំនើបកម្មរដ្ឋបាលសារពើពន្ធដោយធ្វើឡើងតាមកិច្ចប្រជុំ សិក្ខាសាលា វិបស្សនា ប្រព័ន្ធផ្សព្វផ្សាយនានា គេហទំព័រ ទំព័រទំនាក់ទំនងសង្គម និងការផ្សាយផ្ទាល់តាមអនឡាញពីមជ្ឈមណ្ឌលឆ្លើយតបតាមទូរស័ព្ទ (Call center) ជាពិសេសការរៀបចំកម្មវិធីពន្ធដារកម្ពុជាដោយមានការជួបជជែកជាមួយអ្នកជាប់ពន្ធផ្ទាល់ តាមប្រព័ន្ធបណ្តាញសង្គម Facebook (GDT Facebook Live) ដើម្បីពន្យល់ និងដោះស្រាយការលំបាក និងចម្ងល់របស់ប្រជាពលរដ្ឋ។



## ២.២ ភារកិច្ច និងសិទ្ធអ្នកជាប់ពន្ធ

### ២.២.១ និយមន័យកាតព្វកិច្ច

- **កាតព្វកិច្ច៖** គឺជាចំណងតាមផ្លូវច្បាប់ ដែលចងបុគ្គលពីរនាក់ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់ហៅថា «កូនបំណុល» មានករណីយកិច្ចមួយចំនួនចំពោះបុគ្គលម្នាក់ទៀតដែលបានកំណត់ហៅថា «ម្ចាស់បំណុល»[5]។
- **កាតព្វកិច្ច៖** គឺជាចំណងនៃសិទ្ធ ដែលបង្ខំជនម្នាក់ឱ្យផ្ទេរកម្មសិទ្ធិ ឬសិទ្ធិណាមួយឱ្យបំពេញនូវកិច្ចការណាមួយ ឬឱ្យឈប់បំពេញនូវកិច្ចការណាមួយដល់ជនម្នាក់ទៀត[6]។
- **កាតព្វកិច្ច៖** ពាក្យទូលំទូលាយមួយដែលមានន័យថា ករណីយកិច្ចណាមួយដូចជាករណីយកិច្ចមួយដែលដាក់បង្គាប់តាមកិច្ចសន្យា ការសន្យាជាលាយលក្ខណ៍អក្សរជាផ្លូវការថានឹងសងប្រាក់ ករណីយកិច្ចចំពោះរដ្ឋាភិបាល, ពន្ធដារ។

### ២.២.២ កាតព្វកិច្ចប្រជាពលរដ្ឋទូទៅ

#### ក. ពន្ធចំណេញលើមូលធន

ពន្ធលើចំណេញមូលធន ត្រូវអនុវត្តលើចំណេញមូលធនសម្រេចបានពីការលក់ ឬផ្ទេរ៖

- មូលធននៅក្នុងព្រះរាជាណាចក្រកម្ពុជានិងនៅបរទេសចំពោះរូបវន្តបុគ្គលនិវាសនជន
- មូលធននៅក្នុងព្រះរាជាណាចក្រកម្ពុជាចំពោះរូបវន្តបុគ្គលនិងនីតិបុគ្គលអនិវាសនជន។

មូលធនរួមមាន៖ អចលនទ្រព្យ ភតិសន្យា ទ្រព្យវិនិយោគ កេរ្តិ៍ឈ្មោះអាជីវកម្ម កម្មសិទ្ធិបញ្ញា រូបិយវត្ថុបរទេស។

- **កាតព្វកិច្ចនិងបែបបទនៃការប្រកាសបង់ប្រាក់ពន្ធ**

អ្នកជាប់ពន្ធ ត្រូវដាក់លិខិតប្រកាស និងបង់ពន្ធលើចំណេញមូលធនតាមប្រតិបត្តិការនីមួយៗជូនរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេលមិនលើសពី ០៣ខែ បន្ទាប់ពីសម្រេចបានចំណេញមូលធន។

- ចំពោះទ្រព្យដែលស្ថិតនៅរាជធានីភ្នំពេញត្រូវដាក់លិខិតប្រកាសនៅអគ្គនាយកដ្ឋានពន្ធដារ និងបង់ប្រាក់ពន្ធនៅធនាគារដៃគូជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ចំពោះទ្រព្យ ដែលស្ថិតនៅតាមបណ្តាខេត្តត្រូវដាក់លិខិតប្រកាស នៅសាខាពន្ធដារខេត្ត ដែលទ្រព្យនោះស្ថិតនៅ ឬនៅអគ្គនាយកដ្ឋានពន្ធដារតាមការស្នើសុំរបស់អ្នកជាប់ពន្ធ និងត្រូវបង់ប្រាក់ពន្ធនៅសាខាពន្ធដារខេត្ត ឬនៅធនាគារដៃគូជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

#### ខ.ពន្ធលើអចលនទ្រព្យ

ពន្ធលើអចលនទ្រព្យ គឺជាប្រភេទពន្ធប្រចាំឆ្នាំ។ ពន្ធនេះ ប្រមូលចំពោះអចលនទ្រព្យ ដែលមានតម្លៃលើសពី១០០លានរៀល និងមានទីតាំងស្ថិតនៅក្នុងភូមិសាស្ត្ររដ្ឋបាលរាជធានី និងរដ្ឋបាលក្រុងនៃខេត្តនានា

---

[5] គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់«សន្ទានុក្រមពាក្យច្បាប់ ខ្មែរ~អង់គ្លេស~បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី» ទំព័រទី១ ឆ្នាំ២០០៧ មាន ១៨ទំព័រ។

[6] ផេង វិច្ឆ័យ «សន្ទានុក្រម ច្បាប់ ភូមិបាល» ទំព័រទី១ ឆ្នាំ២០០១ មាន ៩ទំព័រ។

ក្នុងព្រះរាជាណាចក្រកម្ពុជា។ ការប្រមូលពន្ធលើអចលនទ្រព្យនេះគឺសម្រាប់ជាផលប្រយោជន៍ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

❖ **កាតព្វកិច្ចនិងបែបបទនៃការប្រកាសបង់ពន្ធ**




ពន្ធនេះ ជាប្រភេទពន្ធស្វ័យប្រកាសដែលតម្រូវឱ្យកម្មសិទ្ធិករ ឬអ្នកកាន់កាប់ ឬអ្នកទទួលផលប្រយោជន៍ចុងក្រោយ ត្រូវមកចុះបញ្ជីអចលនទ្រព្យ ឬធ្វើបច្ចុប្បន្នភាពព័ត៌មានអចលនទ្រព្យ និងដាក់លិខិតប្រកាសបង់ពន្ធ នៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌដែលអចលនទ្រព្យស្ថិតនៅ។ អ្នកជាប់ពន្ធត្រូវបង់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំជាប់ពន្ធនីមួយៗ និងត្រូវបង់ប្រាក់ពន្ធនៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅធនាគារជាដៃគូជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬតាមរយៈកម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ GDT Taxpayer App ដែលមានក្នុង App Store និង Play Store។

**គ.ពន្ធលើឈ្នួលផ្ទះ និងដី**

ពន្ធឈ្នួលផ្ទះ និងដី ត្រូវបានកំណត់យកលើប្រាក់ឈ្នួលដែលបានមកពីការជួលៈ




- អគារដែលសង់លើដីដូចជាផ្ទះ រោងចក្រ សណ្ឋាគារ ការិយាល័យយន្តឧបករណ៍ដែលជាប់ជាមួយគ្រឹះស្ថានឧស្សាហកម្ម
- វាយនភ័ណ្ឌពាណិជ្ជកម្ម ឧស្សាហកម្ម ដែលនៅនឹងមួយកន្លែងអាគារធំៗដែលដាក់ធាតុរាវឬផលិតផលផ្សេងៗ ដូចជាប្រេងឥន្ធនៈ កៅស៊ូចាក់ថ្នល់ គ្រាប់ធញ្ញជាតិ
- ផ្ទះបណ្តែតទឹក កប៉ាល់សំរាប់ធ្វើលំនៅដ្ឋាន ឬដើម្បីប្រកបអាជីវកម្មផ្សេងៗ
- ដីធ្លីដែលគ្មានសំណង់ដោយរាប់បញ្ចូលទាំងកន្លែងយកថ្ម យករ៉ែ ធ្យូងថ្ម បឹងបួរ ឬស្រែអំបិល។

ពន្ធនេះត្រូវប្រមូលពីកម្មសិទ្ធិករ ឬសិទ្ធិវន្តរបស់កម្មសិទ្ធិករ។ បើករណីអ្នកជួលជា សហគ្រាសបានចុះបញ្ជីពន្ធដារក្នុងរបបស្វ័យប្រកាស ប្រាក់ឈ្នួលនេះត្រូវបានបង្វែរមកគិតពន្ធនឹងបង់តាមវិធានពន្ធកាត់ទុកទូទៅវិញក្នុងអត្រា១០%។ ពន្ធនេះមិនត្រូវអនុវត្តទេ ចំពោះកម្មសិទ្ធករ ឬសិទ្ធវន្តរបស់កម្មសិទ្ធករ ដែលបានប្រកាសចំណូលប្រាក់ឈ្នួលគិតបញ្ចូលជាប់ពន្ធលើប្រាក់ចំណូលតាមរបបស្វ័យប្រកាស។

❖ **កាតព្វកិច្ច និងបែបបទនៃការប្រកាសបង់ពន្ធ**

ប្រាក់ពន្ធនេះ ត្រូវបង់ប្រចាំខែជារៀងរាល់ខែដោយគិតចាប់ពីថ្ងៃដែលបានចុះកិច្ចសន្យា ឬបានព្រមព្រៀងគ្នា។ ម្ចាស់កម្មសិទ្ធិត្រូវប្រកាសក្នុងរយៈពេល ១៥ថ្ងៃគិតចាប់ពីថ្ងៃចុះកិច្ចសន្យាជួល ឬចាប់ពីថ្ងៃមានការប្រែប្រួលអំពីកិច្ចសន្យាជូនទៅអង្គភាពពន្ធដារ នៅក្នុងមូលដ្ឋានដែលទ្រព្យសម្បត្តិជួលនោះស្ថិតនៅ និងត្រូវភ្ជាប់ច្បាប់ថតចម្លងនៃកិច្ចសន្យាជួលចំនួន១ច្បាប់ផង។ ពេលឈប់ជួលក្នុងរវាង ១៥ ថ្ងៃម្ចាស់កម្មសិទ្ធិត្រូវ

ប្រកាសជាលាយលក្ខណ៍អក្សរជូនទៅអង្គភាពពន្ធដារជាមុន។ បើក្នុងករណី ដែលកម្មសិទ្ធិករមិនព្រមបង់ពន្ធលើឈ្នួលផ្ទះ ឬដីនោះអ្នកជួលមានភារកិច្ចទទួលខុសត្រូវដកយកប្រាក់ថ្លៃឈ្នួល ដើម្បីបង់ពន្ធឱ្យគ្រប់ចំនួន។

**ឃ. ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ**

ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ គឺជាពន្ធប្រចាំឆ្នាំ។ ពន្ធនេះប្រមូលចំពោះមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទដូចជា រថយន្តទេសចរណ៍ រថយន្តដឹកទំនិញ រថយន្តដឹកអ្នកដំណើរ រ៉ឺម៉កសណ្តោង ជលយាន ឬជលយានយន្ត (លើសពី១៥០ សេះ) ទាំងផ្លូវទន្លេ និងសមុទ្រ។ ពន្ធនេះ គឺជាពន្ធផ្ទាល់ សម្រាប់ជាគុណប្រយោជន៍ដល់ថវិកាថ្នាក់ក្រោមជាតិ។

❖ **កាតព្វកិច្ច និងបែបបទនៃការប្រកាសបង់ពន្ធ**

ពន្ធនេះជាពន្ធស្វ័យប្រកាស ដែលតម្រូវឱ្យកម្មសិទ្ធិករ ឬអ្នកកាន់កាប់មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទត្រូវមកចុះបញ្ជី និងដាក់លិខិតប្រកាសបង់ប្រាក់ពន្ធយ៉ាងយឺតបំផុត នៅថ្ងៃទី៣០ ខែវិច្ឆិកា នៃឆ្នាំជាប់ពន្ធនីមួយៗ នៅអគ្គនាយកដ្ឋានពន្ធដារ ឬសាខាពន្ធដារខេត្ត-ខណ្ឌ ឬធនាគារដៃគូជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កម្មសិទ្ធិករក៏អាចប្រកាសបង់ប្រាក់ពន្ធតាមរយៈទូរស័ព្ទដៃក្នុងកម្មវិធី GDT Taxpayer App ដែលអាចទាញយកបានពី App Store ឬ Play Store។

**ង.ពន្ធលើដីធ្លីដែលមិនបានប្រើប្រាស់**

ពន្ធលើដីធ្លីមិនបានប្រើប្រាស់ គឺជាប្រភេទពន្ធប្រចាំឆ្នាំ។ ពន្ធនេះ កំណត់លើដីដែលគ្មានសំណង់ និងដីដែលមានសំណង់បោះបង់ស្ថិតក្នុងទីក្រុងនានា និងក្នុងតំបន់ទាំងឡាយ ដែលកំណត់ដោយគណៈកម្មការវាយតម្លៃដីធ្លីមិនបានប្រើប្រាស់។ ពន្ធលើដីធ្លីមិនបានប្រើប្រាស់ មានគោលបំណងដើម្បី៖

- ទប់ស្កាត់រាល់រូបភាពទិញដីទុកមិនប្រើប្រាស់ រង់ចាំពេលឡើងថ្លៃលក់យកកម្រៃលើស
- ជំរុញការប្រើប្រាស់ដីធ្លីឱ្យបានសមស្រប និងមានការអភិវឌ្ឍន៍
- បង្កើនសកម្មភាពសេដ្ឋកិច្ច និងកម្លាំងការងារ
- រួមចំណែកដល់ប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។

❖ **កាតព្វកិច្ច និងបែបបទនៃការប្រកាសបង់ពន្ធ**

ពន្ធនេះជាប្រភេទពន្ធស្វ័យប្រកាស ដែលតម្រូវឱ្យកម្មសិទ្ធិករនៃដីជាប់ពន្ធ និងអ្នកជួលដីពីរដ្ឋត្រូវមកចុះបញ្ជី និងដាក់លិខិតប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ នៅអគ្គនាយកដ្ឋានពន្ធដារ ចំពោះដីដែលស្ថិតនៅរាជធានីភ្នំពេញនិងនៅខេត្ត ឬនៅសាខាពន្ធដារខេត្តដែលដីនោះស្ថិតនៅ។ អ្នកជាប់ពន្ធត្រូវបង់ពន្ធយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំជាប់ពន្ធនីមួយៗ និងត្រូវបង់ប្រាក់ពន្ធនៅសាខាពន្ធដារខេត្ត ឬនៅធនាគារជាដៃគូជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ច. ពន្ធប្រថាប់ត្រា**

**ពន្ធប្រថាប់ត្រា** គឺជាប្រភេទពន្ធដែលកំណត់លើ ៖

- ការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ឬការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន
- ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូនឬយានយន្តគ្រប់ប្រភេទ
- ការផ្ទេរចំណែកណាមួយ ឬទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន

- កិច្ចសន្យាផ្គត់ផ្គង់ទំនិញឬសេវា ដែលប្រើប្រាស់ថវិការដ្ឋ
- លិខិតមានលក្ខណៈគតិយុត្តិ ដូចជា ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន

ពន្ធនេះត្រូវបានបង្កើតដើម្បីជាគុណប្រយោជន៍ដល់ថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់អភិវឌ្ឍមូលដ្ឋាន។ ប្រភេទពន្ធនេះត្រូវប្រមូលពីអ្នកទទួលសិទ្ធិកាន់កាប់។ ពន្ធប្រថាប់ត្រា ដែលប្រជាពលរដ្ឋទូទៅតែងតែជួបប្រទះញឹកញាប់ចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់មានដូចខាងក្រោម៖

**១. ពន្ធប្រថាប់ត្រា ចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ** គឺជាពន្ធដែលត្រូវបង់នៅពេលមានការទិញលក់ឬដោះដូរឬធ្វើអំណោយអចលនទ្រព្យឬការដាក់ហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន។

❖ **កាតព្វកិច្ចនិងបែបបទនៃការប្រកាសបង់ពន្ធ**

អ្នកជាប់ពន្ធមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ពន្ធប្រថាប់ត្រាឱ្យបានគ្រប់ក្នុងរយៈពេល **៣ ខែ** បន្ទាប់ពីកាលបរិច្ឆេទនៃ "**ដីកាបញ្ជូន**" សំណុំឯកសារ៖

- ផ្ទេរកម្មសិទ្ធិរបស់រដ្ឋបាលសុរិយោដីរាជធានី-ខេត្ត ចំពោះអចលនទ្រព្យបានចុះបញ្ជី (មានប័ណ្ណកម្មសិទ្ធិ)
- ផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យរបស់អាជ្ញាធរដែនដី (ក្រុង-ស្រុក-ខណ្ឌ) ចំពោះអចលនទ្រព្យពុំបានចុះបញ្ជី (គ្មានប័ណ្ណកម្មសិទ្ធិ) និងត្រូវបង់ប្រាក់ពន្ធនៅសាខាពន្ធដារខេត្ត-ខណ្ឌ ឬនៅធនាគារជាដៃគូជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អ្នកជាប់ពន្ធត្រូវដាក់លិខិតប្រកាសនៅអគ្គនាយកដ្ឋានពន្ធដារ និងបង់ប្រាក់ពន្ធ នៅធនាគារជាដៃគូជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចំពោះអចលនទ្រព្យនៅរាជធានីភ្នំពេញ ហើយចំពោះអចលនទ្រព្យតាមបណ្តាខេត្ត អាចដាក់លិខិតប្រកាសនៅសាខាពន្ធដារខេត្ត ដែលអចលនទ្រព្យនោះស្ថិតនៅ ឬនៅអគ្គនាយកដ្ឋានពន្ធដារតាមការស្នើសុំរបស់អ្នកជាប់ពន្ធ និងត្រូវបង់ប្រាក់ពន្ធនៅសាខាពន្ធដារខេត្ត ឬនៅធនាគារជាដៃគូជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**២. ពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់យានជំនិះគ្រប់ប្រភេទ** គឺជាពន្ធដែលត្រូវបង់នៅពេលផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់យានជំនិះគ្រប់ប្រភេទ រួមមានការទិញលក់ ឬការដោះដូរ ឬការធ្វើអំណោយ ឬការដាក់ភាគហ៊ុនក្នុងក្រុមហ៊ុននូវមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ។

❖ **កាតព្វកិច្ចនិងបែបបទនៃការប្រកាសបង់ពន្ធ**

ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានជំនិះត្រូវប្រមូលពីអ្នកទទួលសិទ្ធិ ឬហៅកាត់ថាអ្នកទិញ។ អ្នកជាប់ពន្ធ មានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រថាប់ត្រាឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេល ៣ខែ បន្ទាប់ពីកាលបរិច្ឆេទនៃពាក្យស្នើសុំផ្ទេរកម្មសិទ្ធិយានជំនិះរបស់មន្ទីរសាធារណៈការនិងដឹកជញ្ជូន។

**២.២.៣ កាតព្វកិច្ច និងសិទ្ធរបស់អ្នកជាប់ពន្ធតូច**

**ក.កាតព្វកិច្ចអ្នកជាប់ពន្ធតូច**

**១.ការចុះបញ្ជីពន្ធដារ**

**បុគ្គលទាំងឡាយ** ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥ ថ្ងៃនៃថ្ងៃធ្វើការក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតពីក្រសួង-ស្ថាប័នពាក់ព័ន្ធ។

### ២.ការកាន់បញ្ជីកាគណនេយ្យ

អ្នកជាប់ពន្ធ ត្រូវកាន់កាប់បញ្ជីគណនេយ្យសាមញ្ញ ដើម្បីជួយសម្រួលដល់អាជីវកម្មតូចៗ ឬលក្ខណៈគ្រួសារ ក្នុងការកត់ត្រាប្រតិបត្តិការប្រចាំថ្ងៃ ហើយបញ្ជីនេះរួមមាន បញ្ជីទិញប្រចាំថ្ងៃ បញ្ជីលក់ប្រចាំថ្ងៃ និងបញ្ជីស្តុកទំនិញ។

### ៣. វិធានវិក្កយបត្រ

អ្នកជាប់ពន្ធតូចត្រូវចេញវិក្កយបត្រធម្មតា( Commercial Invoice )ដោយត្រូវមាននិទ្ទេសដូចខាងក្រោម៖

- ឈ្មោះសហគ្រាស អាសយដ្ឋាន និងលេខអត្តសញ្ញាណកម្មសារពើពន្ធរបស់អ្នកលក់ ឬអ្នកផ្គត់ផ្គង់
- លេខរៀងវិក្កយបត្រតាមលំដាប់ និងកាលបរិច្ឆេទចេញវិក្កយបត្រ
- ឈ្មោះនិងអាសយដ្ឋានរបស់អ្នកទិញ
- សេចក្តីបរិយាយមុខទំនិញឬសេវា បរិមាណ និងថ្លៃ
- តម្លៃរួមបញ្ចូលទាំងអាករនានានៃទំនិញនីមួយៗ
- ហត្ថលេខា និងឈ្មោះរបស់អ្នកលក់។

### ៤. ការដាក់លិខិតប្រកាសនិងបង់ពន្ធអាករនានា

ពន្ធប្រចាំខែសំខាន់ៗរួមមាន៖

- ប្រាក់រំដោះពន្ធលើប្រាក់ចំណូល៖ ប្រាក់រំដោះពន្ធនេះត្រូវបង់ជារៀងរាល់ខែ តាមអត្រា១%នៃផលរបររួមទាំងអាករនានាលើកលែងអាករលើតម្លៃបន្ថែម
- អាករលើតម្លៃបន្ថែម៖ ត្រូវបង់សម្រាប់ខែនីមួយៗ បានអនុញ្ញាតជាឥណទានអាករលើធាតុចូល ៨០% សម្រាប់កាត់កងនឹងអាករលើធាតុចេញ ទោះមានឬគ្មានវិក្កយបត្របញ្ជាក់
- ពន្ធកាត់ទុកលើការជួល៖ អ្នកជាប់ពន្ធ ត្រូវបានអនុគ្រោះពីកាតព្វកិច្ចជាភ្នាក់ងារកាត់ទុក លើកលែងតែពន្ធកាត់ទុកលើថ្លៃឈ្នួលលើចលនទ្រព្យ និងអចលនទ្រព្យសម្រាប់អត្រាពន្ធ១០%
- ពន្ធលើប្រាក់បៀវត្ស៖ សម្រាប់សហគ្រាសដែលមានបុគ្គលិកត្រូវជាប់ពន្ធ។

អ្នកជាប់ពន្ធត្រូវបង់ប្រាក់ពន្ធ និងដាក់លិខិតប្រកាសពន្ធប្រចាំខែចាប់ពីថ្ងៃទី០១ ដល់ ថ្ងៃទី២៥ នៃខែបន្ទាប់នៅអគ្គនាយកដ្ឋានពន្ធដារ ឬដាក់លិខិតប្រកាសពន្ធតាមប្រព័ន្ធ GDT Tax Pre-filing App។ ពន្ធប្រចាំឆ្នាំសំខាន់ៗរួមមាន៖

- ពន្ធប៉ាតង់៖ ៤០០.០០០រៀល ក្នុង១ឆ្នាំ សម្រាប់១សកម្មភាព
- ពន្ធលើប្រាក់ចំណូល៖ ការគណនាប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំណាមួយ ត្រូវយកប្រាក់ចំណូលសរុបប្រចាំឆ្នាំនោះ ដកថ្លៃដើមទំនិញ ឬសេវាដែលបានលក់ ដកចំណាយចរន្ត ដករំលស់ទ្រព្យអចលកម្ម។

- ពន្ធអប្បបរមា៖ កំណត់តាមអត្រា១% លើផលរបរប្រចាំឆ្នាំរួមទាំងអាករនានាលើកលែងអាករលើតម្លៃបន្ថែម។

**ខ.សិទ្ធិរបស់អ្នកជាប់ពន្ធតូច**

អ្នកជាប់ពន្ធតូចនឹងទទួលបានសិទ្ធិរបស់ខ្លួនដូចតទៅ៖

- ទទួលបានការរក្សាទុកជាការសម្ងាត់នូវរាល់ព័ត៌មានដែលអ្នកជាប់ពន្ធបានផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- ទទួលបានការផ្តល់សេវាប្រកបដោយវិជ្ជាជីវៈ និងមានការជួយពន្យល់ណែនាំឱ្យបានយល់អំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារនីតិវិធីសារពើពន្ធ និងការអនុវត្តន៍កាតព្វកិច្ចសារពើពន្ធ
- ទទួលបានការពន្យល់រាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធចំពោះកិច្ចការសារពើពន្ធ
- ប្តឹងតវ៉ាចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ
- បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់
- មានការទទួលស្គាល់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ តាមការជ្រើសរើសដើម្បីផ្តល់យោបល់អំពីកិច្ចការសារពើពន្ធ
- ទទួលបានការអនុវត្តន៍ដោយមានតម្លាភាព និង មិនលម្អៀងពីសំណាក់រដ្ឋបាលសារពើពន្ធ
- ទទួលបានការទទួលស្គាល់អំពីភាពស្មោះត្រង់ក្នុងការអនុវត្តកាតព្វកិច្ចសារពើពន្ធ។

## ២.២.៤ កាតព្វកិច្ច និងសិទ្ធរបស់អ្នកជាប់ពន្ធមធ្យម

### ក.កាតព្វកិច្ចរបស់អ្នកជាប់ពន្ធមធ្យម

**១. ការចុះបញ្ជីពន្ធដារ**

បុគ្គលទាំងឡាយ ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥ ថ្ងៃនៃថ្ងៃធ្វើការ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោយពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតពីក្រសួង-ស្ថាប័នពាក់ព័ន្ធ។

**២. ការកាន់បញ្ជីកាគណនេយ្យ**

អ្នកជាប់ពន្ធ ត្រូវប្រើវិធានគណនេយ្យតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា៖

- ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនទាន់ទូទាត់ក្តី
- ការកាត់កងចំណាយណាមួយអាចធ្វើទៅបាន លុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធបានកើតឡើង លទ្ធផលនៃសកម្មភាព សេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់។

**៣. វិធានវិក្កយបត្រ**

អ្នកជាប់ពន្ធមធ្យមត្រូវចេញវិក្កយបត្រដូចខាងក្រោម៖

- វិក្កយបត្រអាករដល់អតិថិជនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
- វិក្កយបត្រធម្មតាដល់អតិថិជនដែលជាអ្នកប្រើប្រាស់

### ៤. ការដាក់លិខិតប្រកាស និងបង់ពន្ធ-អាករនានា

ពន្ធប្រចាំខែសំខាន់ៗរួមមាន៖ ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អាករលើតម្លៃបន្ថែម ពន្ធកាត់ទុកលើការដួលពន្ធលើប្រាក់បៀវត្ស។ ពន្ធប្រចាំខែអ្នកជាប់ពន្ធមធ្យមត្រូវបង់ពន្ធ និងដាក់លិខិតប្រកាសពន្ធចាប់ពីថ្ងៃទី០១ ដល់ថ្ងៃទី២៥នៃខែបន្ទាប់ នៅអគ្គនាយកដ្ឋានពន្ធដារឬដាក់លិខិតប្រកាសតាមប្រព័ន្ធ E-Filing។

ពន្ធប្រចាំឆ្នាំសំខាន់ៗរួមមាន៖ ពន្ធប៉ាតង់ ពន្ធលើប្រាក់ចំណូល ពន្ធអប្បបរមា។

### ខ.សិទ្ធិរបស់អ្នកជាប់ពន្ធមធ្យម

- ទទួលបានការរក្សាទុកជាការសម្ងាត់ នូវរាល់ព័ត៌មានដែលអ្នកជាប់ពន្ធបានផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- ទទួលបានការផ្តល់សេវាប្រកបដោយវិជ្ជាជីវៈ និងមានការជួយពន្យល់ណែនាំឱ្យបានយល់អំពីកិច្ចដំណើរការនៃប្រព័ន្ធពន្ធដារ នីតិវិធីសារពើពន្ធ និងការអនុវត្តន៍កាតព្វកិច្ចសារពើពន្ធ
- ទទួលបានការពន្យល់រាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធចំពោះកិច្ចការសារពើពន្ធ
- ប្តឹងតវ៉ាចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ
- បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់
- មានការទទួលស្គាល់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធតា មការជ្រើសរើសដើម្បីផ្តល់យោបល់អំពីកិច្ចការសារពើពន្ធ
- ទទួលបានការអនុវត្តន៍ដោយមានតម្លាភាព និងមិនលម្អៀងពីសំណាក់រដ្ឋបាលសារពើពន្ធ។

## ២.២.៥ កាតព្វកិច្ច និងសិទ្ធរបស់អ្នកជាប់ពន្ធធំ

### ក.កាតព្វកិច្ចរបស់អ្នកជាប់ពន្ធធំ

#### ១.ការចុះបញ្ជីពន្ធដារ

បុគ្គលទាំងឡាយ ត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុងពេល១៥ ថ្ងៃនៃថ្ងៃធ្វើការក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ឬក្រោពេលទទួលបានលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតអនុញ្ញាតពីក្រសួង-ស្ថាប័នពាក់ព័ន្ធ។

#### ២. ការកាន់បញ្ជីកាគណនេយ្យ

អ្នកជាប់ពន្ធ ត្រូវប្រើវិធានគណនេយ្យតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា៖

- ប្រាក់ចំណូលត្រូវគិតបញ្ចូលនៅក្នុងឆ្នាំ ដែលចំណូលនោះបានកើតឡើង ទោះបីប្រាក់ចំណូលនោះបានទូទាត់ ឬមិនទាន់ទូទាត់ក្តី
- ការកាត់កងចំណាយណាមួយ អាចធ្វើទៅបានលុះណាតែហេតុការណ៍បញ្ជាក់នូវបន្ទុករបស់អ្នកជាប់ពន្ធបានកើតឡើងលទ្ធផលនៃសកម្មភាពសេដ្ឋកិច្ចដែលជាប់ទាក់ទងដល់ខ្ទង់ចំណាយនោះបានកើតឡើង និងចំនួនទឹកប្រាក់ដែលជាបន្ទុករបស់អ្នកជាប់ពន្ធអាចបង្ហាញច្បាស់លាស់។

#### ៣. វិធានវិក្កយបត្រ

អ្នកជាប់ពន្ធធំត្រូវចេញវិក្កយបត្រដូចខាងក្រោម៖

- វិក្កយបត្រអាករដល់អតិថិជនជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស
- វិក្កយបត្រធម្មតាដល់អតិថិជនដែលជាអ្នកប្រើប្រាស់

### ៤. ការដាក់លិខិតប្រកាស និងបង់ពន្ធនិងអាករនានា

ពន្ធប្រចាំខែសំខាន់ៗរួមមាន៖ ប្រាក់រំដោះពន្ធលើប្រាក់ចំណូល អាករលើតម្លៃបន្ថែម ពន្ធកាត់ទុកលើការជួល ពន្ធលើប្រាក់បៀវត្ស។ ពន្ធប្រចាំខែអ្នកជាប់ពន្ធធំត្រូវបង់ពន្ធ និងដាក់លិខិតប្រកាសពន្ធចាប់ពីថ្ងៃទី ០១ ដល់ថ្ងៃទី២៥ នៃខែបន្ទាប់នៅអគ្គនាយកដ្ឋានពន្ធដារ ឬដាក់លិខិតប្រកាសតាមប្រព័ន្ធ E-Filing។

ពន្ធប្រចាំឆ្នាំសំខាន់ៗរួមមាន៖ ពន្ធប៉ាតង់ ពន្ធលើប្រាក់ចំណូល ពន្ធអប្បបរមា។

### ខ.សិទ្ធិរបស់អ្នកជាប់ពន្ធធំ

អ្នកជាប់ពន្ធធំនឹងទទួលបានសិទ្ធិរបស់ខ្លួន ដូចតទៅ៖

- ទទួលបានការរក្សាទុកជាការសម្ងាត់នូវរាល់ព័ត៌មានដែលអ្នកជាប់ពន្ធបានផ្តល់ជូនរដ្ឋបាលសារពើពន្ធ
- ទទួលបានការផ្តល់សេវាប្រកបដោយវិជ្ជាជីវៈនិងមានការជួយពន្យល់ណែនាំឱ្យយល់អំពីកិច្ចដំណើរការនៃប្រព័ន្ធ ពន្ធដារ នីតិវិធីសារពើពន្ធ និងការអនុវត្តន៍កាតព្វកិច្ចសារពើពន្ធ
- ទទួលបានការពន្យល់រាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធចំពោះកិច្ចការសារពើពន្ធ
- ប្តឹងតវ៉ាចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ
- បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់
- មានការទទួលស្គាល់ តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធតាមការជ្រើសរើស ដើម្បីផ្តល់យោបល់អំពីកិច្ចការសារពើពន្ធ។

## ២.៣ នីតិវិធីក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ

### ២.៣.១ និយមន័យនីតិ

**នីតិ** ត្រូវបានគេឱ្យនិយមន័យជាច្រើន៖

- ជាវិធានគ្រប់គ្រងឥរិយាបថសង្គមមនុស្សផ្លូវការ។
- ជាក្បួនឬជាវិន័យប្រដៅមនុស្សឱ្យប្រព្រឹត្តល្អ។
- ជាឧបករណ៍ដើម្បីការពារ និងអភិវឌ្ឍតម្លៃនៃសង្គមមនុស្ស។
- ជាអត្ថបទដែលបញ្ញត្តិអំពីវិធានគតិយុត្តិដោយអង្គការនីតិបញ្ញត្តិ (រដ្ឋសភា និងព្រឹទ្ធសភា) និងត្រូវប្រកាសឱ្យប្រើតាមរយៈព្រះរាជក្រមដែលឡាយព្រះហស្តលេខាដោយប្រមុខរដ្ឋ[7]។

**នីតិ** គឺជាវិទ្យាសាស្ត្រច្បាប់ សិក្សាលើសំណុំវិធានទាំងឡាយណា ដែលមនុស្សជាអ្នកបង្កើតឡើងដើម្បីគ្រប់គ្រងការរស់នៅ និងការទំនាក់ទំនងរបស់មនុស្សក្នុងសង្គមតាមរយៈ ការអនុវត្តន៍ និងផ្តន្ទាទោស(ដាក់ទណ្ឌកម្ម) ដោយអំណាចសាធារណៈ។ លើសពីនេះទៅទៀត នីតិជាមធ្យោបាយដោះស្រាយទំនាស់ក្នុងសង្គម។ **ឧទាហរណ៍:** មនុស្សពីរនាក់ជាមិត្តភក្តិជិតស្និទ្ធនឹងគ្នា ប៉ុន្តែមានម្នាក់បានខ្ចីលុយពីម្នាក់ទៀត ហើយមិនសងរហូតធ្វើឱ្យមានការបែកបាក់មិត្តភាពរវាងគ្នា និងគ្នា ឈានទៅដល់ការប្តឹងទាមទារសំណងផ្សេងៗ។ យន្តការដោះស្រាយទង្វើខាងលើនេះសុទ្ធសឹងតែជាវិធាននៃនីតិ។

[7] វិទ្យាស្ថានវ៉ាន់ដា សេចក្តីផ្តើមនៃនីតិ បោះពុម្ពលើកទី៨(២០១៩) ទំព័រ១៦ មាន ១០១ទំព័រ

**នីតិ** ជាបណ្តុំវិធានគតិយុត្តិទាំងឡាយដែលមានគោលដៅធ្វើឱ្យសង្គមមនុស្សមានសណ្តាប់ធ្នាប់ និងអមមកជាមួយដោយទណ្ឌកម្ម[8]។

**នីតិ** ជាគ្រឿងណែនាំបែបផែន ជាទំនៀមប្រពៃណី ឬជាបណ្តុំនៃវិធានគតិយុត្តិដែលមានចំណង សិទ្ធិនិងកាតព្វកិច្ចមានអានុភាពចាប់បង្ខំលក្ខណៈទូទៅមិនចំពោះ និងមានគោលដៅរៀបចំសណ្តាប់ធ្នាប់សាធារណៈ[9]។

**នីតិ** គឺជាសំណុំឯកសារនៃវិធានគតិយុត្តិទាំងឡាយណា ដែលត្រូវបានបង្កើតឡើងដើម្បីធ្វើការគ្រប់គ្រងឱ្យមានសណ្តាប់ធ្នាប់របស់សង្គម និងរបៀបរៀបរយល្អប្រសើរ[10]។

### ២.៣.២ ចំណាត់ថ្នាក់នៃនីតិ

**១. ចំណាត់ថ្នាក់តាមលោក Cicéron** (១០៦-៤៣ មុនគ.ស ) ជនជាតិរ៉ូម៉ាំងគាត់បានបែងចែកច្បាប់ជា៣គឺ៖

- នីតិធម្មជាតិ
- នីតិវិជ្ជមាន
- នីតិប្រជាជាតិ ឬនីតិអន្តរជាតិ។

**២. ការបែងចែកជានីតិជាតិ និងនីតិអន្តរជាតិ**

**នីតិជាតិ** គឺជាច្បាប់សម្រាប់គ្រប់គ្រងរដ្ឋនីមួយៗ ហើយមានអានុភាពអនុវត្តន៍តែនៅក្នុងផែនដី ឬរដ្ឋនោះតែប៉ុណ្ណោះ ។

**នីតិអន្តរជាតិ** គឺជាច្បាប់សម្រាប់គ្រប់គ្រងទំនាក់ទំនងរដ្ឋ និងរដ្ឋ ឬរវាងរដ្ឋ និងអង្គការអន្តរជាតិ។ ក្នុងក្របខណ្ឌអន្តរជាតិគេត្រូវបង្កើតច្បាប់ថ្មីតាមរយៈការចរចារវាងរដ្ឋ និងរដ្ឋព្រោះរដ្ឋមានអធិបតេយ្យរៀងៗខ្លួនមិនចំណុះក្រោមច្បាប់ជាតិណាមួយឡើយ។

**៣. នីតិសាធារណៈ និងនីតិឯកជន**

**នីតិសាធារណៈ**៖ គឺជានីតិដែលគ្រប់គ្រងទំនាក់ទំនងរវាងអំណាចរដ្ឋ និងបុគ្គលឯកជន។

**នីតិឯកជន**៖ គឺជានីតិដែលគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គលឯកជន និងបុគ្គលឯកជន។

**៤. នីតិវត្ថុវិស័យ និងនីតិអត្តវិស័យ**

**នីតិវត្ថុវិស័យ (Droit objectif /Objective law)**៖ គឺជាវិធានទាំងឡាយដែលគ្រប់គ្រងជីវភាពរស់នៅក្នុងសង្គមដោយមានការដាក់ទណ្ឌកម្មពីអាជ្ញាធរសាធារណៈ។

**នីតិអត្តវិស័យ (Droit subjecti /Subjective Law)**៖ គឺជាបុព្វសិទ្ធិដែលច្បាប់ទទួលស្គាល់ចំពោះបុគ្គលសម្រាប់ប្រើប្រាស់ជាប្រយោជន៍ផ្ទាល់ខ្លួន ព្រមទាំងទទួលបានការការពារពីច្បាប់។

### ២.៣.៣ និយមន័យនៃបទល្មើស

[8] https://www.facebook.com/345437756647388/posts/
[9] https://web.facebook.com/1482208281916621/posts/
[10] https://www.tnaot.com/km/m/detail/article/2127308

**បទល្មើស** គឺជាអំពើប្រឆាំងនឹងរដ្ឋ អំពើដែលនាំឱ្យមានគ្រោះថ្នាក់ដល់សង្គម អំពើប្រឆាំងនឹងច្បាប់ព្រហ្មទណ្ឌជាធរមាន និងត្រូវផ្តន្ទាទោសក្នុងបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ[11]។

**បទល្មើស** គឺជាអំពើនៃការប្រព្រឹត្តិដោយចេតនាឬដោយអចេតនាដែលបណ្តាលឱ្យមានគ្រោះថ្នាក់ដល់សង្គមនិងត្រូវផ្តន្ទាទោសតាមការកំណត់ទុកជាមុននៅក្នុងច្បាប់ព្រហ្មទណ្ឌឬអាចនិយាយម្យ៉ាងទៀតថាជាអំពើបំពានលើច្បាប់ព្រហ្មទណ្ឌ។

**បទល្មើស** គឺជាអំពើទាំងឡាយណាដែលបានប្រព្រឹត្តដោយបុគ្គលណាម្នាក់ ឬច្រើនអ្នកហើយអំពើនោះទៀតសោត បានបង្កឱ្យមានភាពចលាចល ខូចសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ អសន្តិសុខនៅក្នុងសង្គមជាដើម។

**បទល្មើស** គឺជាអំពើប្រព្រឹត្ត ឬការខកខានមិនបានប្រព្រឹត្ត ដែលអាចនាំឱ្យត្រូវផ្តន្ទាទោសព្រហ្មទណ្ឌ ដល់ ជនល្មើសស្របតាមច្បាប់ព្រហ្មទណ្ឌដែលបានចែងទុកជាមុន[12]។

### ២.៣.៤ ចំណាត់ថ្នាក់នៃបទល្មើស

#### ក.ការចាត់ថ្នាក់បទល្មើស

ការចាត់ថ្នាក់បទល្មើស មានរបៀបចាត់ថ្នាក់បទល្មើសច្រើនយ៉ាង ប៉ុន្តែការចាត់ថ្នាក់ដោយយោងលើកម្រិតធ្ងន់ធ្ងរនៃបទល្មើសមានសារៈសំខាន់ជាងគេ។ ការចាត់ថ្នាក់របៀបនេះ មាន៣កម្រិត គឺបទលហុបទមជ្ឈិម និងបទឧក្រិដ្ឋ។ ការចាត់ថ្នាក់បែបនេះ មានប្រយោជន៍ដូចខាងក្រោម៖

**១.ការស្វែងរកនីតិក្នុងការចោទប្រកាន់:** បទល្មើសឧក្រិដ្ឋ គឺព្រះរាជអាជ្ញាជាអ្នកចោទប្រកាន់ហើយត្រូវមានចៅក្រមស៊ើបអង្កេតជាអ្នកស្វែងរកភ័ស្តុតាង។ បទល្មើសមជ្ឈិម ដែលមានទោសតិចជាង៥ឆ្នាំ ព្រះរាជអាជ្ញាអាចធ្វើការចោទប្រកាន់ និងស្វែងរកភ័ស្តុតាងរួចបញ្ជូនទៅតុលាការជំនុំជំរះតែម្តង។ ចំពោះបទលហុ គឺជាកាតព្វកិច្ចរបស់ប៉ូលីស។

**២. ទាក់ទងនឹងអាជ្ញាយុកាលនៃបទល្មើស:** បទល្មើសឧក្រិដ្ឋមានអាជ្ញាយុកាលរយៈពេល២០ឆ្នាំ ឯបទល្មើសមជ្ឈិមមានអាជ្ញាយុកាលរយៈពេល៥ឆ្នាំ ហើយបទលហុមានអាជ្ញាយុកាលរយៈពេល១ឆ្នាំ។

- ទាក់ទងនឹងការចោទប្រកាន់ចំពោះបទល្មើសៈ គ្រប់បទល្មើសឧក្រិដ្ឋ អាចត្រូវគេចោទប្រកាន់ពីបទសមគំនិត ចំពោះបទល្មើសមជ្ឈិម ការចោទប្រកាន់ពីបទសមគំនិតអាចធ្វើទៅបាន លុះត្រាតែមានច្បាប់ចងក្រងច្បាស់លាស់ ហើយបទលហុជាគោលការណ៍គ្មានបទសមគំនិតទេ។
- ទាក់ទងនឹងការអនុវត្តន៍ទោសៈ បទល្មើសឧក្រិដ្ឋមិនអាចត្រូវផ្តន្ទាទោសពិន័យទេ (ជាគោលការណ៍)មានតែទោសពន្ធធនាគារ ចំពោះបទមជ្ឈិមអាចមានទោសពិន័យផង និងទោសពន្ធធនាគារផង។

#### ខ.ធាតុផ្សំបទល្មើស

តាមគោលការណ៍នៃច្បាប់ព្រហ្មទណ្ឌ ដើម្បីអាចឱ្យគេចោទប្រកាន់ថាជនណាម្នាក់ បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌបានលុះត្រាតែមានធាតុផ្សំចូលរួម៣គឺៈ

[11] https://www.khsearch.com/qna/25576
[12] វិទ្យាស្ថានវ៉ាន់ដា សេចក្តីផ្តើមនៃនីតិ បោះពុម្ពលើកទី៨(២០១៩) ទំព័រ ៥៦ មាន ១០១ទំព័រ

**១. ជាតុនីត្យានុកូលឬជាតុច្បាប់៖** មានន័យថា ការចោទប្រកាន់អាចធ្វើទៅបានលុះត្រាតែមានច្បាប់ចែងថាជាអំពើល្មើសនឹងច្បាប់។

**២. ជាតុសត្យានុម័តឬជាតុសម្ភារៈ** មានន័យថា ការចោទប្រកាន់អាចធ្វើទៅបានលុះត្រាតែមានការប្រព្រឹត្តអំពើបទល្មើស។

**៣. ជាតុអត្តនោម័តឬជាតុចេតនាៈ** មានន័យថា ការចោទប្រកាន់អាចធ្វើទៅបានលុះត្រាតែមានចេតនាទុច្ចរិត។ ការខ្វះជាតុណាមួយក្នុងចំណោមជាតុទាំងបីខាងលើ នឹងនាំឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់[13]។

នៅក្នុងនីតិព្រហ្មទណ្ឌជាតុសត្យានុម័តជាជាតុមួយដែលសំខាន់ ក្នុងការកំណត់ថាតើអំពើណាមួយជាបទល្មើស។ ជាតុសត្យានុម័ត ជាអំពើល្មើសទាំងឡាយ ដែលបុគ្គលម្នាក់បានប្រព្រឹត្តក្រោមរូបភាពជាអំពើសកម្មក្តី ឬអសកម្មក្តី ដែលមានចរិកលក្ខណៈបង្កគ្រោះថ្នាក់ដល់សង្គម។ ដើម្បីអនុវត្ត នូវអំពើរបស់ខ្លួនឱ្យបានសម្រេចជនល្មើសប្រាកដជានឹងប្រើប្រាស់ នូវគ្រប់មធ្យោបាយដែលក្នុងនោះជនល្មើស ចាំបាច់ត្រូវប្រើឧបករណ៍ល្មើសមួយ ក្នុងស្ថានភាពនិងពេលវេលាមួយជាកំណត់[14]។

[13] វិទ្យាស្ថានវ៉ាន់ដា សេចក្តីផ្តើមនៃនីតិ បោះពុម្ពលើកទី៨(២០១៩) ទំព័រ ៥៧ មាន ១០១ទំព័រ

[14] https://chuonviraklaw.files.wordpress.com/2015/12/e19e94e19e91e19e9be19f92e19e98e19ebee19e9f-e19e9fe19e89e19f92e19e89e19eb6e19e8e-e19e93e19eb7e19e84e19e85e19e9ae19eb7e19e8fe19e9b.pdf

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

# ជំពូកទី៣
# នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ

## ៣.១ ស្ថានភាពទូទៅរបស់អគ្គនាយកដ្ឋានពន្ធដារ

### ៣.១.១ ប្រវត្តិរបស់អគ្គនាយកដ្ឋានពន្ធដារ




ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងស្រាវជ្រាវអស់រយៈពេលជាច្រើនឆ្នាំកន្លងមកនេះ គឺពុំមានប្រភព ឬកំណត់ត្រាឯកសារជាប្រវត្តិសាស្ត្រជាក់លាក់ច្បាស់ការណាមួយដែលនៅសេសសល់ បន្ទាប់ពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ដើម្បីយកមកធ្វើជាមូលដ្ឋានសម្រាប់ចងក្រង និងរំលេចអំពីសាវតារ និងប្រវត្តិនៃពន្ធដារកម្ពុជានៅក្នុងសៀវភៅនេះ ថាតើពន្ធដារកម្ពុជា មានកំណើតពីឆ្នាំណា និងមានរចនាសម្ព័ន្ធជាក់លាក់ពិតប្រាកដបែបណានោះទេ។

និយាយរួមបច្ចុប្បន្ននេះ គឺពុំមានព័ត៌មានច្បាស់ការណាមួយស្ដីពីសាវតារឬប្រវត្តិពន្ធដារកម្ពុជា ក្នុងអំឡុងពេលមុនឆ្នាំ១៩៧៥ នោះទេ ប៉ុន្តែបើយោងតាមការនិយាយតៗគ្នារបស់បុគ្គលមួយចំនួនដែលធ្លាប់មានការពាក់ព័ន្ធជាមួយពន្ធដារកម្ពុជានៅក្នុងសម័យកាលទសវត្សរ៍១៩៦០ និង១៩៧០ គឺមុនរបបប្រល័យពូជសាសន៍ ប៉ុល ពត បានបញ្ជាក់ថាពន្ធដារកម្ពុជា បានចាប់ផ្ដើមមានកំណើតតាំងពីសម័យអាណានិគមបារាំង គឺមុនកម្ពុជាទទួលបាននូវឯករាជ្យពីអាណានិគមបារាំងក្នុងឆ្នាំ១៩៥៣។ សូមបញ្ជាក់ថាឯកសារ ឬកំណត់ត្រាប្រវត្តិសាស្ត្រមួយចំនួនរបស់កម្ពុជាត្រូវបានកម្ទេចចោល ឬបាត់បង់ក្នុងរបបប៉ុល ពត។

បន្ទាប់ពីថ្ងៃរំដោះ ជាតិមាតុភូមិនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដែលជាថ្ងៃប្រវត្តិសាស្ត្រដ៏ថ្លៃថ្លានៃការរស់រានមានជីវិតឡើងវិញពីរបបប្រល័យពូជសាសន៍ និងជាសម័យកាលដ៏ខ្មៅងងឹតពោរពេញទៅដោយសោកនាដកម្ម ដែលស្ថានភាព និងហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសទាំងមូលត្រូវលិចលង់ ដោយរាប់ទាំងការធ្លាក់ចុះដុនដាបក្រោមកម្រិតសូន្យទៅទៀត ដោយសារការកម្ទេច និងរំលាយចោល ដោយរបបកម្ពុជាប្រជាធិបតេយ្យរបស់ប៉ុល ពត ហើយដែលធ្វើឱ្យប្រជាជនកម្ពុជា និងពិភពលោកទាំងមូលមិនអាចបំភ្លេចបាន។ កម្ពុជានៅពេលនោះ

បានចាប់ផ្ដើមសារជាថ្មីនូវការខិតខំប្រឹងប្រែងកសាង និងស្ដារហេដ្ឋារចនាសម្ព័ន្ធប្រទេសជាតិឡើងវិញ ពីចំណុចក្រោមសូន្យលើគ្រប់វិស័យទាំងអស់ ចាប់ពីវិស័យអប់រំសុខាភិបាល និងសេដ្ឋកិច្ចទាំងមូល។ កត្តាអាទិភាពចម្បងទីមួយរបស់រដ្ឋាភិបាលនៃរដ្ឋកម្ពុជានៅពេលនោះ គឺការខិតខំបង្កើត និងរក្សាសុខសន្តិភាពជូនប្រទេសជាតិ គឺការខិតខំគ្រប់បែបយ៉ាងក្នុងការការពារកុំឱ្យមានការវិលត្រឡប់មកវិញ នូវរបបប្រល័យពូជសាសន៍ ប៉ុល ពត ក្នុងពេលដែលកម្ពុជាកំពុងខិតខំកសាង និងស្ដារប្រទេសជាតិឡើងវិញ។

នាថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៩ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា បានដាក់ចេញនូវសេចក្ដីប្រកាសមួយ ស្ដីពីការបង្កើតរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ក៏បានបង្កើតឡើងវិញ នូវប្រព័ន្ធគ្រប់គ្រងរដ្ឋ ការផ្ដល់សេវាសាធារណៈ និងការស្ដារតំបន់ ឧស្សាហកម្មសំខាន់ៗ សម្រាប់ជំរុញសកម្មភាពសេដ្ឋកិច្ច។

ដើមឆ្នាំ១៩៨០ ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានដាក់ឱ្យដំណើរការនូវការប្រមូលចំណូលថវិការដ្ឋនៅតាមផ្ទះលក់ទំនិញ និងកន្លែងធ្វើអាជីវកម្មធំៗមួយចំនួនតែប៉ុណ្ណោះ ក្រោមរូបភាពជាការធ្វើវិភាគទានដែលជាដែនសមត្ថកិច្ចរបស់អង្គភាពមន្ទីរហិរញ្ញវត្ថុដើម្បីជំរុញវិស័យសេដ្ឋកិច្ចឱ្យកាន់តែមានសកម្មភាពផុសផុលបន្ថែមទៀត។

នៅឆ្នាំ១៩៨១ ក្រុមប្រឹក្សារដ្ឋនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជា បានចេញសេចក្ដីសម្រេចអនុញ្ញាតឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអនុវត្តជាគំរូនូវកិច្ចប្រតិបត្តិការចុះឈ្មោះអាជីវកម្ម ប្រមូលពន្ធអាជីវកម្ម និងពន្ធលើទំនិញនាំចូលចំពោះមូលដ្ឋានមួយចំនួនតាមរយៈលិខិតលេខ ៧៨ ស.រ.ច ចុះ ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ១៩៨១។ ផ្អែកតាមខ្លឹមសារនៃសារាចរលេខ ២៤៩-៨១ កហវ.ពដ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ១៩៨១ ការអនុវត្តន៍ជាគំរូនេះ គឺអនុវត្តតែនៅក្នុងរាជធានីភ្នំពេញ ទីរួមខេត្តកណ្ដាល និងស្រុកពញាឮតែប៉ុណ្ណោះ ហើយប្រមូលពន្ធតែទៅលើមូលដ្ឋានអាជីវកម្មផ្នែកពាណិជ្ជកម្ម ហូបចុក និងបម្រើការងារ ដែលកិច្ចការនេះស្ថិតក្រោមដែនសមត្ថកិច្ចរបស់នាយកដ្ឋានពន្ធដារឧស្សាហាពាណិជ្ជកម្ម។ ក្នុងពេលជាបណ្ដោះអាសន្នការប្រមូលពន្ធលើមូលដ្ឋានអាជីវកម្ម ផ្នែកពាណិជ្ជកម្ម ហូបចុក និងបម្រើការងារ គឺអនុវត្តបានតែចំពោះមូលដ្ឋានមួយចំនួន ដែលមានលក្ខណៈនឹងនរព្រមទាំងមានកម្រិតផលរបរមធ្យមប្រចាំខែ តាមតារាងដែលបានកំណត់ពោល គឺមិនទាន់ធ្វើការប្រមូលពន្ធអាជីវកម្មដល់មូលដ្ឋានទាំងឡាយណា ដែលលក់ដូរអចល័ត ហើយមានផលរបរមធ្យមប្រចាំខែស្ថិតក្រោមកម្រិតដែលតម្រូវឱ្យបង់ពន្ធ និងបណ្ដាមូលដ្ឋានអាជីវកម្មចល័តដែលយកផលិតផល កសិកម្ម ឬសត្វចិញ្ចឹមដោយផ្ទាល់មកលក់នៅទីផ្សារ។ ចំពោះផ្នែកផលិតកម្ម សិប្បកម្មតូចតាចផ្នែក សំណង់ ដឹកជញ្ជូន នេសាទ និងផ្នែកផ្សេងៗទៀតត្រូវបានដាក់ឱ្យបន្តសិក្សាស្រាវជ្រាវដើម្បីរៀបចំ ដាក់អនុវត្តការប្រមូលពន្ធនៅពេលក្រោយ។

នៅចុងឆ្នាំ១៩៨២ ជាជំហានបន្ទាប់ ក្រុមប្រឹក្សារដ្ឋនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានដាក់ខេត្តអនុវត្តឱ្យប្រមូលពន្ធកាន់តែទូលំទូលាយក្នុងក្របខណ្ឌទូទាំងប្រទេសលើកលែងតែខេត្តព្រះវិហារ មណ្ឌលគិរី និងខេត្តរតនគិរី តាមរយៈក្រឹត្យច្បាប់លេខ ១៤ ក្រ.ច ចុះថ្ងៃទី២៧ ខែ វិច្ឆិកា ឆ្នាំ១៩៨២ ។ បន្ទាប់មក ក្រសួងហិរញ្ញវត្ថុ បានដាក់អនុវត្តប្រកាសលេខ ២១៤៩-៨២ កហវ ចុះថ្ងៃ ទី២០ ខែធ្នូ ឆ្នាំ១៩៨២ ស្ដីពីការណែនាំអនុវត្តក្រឹត្យច្បាប់ពន្ធអាជីវកម្មចំពោះមុខ ដែលតម្រូវឱ្យប្រមូលពន្ធចំពោះ មូលដ្ឋានអាជីវកម្មចល័ត និង អចល័ត

ដែលនៅក្នុងផ្នែកពាណិជ្ជកម្មហូបចុក និងបម្រើការងារដែលកំពុងមានសកម្មភាពក្រោមរូបភាពឯកជន ឬសមូហភាព ដូចជា ក្រុមហ៊ុន សមាគម ក្រុមសាមគ្គី សហករណ៍ ក្រុមហ៊ុនចម្រុះរដ្ឋជាដើម។ ចំពោះរបៀបរបបនៃការកំណត់ពន្ធសម្រាប់ការប្រមូលពន្ធនេះ គឺមិនគិតតាមអត្រាទេ ប៉ុន្តែត្រូវគិតតាមផលរបរប្រចាំខែ និងកំណត់ប្រាក់ពន្ធត្រូវបង់តែម្តង មានន័យថា បើផលរបរប្រចាំខែតិច គឺបង់ពន្ធតិចបើផលរបរច្រើនគឺបង់ពន្ធច្រើន។

រហូតដល់ឆ្នាំ១៩៩០ នាយកដ្ឋានពន្ធដារឧស្សាហាពាណិជ្ជបានប្តូរឈ្មោះមកជា នាយកដ្ឋានពន្ធដារ ហើយនៅតាមបណ្តាខេត្ត-រាជធានី ក៏បានប្តូរឈ្មោះពីការិយាល័យពន្ធដារឧស្សាហាពាណិជ្ជទៅជាសាខាពន្ធដារខេត្ត-រាជធានី តាមរយៈអនុក្រឹត្យលេខ២៤ អនុក្រ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៩០ ។ ក្រោយពីការបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងត្រូវបានដាក់អនុវត្ត ដោយកំណត់នូវមូលដ្ឋានសម្រាប់ការប្រមូលពន្ធចាប់ពីឆ្នាំ១៩៩៤ រហូតមក។




នៅក្នុងឆ្នាំ២០០០ នាយកដ្ឋានពន្ធដារត្រូវបានបង្កើតឡើងស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអនុក្រឹត្យលេខ ០៤ អនុក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅឆ្នាំ២០០៨ នាយកដ្ឋានពន្ធដារត្រូវបានដំឡើងទៅជាអគ្គនាយកដ្ឋានពន្ធដារដែលមានភារកិច្ចគ្រប់គ្រងរដ្ឋបាលប្រមូលពន្ធដារក្នុងស្រុក( ពន្ធផ្ទៃក្នុង )បង្កើតគោលនយោបាយពន្ធដារ ក៏ដូចជាធ្វើសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការយកពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការកែសម្រួល និងបង្កើតការិយាល័យថ្មីបន្ថែមមួយចំនួនទៀត ដើម្បីសម្រួលដល់ការងារ ប្រមូលចំណូលពន្ធ តាមរយៈអនុក្រឹត្យលេខ ១៣៤ អនុក្រ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨។

### ៣.១.២ ទស្សនវិស័យ បេសកកម្ម គុណតម្លៃ និងតួនាទី និងភារកិច្ច របស់អគ្គនាយកដ្ឋានពន្ធដារ

- **ទស្សនវិស័យ**

អគ្គនាយកដ្ឋានពន្ធដារ ជាអង្គភាពសាធារណៈដែលត្រូវបានជឿជាក់ គោរពនិងទទួលស្គាល់លើគុណភាព និងជំនាញក្នុងការប្រមូលចំណូលពន្ធដារ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

- **បេសកកម្ម**

អគ្គនាយកដ្ឋានពន្ធដារ ផ្តល់នូវសេវាដែលមានគុណភាព និងពង្រឹងការអនុវត្តន៍ច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារប្រកបដោយភាពសុចរិត និងស្មើភាពចំពោះអ្នកជាប់ពន្ធទាំងអស់ ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការអភិវឌ្ឍន៍និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។

- **គុណតម្លៃ**

អគ្គនាយកដ្ឋានពន្ធដារ បំពេញបេសកកម្ម និងធ្វើប្រតិបត្តិការរបស់ខ្លួនដោយប្រកាន់ខ្ជាប់នូវគុណតម្លៃដូចខាងក្រោម៖

- **ការអនុវត្តន៍៖** អនុវត្តវិធាននៃច្បាប់ គាំទ្រប្រជាពលរដ្ឋដែលប្រព្រឹត្តត្រឹមត្រូវ តាមច្បាប់ និងតឹងរឹងចំពោះជនដែលមិនអនុលោមតាមច្បាប់
- **វិជ្ជាជីវៈ** ៖ ប្តេជ្ញាចិត្តប្រើវិជ្ជាជីវៈនិងជំនាញដើម្បីផ្តល់នូវសេវាដែលមានភាពសាមញ្ញនិងងាយស្រួល
- **ស័ក្តិសិទ្ធិភាព៖** ប្រើប្រាស់ធនធានឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព
- **សុចរិតភាព ៖** ផ្តល់សេវាឱ្យប្រជាពលរដ្ឋដោយស្មើភាព និងតម្លាភាព
- **គារវភាព៖** ផ្តល់សេវាឱ្យប្រជាពលរដ្ឋប្រកបដោយភាពថ្លៃថ្នូរ និងការគោរព
- **ភាពបត់បែន៖** ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន។

**➢ តួនាទី និងភារកិច្ច**

អគ្គនាយកដ្ឋានពន្ធដារ មានភារកិច្ចដូចតទៅ៖

- ចូលរួមរៀបចំគោលនយោបាយសារពើពន្ធស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងបរិបទអន្តរជាតិ
- រៀបចំសេចក្តីព្រាងច្បាប់ លិខិតបទដ្ឋានស្តីពីពន្ធដារ កំណត់បញ្ជីឯកសារ និងលិខិតយុត្តិការនានាសម្រាប់ការគ្រប់គ្រងប្រមូលពន្ធ
- ប្រមូលប្រាក់ពន្ធគ្រប់ប្រភេទបង់ចូលថវិកាជាតិ
- ចុះបញ្ជីអ្នកជាប់ពន្ធ
- ផ្តល់ការអប់រំដល់អ្នកជាប់ពន្ធអំពីកាតព្វកិច្ចសារពើពន្ធ ផ្តល់សេវា និងព័ត៌មានដល់អ្នកជាប់ពន្ធ ដើម្បីបង់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- កសាងកម្មវិធីសវនកម្ម និងធ្វើសវនកម្មលើអ្នកជាប់ពន្ធ
- កំណត់មូលដ្ឋានគិតពន្ធ ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់យឺតយ៉ាវ ចំពោះអ្នកជាប់ពន្ធ ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- ស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ
- អនុវត្តវិធានការទាមទារនិងទោសទណ្ឌតាមច្បាប់ ចំពោះអ្នកជាប់ពន្ធដែលប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ
- ធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ
- រៀបចំ និងអនុវត្តកិច្ចសហប្រតិបត្តិការជាតិ និងអន្តរជាតិនានាទាក់ទិននឹងពន្ធដារ
- រៀបចំផែនការជ្រើសរើស បណ្តុះបណ្តាល និងកសាងសមត្ថភាពធនធានមនុស្សទាក់ទិននឹងពន្ធដារ
- ចូលរួមរៀបចំគម្រោងថវិកាជាតិ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ។

### ៣.១.៣ និមិត្តសញ្ញារបស់អគ្គនាយកដ្ឋានពន្ធដារ

## ៣.១.៤ រចនាសម្ព័ន្ធគ្រប់គ្រង (តួនាទី និងភារកិច្ច)អគ្គនាយកដ្ឋានពន្ធដារ



អគ្គនាយកដ្ឋានពន្ធដារ ជាអង្គភាពមួយស្ថិតក្រោមចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដែលមានអគ្គនាយក០១រូប ជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។ បច្ចុប្បន្ននេះ អគ្គនាយកដ្ឋានពន្ធដារមានថ្នាក់ដឹកនាំជាអគ្គនាយករងចំនួន០៨រូប ជាជំនួយការអគ្គនាយក តាមលិខិតបង្គាប់ការបែងចែកភារកិច្ច និងការទទួលខុសត្រូវ។

- ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ
- ឯកឧត្តម **អ៊ុំ សីហា** អគ្គនាយករង
- ឯកឧត្តម **ជាប ជារុជ** អគ្គនាយករង
- ឯកឧត្តម **ម៉ិញ បានកុសល** អគ្គនាយករង
- ឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករង
- ឯកឧត្តម **ហេង សុខណាង** អគ្គនាយករង
- លោកជំទាវ **ប៊ុន នារី** អគ្គនាយករង
- ឯកឧត្តម **រ័ត្ន មុនី** អគ្គនាយករង
- លោក **លីម ដឹលុច** អគ្គនាយករង
- ឯកឧត្តម **លីម ហ៊ុយជីវ** អគ្គនាយករង

➢ **នាយកដ្ឋានថ្នាក់កណ្តាល**

នាយកដ្ឋានថ្នាក់កណ្តាលនីមួយៗ មានការិយាល័យចំណុះមួយចំនួន គឺស្ថិតក្រោមការគ្រប់គ្រងដោយប្រធាននាយកដ្ឋានចំនួន០១រូបនិងអមដោយអនុប្រធានចំនួន០៤រូប ជាជំនួយការ។ ការិយាល័យនីមួយៗ នៃនាយកដ្ឋានថ្នាក់កណ្តាល ស្ថិតក្រោមការគ្រប់គ្រងដោយប្រធាន០១រូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ។ នាយកដ្ឋានថ្នាក់កណ្តាលចំនួន១១ ស្ថិតនៅទីស្នាក់ការកណ្តាល នៃអគ្គនាយកដ្ឋានពន្ធដារមានដូចខាងក្រោម៖

- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
- នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
- នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
- នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
- នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
- នាយកដ្ឋានសវនកម្មសហគ្រាស
- សាលាជាតិពន្ធដារ
- ទីចាត់ការពន្ធដាររាជធានីភ្នំពេញ

- **សាខាពន្ធដារខណ្ឌនៅរាជធានីភ្នំពេញ**

នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនីមួយៗ អគ្គនាយកដ្ឋានពន្ធដារ មានសាខាពន្ធដារខេត្ត-ខណ្ឌ ជាសេនាធិការសម្រាប់ការផ្តល់សេវា និងការប្រមូលចំណូលពន្ធ។ សាខាពន្ធដារខណ្ឌនីមួយៗ ដែលមានការិយាល័យចំណុះចំនួន ០៥នៅតាមអគារអង្គភាពពន្ធដារក្នុងខណ្ឌចំនួន ០៧ នៃ រាជធានីភ្នំពេញ គឺស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានសាខាខណ្ឌចំនួន ០១រូប មានឋានៈស្មើអនុប្រធាននាយកដ្ឋានថ្នាក់កណ្តាល និងអមដោយអនុប្រធានចំនួន ០៤រូប។ សាខាពន្ធដារខណ្ឌចំនួន ០៩ ស្ថិតនៅតាមខណ្ឌនៃរាជធានីភ្នំពេញ មានដូចខាងក្រោម៖

- សាខាពន្ធដារខណ្ឌ ឫស្សីកែវ
- សាខាពន្ធដារខណ្ឌ ដូនពេញ
- សាខាពន្ធដារខណ្ឌ ៧មករា
- សាខាពន្ធដារខណ្ឌ មានជ័យ
- សាខាពន្ធដារខណ្ឌ ចំការមន
- សាខាពន្ធដារខណ្ឌ ទួលគោក
- សាខាពន្ធដារខណ្ឌ ដង្កោ
- សាខាពន្ធដារខណ្ឌ សែនសុខ
- សាខាពន្ធដារខណ្ឌ ពោធិសែនជ័យ

- **សាខាពន្ធដារខណ្ឌ-ខេត្តសាខាពន្ធដារខេត្ត**

សាខាពន្ធដារខេត្តនីមួយៗ ដែលមានការិយាល័យចំណុះចំនួន០៥ នៅតាមអគារអង្គភាពពន្ធដារក្នុងខេត្តចំនួន២៤ គឺស្ថិតក្រោមការគ្រប់គ្រងរបស់ប្រធានសាខាខេត្តចំនួន០១រូប មានឋានៈស្មើ អនុប្រធាននាយកដ្ឋានថ្នាក់កណ្តាល និងអមដោយអនុប្រធានចំនួន០៤រូប។ ដោយឡែកសាខាពន្ធដារខេត្តនីមួយៗ មានការិយាល័យពន្ធដារស្រុក-ក្រុងដែលជាការិយាល័យចំណុះ មានទីតាំង ភូមិសាស្ត្រនៅក្រៅសាខាពន្ធដារខេត្តសម្រាប់គ្រប់គ្រងប្រមូលពន្ធ នៅក្នុងភូមិសាស្ត្រស្រុក-ក្រុងនីមួយៗ តាមការជាក់ស្តែង។ នៅតាមស្រុក-ក្រុង មានការិយាល័យពន្ធដារស្រុក-ក្រុងដែលមានថ្នាក់ស្មើនឹងការិយាល័យនៃសាខាពន្ធដារខេត្ត-ខណ្ឌ និងគ្រប់គ្រងដោយប្រធាន ០១រូប អមដោយអនុប្រធានមួយចំនួនជាជំនួយការ។ សាខាពន្ធដារខេត្តចំនួន ២៤ ស្ថិតនៅតាមបណ្តាខេត្ត មានដូចខាងក្រោម៖

- សាខាពន្ធដារខេត្ត កណ្តាល
- សាខាពន្ធដារខេត្ត កំពង់ចាម
- សាខាពន្ធដារខេត្ត បាត់ដំបង
- សាខាពន្ធដារខេត្ត ព្រៃវែង
- សាខាពន្ធដារខេត្ត សៀមរាប
- សាខាពន្ធដារខេត្ត កំពង់ធំ
- សាខាពន្ធដារខេត្ត តាកែវ

- សាខាពន្ធដារខេត្ត ស្វាយរៀង
- សាខាពន្ធដារខេត្ត ពោធិ៍សាត់
- សាខាពន្ធដារខេត្ត កំពង់ឆ្នាំង
- សាខាពន្ធដារខេត្ត កំពង់ស្ពឺ
- សាខាពន្ធដារខេត្ត កំពត
- សាខាពន្ធដារខេត្ត ព្រះសីហនុ
- សាខាពន្ធដារខេត្ត កោះកុង
- សាខាពន្ធដារខេត្ត ព្រះវិហារ
- សាខាពន្ធដារខេត្ត ក្រចេះ
- សាខាពន្ធដារខេត្ត រតនគិរី
- សាខាពន្ធដារខេត្ត មណ្ឌលគិរី
- សាខាពន្ធដារខេត្ត បន្ទាយមានជ័យ
- សាខាពន្ធដារខេត្ត ស្ទឹងត្រែង
- សាខាពន្ធដារខេត្ត កែប
- សាខាពន្ធដារខេត្ត ប៉ៃលិន
- សាខាពន្ធដារខេត្ត ឧត្តរមានជ័យ
- សាខាពន្ធដារខេត្ត ត្បូងឃ្មុំ

## ៣.២ ភាតព្វកិច្ច និងសិទ្ធរបស់អ្នកជាប់ពន្ធ

### ៣.២.១ កាតព្វកិច្ចអ្នកជាប់ពន្ធ

ការបង់ពន្ធជូនរដ្ឋ ជាកាតព្វកិច្ចរបស់ពលរដ្ឋគ្រប់រូប។ ប៉ុន្តែ ពន្ធដារមានច្រើនប្រភេទទាំងពន្ធលើបុគ្គល ក៏ដូចជាពន្ធលើគ្រឹះស្ថានផ្សេងៗ។ ប្រសិនបើ អ្នកទាំងអស់គ្នាមានគម្រោងបើកអាជីវកម្មខ្លួនឯងនៅថ្ងៃអនាគត អ្នកទាំងអស់គ្នាត្រូវត្រៀមខ្លួន និងស្វែងយល់ពីកាតព្វកិច្ចពន្ធដែលត្រូវបំពេញសម្រាប់អាជីវកម្ម។



អ្នកជាប់ពន្ធមានកាតព្វកិច្ចដូចខាងក្រោមៈ

**១. ចុះឈ្មោះក្នុងបញ្ជីរបស់រដ្ឋបាលសារពើពន្ធ៖** បុគ្គលទាំងឡាយត្រូវចុះបញ្ជី នៅរដ្ឋបាលសារពើពន្ធ ក្នុងកំឡុង ១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ច ។

**២. ដាក់លិខិតប្រកាសសារពើពន្ធ និងផ្តល់ព័ត៌មានតាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីពន្ធដារ៖** អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលបានកំណត់។ លិខិតប្រកាសសារពើពន្ធ ត្រូវចុះហត្ថលេខាដោយអ្នកជាប់ពន្ធ ឬតំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ។ អ្នកវិនិយោគទាំងអស់ត្រូវដាក់លិខិត ប្រកាសសារពើពន្ធប្រចាំខែសម្រាប់ខែនីមួយៗ និងលិខិតប្រកាសសារពើពន្ធ ប្រចាំឆ្នាំសម្រាប់ឆ្នាំសារពើពន្ធនោះ និងបង់ពន្ធអាករទាំងអស់ទៅតាមបទប្បញ្ញត្តិនៃពន្ធនីមួយៗ។ អ្នកវិនិយោគទាំងអស់ ត្រូវភ្ជាប់នូវវិញ្ញាបនបត្ររបស់ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា បញ្ជាក់ពីការគោរពប្រតិបត្តិជាមួយលិខិតប្រកាសសារពើពន្ធប្រចាំឆ្នាំ សម្រាប់ឆ្នាំសារពើពន្ធនោះ ។

អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសមាន កាតព្វកិច្ចរៀបចំបញ្ជីកាគណនេយ្យ (បិទបញ្ជីគណនេយ្យ) របស់ខ្លួន និងរៀបចំ និងដាក់លិខិតប្រកាសសារពើពន្ធតាមគំរូទម្រង់លិខិតប្រកាសសារពើពន្ធ ។

រដ្ឋបាលសារពើពន្ធមានសិទ្ធិធ្វើការកំណត់ពន្ធជា ឯកតោភាគី ចំពោះសហគ្រាសណា ដែលមិនបានរៀបចំ និងដាក់លិខិតប្រកាសសារពើពន្ធ មិនបានកាន់កាប់ និងរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីកាគណនេយ្យ ឬឯកសារផ្សេងៗ តាមបទប្បញ្ញត្តិស្តីពីពន្ធដារ ។

**៣. បង់ពន្ធតាមកាលបរិច្ឆេទកំណត់៖** ការបង់ពន្ធត្រូវបានកំណត់ដូចតទៅៈ

- ប្រាក់ពន្ធត្រូវដល់កំណត់ និងត្រូវបង់នៅក្នុងរយៈពេលដែលបទប្បញ្ញត្តិស្តីពីពន្ធដារ បានតម្រូវឱ្យធ្វើការដាក់លិខិតប្រកាសសារពើពន្ធ៖

ក-អាករលើតម្លៃបន្ថែម «អតប» យ៉ាងយឺតបំផុតនៅថ្ងៃទី២០ នៃខែបន្ទាប់។

ខ-ពន្ធលើប្រាក់ចំណេញ៖

+ចំពោះសហគ្រាសអនុវត្តឆ្នាំជាប់ពន្ធតាមឆ្នាំប្រតិទិន៖ យ៉ាងយឺតបំផុតត្រឹម ថ្ងៃទី៣១ ខែមីនា នៃឆ្នាំបន្ទាប់ ។

+ចំពោះសហគ្រាស ដែលស្នើសុំប្តូរឆ្នាំជាប់ពន្ធថ្មី៖ ក្នុងរយៈពេល ៣ខែបន្ទាប់ពីដំណាច់ការិយបរិច្ឆេទអន្តរកាល និងក្នុងរយៈពេល ៣ខែក្រោយ ដំណាច់ឆ្នាំជាប់ពន្ធថ្មី។

គ-ពន្ធអាករដទៃទៀត ដូចជាពន្ធកាត់ទុកទូទៅ ពន្ធលើប្រាក់បៀវត្ស អាករបំភ្លឺសាធារណៈ អាករពិសេស អាករស្នាក់នៅ៖ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ នៃខែបន្ទាប់។ ពន្ធអាករក្រៅពីនេះ ត្រូវដល់កំណត់ និងត្រូវបង់នៅក្នុងរយៈពេលកំណត់ដោយរដ្ឋបាលសារពើពន្ធ ។

- បំណុលសារពើពន្ធត្រូវដល់កំណត់ និងត្រូវបង់ ក្នុងរយៈពេល៣០ថ្ងៃ ក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ។
- ប្រាក់ពន្ធត្រូវដល់កំណត់ និងត្រូវបង់ក្នុងរយៈពេល៣ថ្ងៃ ក្រោយពីការប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ «បើសិនជាមានមូលដ្ឋានបញ្ជាក់ថា ការប្រមូលពន្ធអាចមានឧបសគ្គ រដ្ឋបាលសារពើពន្ធអាចធ្វើការកំណត់ពន្ធលើអ្នកជាប់ពន្ធនៅពេលណាមួយក៏បាន»។

**៤. កាន់កាប់ថែរក្សា និងត្រូវបង្ហាញបញ្ជីលិខិតយុត្តិការ និងឯកសារផ្សេងៗដល់រដ្ឋបាលសារពើពន្ធ៖** អ្នកជាប់ពន្ធត្រូវកាន់កាប់កត់ត្រា និងរក្សាទុកបញ្ជីលិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗដូចដែលបទប្បញ្ញត្តិស្តីពីពន្ធដារបានកំណត់ និងត្រូវដាក់បញ្ជីឯកសារទាំងនោះតាមការតម្រូវជូនរដ្ឋបាលសារពើពន្ធ ដើម្បីពិនិត្យ។

បុគ្គលដែលត្រូវកាន់កាប់កត់ត្រា ឬរក្សាទុកបញ្ជីឯកសារនានា ឬទិនានុប្បវត្តិ ដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវរក្សាទុកបញ្ជីឯកសារទាំងនោះក្នុងរយៈពេល១០ ឆ្នាំគិតពីដំណាច់ឆ្នាំជាប់ពន្ធ។

**៥. បង្ហាញខ្លួនចំពោះរដ្ឋបាលសារពើពន្ធតាមកាលបរិច្ឆេទដែលមានចុះនៅក្នុងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធ៖** ដូចមានចែងនៅក្នុងមាត្រា៩៩ នៃចសព ក្នុងគោលដៅកំណត់ប្រាក់ពន្ធត្រូវបង់របស់បុគ្គលណាម្នាក់ ឬដើម្បីប្រមូលពន្ធរដ្ឋបាលសារពើពន្ធអាចធ្វើលិខិតជូនដំណឹងដល់អ្នកជាប់ពន្ធ ឬតតីយជនឱ្យផ្តល់ព័ត៌មានដែលទាក់ទិននឹងអ្នកជាប់ពន្ធដែលចែងក្នុងលិខិតជូនដំណឹង ដូចជាព័ត៌មានស្តីពីអ្នកផ្គត់ផ្គង់ អតិថិជន ឬគណនីនៅធនាគារ។ បង្ហាញខ្លួនទៅតាមពេលវេលាទីកន្លែងដែលមានបញ្ជាក់នៅក្នុងលិខិតជូនដំណឹង ដើម្បីផ្តល់ព័ត៌មាន និងដើម្បីបង្ហាញ ឬផ្តល់ឯកសារ ឬទិន្នន័យ ដែលបុគ្គលនោះគ្រប់គ្រង ដែលមានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុងលិខិតជូនដំណឹង។

**៦.បង់ប្រាក់ពន្ធ ប្រាក់ពន្ធបន្ថែម និងការប្រាក់ផ្សេងៗ៖** រដ្ឋបាលសារពើពន្ធបានកំណត់ទៅតាមកាលបរិច្ឆេទ ដូចមាននៅក្នុងបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលរដ្ឋបាលសារពើពន្ធបានជូនដំណឹងជាលាយលក្ខណ៍អក្សរ។

**៧.ត្រូវមានភាពស្មោះត្រង់ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ៖**

- ផ្តល់ព័ត៌មានត្រឹមត្រូវក្នុងលិខិតប្រកាសសារពើពន្ធ។
- ផ្តល់ព័ត៌មាន និងស្ថានភាពទាំងស្រុងរបស់សហគ្រាសនៅ ពេលសុំយោបល់ពីរដ្ឋបាលសារពើពន្ធ។
- ឆ្លើយសំណួររបស់រដ្ឋបាលសារពើពន្ធ ដោយពេញលេញត្រឹមត្រូវ និងស្មោះត្រង់។

**៨. ត្រូវមានកិច្ចសហប្រតិបត្តិការជាមួយរដ្ឋបាលសារពើពន្ធក្នុងការបំពេញកាតព្វកិច្ច។**

**៣.២.២ សិទ្ធរបស់អ្នកជាប់ពន្ធ**

អ្នកជាប់ពន្ធមានសិទ្ធិដូចខាងក្រោម៖

- ទទួលបានការរក្សាទុក ជាសម្ងាត់នូវរាល់ព័ត៌មាន ដែលអ្នកជាប់ពន្ធបានផ្តល់ជូនរដ្ឋបាលសារពើពន្ធ។
- ទទួលបានការផ្តល់សេវាប្រកបដោយវិជ្ជាជីវៈ និងមានការជួយណែនាំឱ្យបានយល់អំពីកិច្ចដំណើរការ នៃប្រព័ន្ធពន្ធដារ នីតិវិធីសារពើពន្ធ និងការអនុវត្តន៍កាតព្វកិច្ចសារពើពន្ធ។
- ទទួលបានការពន្យល់រាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ ចំពោះកិច្ចការសារពើពន្ធ។
- ប្តឹងតវ៉ាចំពោះរាល់សេចក្តីសម្រេចរបស់រដ្ឋបាលសារពើពន្ធ។
- បង់ពន្ធមិនឱ្យលើសពីបទប្បញ្ញត្តិស្តីពីពន្ធដារកំណត់។

- មានការទទួលស្គាល់តំណាងស្របច្បាប់របស់អ្នកជាប់ពន្ធ តាមការជ្រើសរើស ដើម្បីផ្តល់យោបល់អំពីកិច្ចការសារពើពន្ធ។
- ទទួលបានការអនុវត្តដោយមានតម្លាភាព និងមិនលម្អៀងពីសំណាក់រដ្ឋបាលសារពើពន្ធ។
- ទទួលបានការទទួលស្គាល់អំពីភាពស្មោះត្រង់ក្នុងការអនុវត្តន៍កាតព្វកិច្ចសារពើពន្ធ។

### ៣.២.៣ បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

#### ក.ការគេចវេះពន្ធ

យើងដឹងហើយថាការបង់ពន្ធ គឺជាកាតព្វកិច្ចមួយដ៏ចាំបាច់របស់អ្នកជាប់ពន្ធ។ យ៉ាងណាមិញអ្នកជាប់ពន្ធ ច្រើនតែចង់កាត់បន្ថយពន្ធដែលពួកគេត្រូវបង់ជូនរដ្ឋហើយ ដោយតាមរយៈនីតិវិធី ឬវិធីស្របច្បាប់ផ្សេងៗ ឬគេហៅថា ការជៀសពន្ធ។ តែបើមានការប្រព្រឹត្តនូវមធ្យោបាយខុសឆ្គង ដើម្បីកាត់បន្ថយប្រាក់ ពន្ធនោះវានឹងក្លាយទៅជាការគេចវេះពន្ធ ហើយវាជាអំពើខុសច្បាប់ បើយោង ទៅតាមច្បាប់ស្តីពីសារពើពន្ធ។




ការគេចវេះពន្ធ (មាត្រា ២២៦នៃច្បាប់ស្តីពីសារពើពន្ធ) គឺជាអំពើណាមួយ ដែលបានប្រព្រឹត្តឡើងដោយចេតនា និងរៀបចំទុកជាមុន ដែលនាំឱ្យបាត់ប្រាក់ពន្ធដែលបទប្បញ្ញត្តិស្តីពីពន្ធដារតម្រូវឱ្យបង់។

ត្រូវបានចាត់ទុកថាជាការគេចវេះពន្ធផងដែរចំពោះករណីណាមួយដូចខាងក្រោម៖

- ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤ នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវ បានប្រព្រឹត្តឡើងពីរលើកដាច់ពីគ្នាក្នុងរយៈពេល៣(បី)ឆ្នាំនៃឆ្នាំប្រតិទិន។
- ការធ្វេសប្រហែសធ្ងន់ធ្ងរដូចមានចែងក្នុងមាត្រា២២៤នៃច្បាប់ស្តីពីសារពើពន្ធដែលត្រូវបានប្រព្រឹត្តឡើងបីលើកឬច្រើនជាងនេះដាច់ពីគ្នាក្នុងរយៈពេល១០(ដប់)ឆ្នាំនៃឆ្នាំប្រតិទិន។

#### ខ.ការធ្វេសប្រហែស

កាតព្វកិច្ចបង់ពន្ធ ជាកិច្ចការមួយដែលប្រជាពលរដ្ឋត្រូវតែធ្វើតាមសេចក្តីសម្រេចរបស់រដ្ឋ ដើម្បីជួយសម្រួលដល់កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុរបស់រដ្ឋ។ ដូច្នេះ កាតព្វកិច្ចបង់ពន្ធចាំបាច់ណាស់ ត្រូវតែធ្វើ ប្រសិនបើ ភ្លេចប្រហែលជាអាចនឹងមានបញ្ហាកាន់តែធ្ងន់ធ្ងរ សម្រាប់អ្នកនៅពេលអនាគតដោយសារតែពន្ធនោះវាកាន់តែច្រើនពីមួយឆ្នាំទៅមួយឆ្នាំ។ ការមិនបង់ពន្ធ អាចប្រឈមមុខនឹងការពិន័យតាមផ្លូវច្បាប់ថែមទៀត។ ចំពោះបុគ្គលដែលមានការធ្វេសប្រហែស ត្រូវរងនូវប្រាក់ពន្ធបន្ថែមដែលស្មើនឹង១០ភាគរយ នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះ បូកបន្ថែមការប្រាក់២ភាគរយនៃចំនួនប្រាក់ពន្ធ ដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលចំនួនប្រាក់ពន្ធខ្វះមិនទាន់បានបង់។ ចំពោះបុគ្គល ដែលមានការធ្វេសប្រហែសធ្ងន់ធ្ងរ ត្រូវរងប្រាក់ពន្ធបន្ថែមដែលស្មើនឹង ២៥ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះបូកបន្ថែមការប្រាក់២ ភាគរយនៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសម្រាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

### គ. អំពើរាំងស្ទះ និងការអនុវត្តន៍បទប្បញ្ញត្តិស្តីពីសារពើពន្ធ

យោងតាមមាត្រា២២៥ នៃច្បាប់សារពើពន្ធស្តីពីអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវបានចាត់ទុកជាអំពើ ដែលប្រព្រឹត្តផ្ទុយពីការកំណត់របស់ច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធផ្សេងទៀតដូចជា៖

១. ការមិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ស្របតាមការកំណត់របស់ច្បាប់នេះ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធផ្សេងទៀត។

២. ការមិនបានជូនដំណឹងទៅរដ្ឋបាលសារពើពន្ធអំពីការផ្លាស់ប្តូរព័ត៌មាននៃការចុះបញ្ជី។

៣. ការមិនបានដាក់លិខិតប្រកាសសារពើពន្ធ។

៤. ការមិនបានប្រើប្រាស់ប្រព័ន្ធកត់ត្រាដែលកំណត់ដោយរដ្ឋបាលសារពើពន្ធ។

៥. ការមិនបានចេញវិក្កយបត្រ។

៦. ការមិនផ្តល់ព័ត៌មាន ឬមិនបញ្ជូនរបាយការណ៍តាមការស្នើសុំ។

៧. ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធធ្វើការពិនិត្យបញ្ជីកាគណនេយ្យឬឯកសារផ្សេងៗ។

៨. ការមិនបានរក្សាបញ្ជីកាគណនេយ្យនិងឯកសារផ្សេងទៀត។

៩. ការព្យាយាមរារាំងការកំណត់ និងការប្រមូលពន្ធ។

១០. ការកសាង ឬផ្តល់នូវកំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានក្លែងបន្លំ។

១១. ការលាក់ទុក ឬបំផ្លាញចោលដោយចេតនានូវបញ្ជីកាគណនេយ្យ កំណត់ត្រា ឯកសារ របាយការណ៍ ឬព័ត៌មានផ្សេងៗ។

១២. ការចេញវិក្កយបត្រក្លែងបន្លំ។

១៣. ការមិនអនុញ្ញាតឱ្យរដ្ឋបាលសារពើពន្ធចូលគ្រឹះស្ថានអាជីវកម្មដើម្បីកំណត់និងប្រមូលពន្ធ។

## ៣.៣ នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធ

អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារ ត្រូវបានធ្វើការគណនាប្រាក់ពន្ធ ដាក់លិខិតប្រកាសសារពើពន្ធ និងបង់ប្រាក់ពន្ធដោយខ្លួនឯងឱ្យបានត្រឹមត្រូវតាមច្បាប់ស្តីពីសារពើពន្ធ។ ដើម្បីបញ្ជាក់ថាការប្រកាសពន្ធរបស់អ្នកជាប់ពន្ធមានភាពត្រឹមត្រូវ និងដើម្បីពង្រឹងអនុលោមភាពសារពើពន្ធ រដ្ឋបាលសារពើពន្ធមានអំណាចនិងកាតព្វកិច្ច ក្នុងការពិនិត្យវិភាគ ផ្ទៀងផ្ទាត់ និងកំណត់ពន្ធឡើងវិញអនុលោមតាមមាត្រា១៩៤ មាត្រា២០៩ និងមាត្រា២១០ នៃច្បាប់ស្តីពីសារពើពន្ធ។

ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារគឺជាការស៊ើបអង្កេត និងស្រាវជ្រាវកម្រិត ឯកទេសស៊ីជម្រៅ ដើម្បីស្វែងរកឬសគល់ និងភ័ស្តុតាងនៃបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពី ពន្ធដារឱ្យបានច្បាស់លាស់ សម្រាប់ជាមូលដ្ឋានក្នុងការទាមទារមកវិញ នូវប្រាក់ពន្ធដែលបាត់បង់រួមទាំងពន្ធបន្ថែម និងការប្រាក់ និងកំណត់អត្តិភាពនៃបទល្មើស ដើម្បីប្តឹងចោទប្រកាន់ព្រមទាំងតម្រូវឱ្យមានការដាក់ទោសចំពោះបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។

អ្នកជាប់ពន្ធ ត្រូវទទួលរងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ គឺអាស្រ័យតាមហានិភ័យ និងភ័ស្តុតាងច្បាស់លាស់ដែលត្រូវបានរកឃើញ។

**៣.៣.១ មុនពេលបើកការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ**

តាមរយៈនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ ពន្ធដារធ្វើការប្រមូលព័ត៌មាន ពីបណ្តាប្រភពពាក់ព័ន្ធនានា ដើម្បីពិនិត្យផ្ទៀងផ្ទាត់ និងវិភាគរកកត្តាហានិភ័យទាំងឡាយ ដែលជាផ្នែកមួយឬទាំងស្រុងនៃការបំពាន ឬការគំរាមកំហែងណាមួយចំពោះប្រព័ន្ធពន្ធដារ។

បែបបទ និងនីតិវិធីនៃការកសាងសំណុំរឿងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវធ្វើឡើងតាមជំហានដូចខាងក្រោម៖

ក. ប្រមូលព័ត៌មានពីប្រភពទាំងឡាយដែលទាក់ទិននឹងករណីសង្ស័យ ឬភ័ស្តុតាងពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារបន្ថែមពីលើព័ត៌មានដែលមានស្រាប់ ដែលក្នុងនោះរួមមានទាំងការប្រមូលព័ត៌មានពីប្រព័ន្ធគ្រប់គ្រងទិន្នន័យអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ។

ខ. ពិនិត្យ វិភាគ ផ្ទៀងផ្ទាត់ និងវាយតម្លៃគ្រប់ជ្រុងជ្រោយ ចំពោះព័ត៌មានដែលប្រមូលបាន ពីប្រភពពាក់ព័ន្ធទាំងឡាយ ដូចមានលើកឡើងក្នុងចំណុច «ក» ខាងលើ ដើម្បីកំណត់ សូចនាករនៃការក្លែងបន្លំ ឬភ័ស្តុតាងបញ្ជាក់ឱ្យបានច្បាស់ថាជាបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ។

គ. បន្ទាប់ពីពិនិត្យឃើញថា ពិតជាមានសូចនាករ ឬតម្រុយច្បាស់លាស់នៃការក្លែងបន្លំ ឬភ័ស្តុតាងបញ្ជាក់ពីបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារប្រាកដមែននោះ អង្គភាពដែលមានមុខងារ និងភារកិច្ចធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារនឹងរៀបចំសំណុំឯកសារ ដើម្បីស្នើសុំកសាងសំណុំរឿងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ។

**៣.៣.២ អំឡុងពេលធ្វើការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ**

ក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ រដ្ឋបាលសារពើពន្ធមានសិទ្ធិក្នុងការចុះឆែកឆេរទីតាំងណាមួយ តាមរយៈដីកាអនុញ្ញាតឱ្យឆែកឆេរ និងមានកិច្ចសហការពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្ថាប័នអនុវត្តន៍ច្បាប់ពាក់ព័ន្ធ ក្នុងការអនុវត្តន៍ដីកាអនុញ្ញាតឱ្យឆែកឆេរ និងចៀសវាងការបំបាត់ភ័ស្តុតាង ដូចមានចែងក្នុងមាត្រា១១៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ យោងតាមមាត្រា ២៣០ នៃច្បាប់ស្តីពីសារពើពន្ធ នៅពេលចូលទៅក្នុងគ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងដែលត្រូវបានចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្ម មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិ ស្តីពីពន្ធដារមានអំណាចក្នុងការស៊ើបអង្កេតដូចខាងក្រោម៖

១. ចូលទៅក្នុងគ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងដែលត្រូវចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្មដើម្បីពិនិត្យបញ្ជីកាគណនេយ្យ លិខិតប្រកាសសារពើពន្ធគ្រប់ប្រភេទ និងឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីកំណត់ពន្ធ។ ការចូលគ្រឹះស្ថានអាជីវកម្ម ដូចមានចែងក្នុងកថាខណ្ឌនេះ ត្រូវធ្វើឡើងក្នុងម៉ោងអាជីវកម្ម ឬនៅគ្រប់ពេលវេលា ដោយអនុវត្តតាមដីការបស់ស្ថាប័នអយ្យការ ឬស្ថាប័នតុលាការដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌជាធរមាន។

២. នៅពេលដែលបានចូលដោយស្របច្បាប់ទៅក្នុងគ្រឹះស្ថានអាជីវកម្ម ឬទីកន្លែងដែលត្រូវចាត់ទុកថាជាគ្រឹះស្ថានអាជីវកម្ម ដូចដែលមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារមានសិទ្ធិ៖

- ធ្វើសម្រង់ ឬចម្លងឯកសារនានា រួមទាំងឯកសារអេឡិចត្រូនិកដែលស្ថិតនៅក្នុងកន្លែងនោះ។
- ចាប់យកឯកសារនានា ឬវត្ថុតាងដទៃទៀតដែលអាចក្លាយជាព័ត៌មាន ឬភ័ស្តុតាងសម្រាប់កំណត់ប្រាក់ពន្ធ ដែលត្រូវបង់របស់បុគ្គលណាម្នាក់ ដោយត្រូវធ្វើកំណត់ហេតុស្តីពីការចាប់យក។
- ដាក់ឧបករណ៍សម្រាប់ត្រួតពិនិត្យផ្សេងៗ ឬបោះត្រាបិទសម្គាល់ ឃាត់ទុកទំនិញ ប្រសិនបើមានជាប់ទាក់ទិនដល់ការអនុវត្តន៍ពន្ធណាមួយ។
- ធ្វើសារពើភណ្ឌទ្រព្យសកម្មវត្ថុធាតុដើម ផលិតផលកំពុងផលិត ផលិតផលសម្រេច និងស្តុកសន្និធិដទៃទៀត។
- ចាប់យក ឃាត់ទុក ឬឃុំគ្រងទ្រព្យសម្បត្តិអ្នកជាប់ពន្ធដើម្បីជានាបំណុលពន្ធ។
- ឃាត់ខ្លួនអ្នកជាប់ពន្ធ ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារដោយអនុវត្តស្រប តាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៣.ក្នុងគ្រប់ករណីទាំងអស់ នៅពេលមានការរកឃើញបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ នៅក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេត របស់មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ ប្រតិបត្តិការទាក់ទិននឹងការប្រមូលភ័ស្តុតាង ការធ្វើកំណត់ហេតុ និងការអនុវត្តន៍រាល់កិច្ចនីតិវិធីព្រហ្មទណ្ឌចាំបាច់ដទៃទៀត ដោយរួមទាំងការឃាត់ខ្លួនជនសង្ស័យផងត្រូវធ្វើឡើង ដោយមន្ត្រីពន្ធដារដែលមាននីតិសម្បទា ជាមន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ ហើយត្រូវអនុវត្តស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

៤. អាចតម្រូវឱ្យស្ថាប័នធនាគារ ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ផ្តល់ព័ត៌មានអំពីគណនីរបស់អ្នកជាប់ពន្ធ ឬបុគ្គលពាក់ព័ន្ធនៅធនាគារ ឬឃាត់ទុកគណនីរបស់អ្នកជាប់ពន្ធ ឬបុគ្គលពាក់ព័ន្ធនោះ ក្នុងករណីមានភ័ស្តុតាងបញ្ជាក់ថាបានប្រព្រឹត្តអំពើគេចវេះពន្ធ។

នៅពេលចុះឆែកឆេរដល់ទីតាំង មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ត្រូវចងក្រងភ័ស្តុតាង កំណត់អត្តិភាពនៃបទល្មើស អ្នកប្រព្រឹត្តបទល្មើស ទំហំនៃការគេចវេះពន្ធ និងអាចសម្ភាស ឬស្តាប់ចម្លើយរបស់អ្នកជាប់ពន្ធ អ្នកគ្រប់គ្រង និងបុគ្គលិកសហគ្រាស ក្រុមគ្រួសាររបស់អ្នកជាប់ពន្ធ និងបុគ្គលពាក់ព័ន្ធផ្សេងទៀត ដូចមានចែងក្នុងមាត្រា១៩៣ មាត្រា១៩៤ និងមាត្រា២០២ នៃច្បាប់ ស្តីពីសារពើពន្ធ និងមាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**៣.៣.៣ ក្រោយពេលស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ**

យោងតាមមាត្រា១៩៣ និងមាត្រា១៩៤នៃច្បាប់ស្តីពីសារពើពន្ធ បន្ទាប់ពីបានកំណត់អត្តិភាពបទល្មើស បុគ្គលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ឬករណីគេចវេះពន្ធ ឬអំពើរាំងស្ទះកម្រិតធ្ងន់ធ្ងរដោយចេតនារបស់អ្នកជាប់ពន្ធរួចហើយ មន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើ បទប្បញ្ញត្តិស្តីពីពន្ធដារនឹងធ្វើការអញ្ជើញអ្នកជាប់ពន្ធមកជួប ដើម្បីពន្យល់បកស្រាយអំពីលទ្ធផល នៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារដែលជាអាទិ៍មានមូលដ្ឋាន និងភ័ស្តុតាងដែលគាំទ្រដល់ការ

កំណត់អត្ថិភាពបទល្មើស បុគ្គលប្រព្រឹត្តបទល្មើសមូលដ្ឋាននៃការកំណត់ពន្ធការកំណត់ពន្ធឡើងវិញ និងកសាងសំណុំរឿងទៅតុលាការជាដើម។

ប្រសិនបើ ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ មិនឈានដល់ការកសាងសំណុំរឿងទៅតុលាការទេ នោះនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវបង្វែរករណីនោះទៅអង្គភាពពាក់ព័ន្ធ ដើម្បីបន្តនីតិវិធីសវនកម្មវិញ។ អនុលោមតាមមាត្រា២២៧ នៃច្បាប់ស្តីពីសារពើពន្ធ បណ្តឹងអាជ្ញាចំពោះបទល្មើសព្រហ្មទណ្ឌ លើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលអគ្គនាយកដ្ឋានពន្ធដារបានប្តឹងទៅតុលាការ អាចត្រូវបានរំលត់ តាមរយៈការស្នើសុំសម្របសម្រួលពីសំណាក់អ្នកជាប់ពន្ធ ដោយធ្វើការបង់ប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ ឱ្យគ្រប់ចំនួនតាមការកំណត់។ ក្នុងករណីយល់ព្រម អគ្គនាយកដ្ឋានពន្ធដារត្រូវធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីពិនិត្យនិងសម្រេច និងត្រូវធ្វើកំណត់ ហេតុស្តីពីការសម្របសម្រួលជូនស្ថាប័នអយ្យការ ឬស្ថាប័នតុលាការ។

**៣.៣.៤ ទណ្ឌកម្មព្រហ្មទណ្ឌតាមបទប្បញ្ញត្តិស្តីពីសារពើពន្ធ**

ដោយមិនទាន់គិតដល់ទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មផ្សេងទៀត៖

**ក.** ទណ្ឌកម្មព្រហ្មទណ្ឌចំពោះរូបវន្តបុគ្គល ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដាររួមមាន៖

- ដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ
- និងពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ដល់ ២០០ ០០០ ០០០ (ពីររយលាន)រៀល ទៅតាមបទល្មើសនីមួយៗ ដូចមានចែងក្នុងមាត្រា២៤២ មាត្រា២៤៣ មាត្រា២៤៥ មាត្រា២៤៦ មាត្រា២៤៧ និងមាត្រា២៥០ នៃច្បាប់ស្តីពីសារពើពន្ធ។

**ខ.** យោងតាមមាត្រា២៤៩ នៃច្បាប់ស្តីពីសារពើពន្ធ ការទទួលខុសត្រូវរបស់នីតិបុគ្គល មានដូចខាងក្រោម៖

- ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌ របស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២៤២ មាត្រា២៤៣ មាត្រា២៤៥មាត្រា២៤៦ មាត្រា២៤៧ និងមាត្រា២៥០ នៃច្បាប់ ស្តីពីសារពើពន្ធ។
- ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ២០០ ០០០ ០០០ (ពីររយលាន)រៀល ទៅតាមបទល្មើសនីមួយៗ ដូចមានចែងក្នុងមាត្រា២៤២ មាត្រា២៤៣ មាត្រា២៤៦ មាត្រា២៤៧ មាត្រា២៤៥ និងមាត្រា២៥០ នៃច្បាប់ស្តីពីសារពើពន្ធ។
- អាចត្រូវប្រកាសទោសបន្ថែមណាមួយ ឬច្រើនដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែម អនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

កន្លងមកអគ្គនាយកដ្ឋានពន្ធដារ បានកត់សម្គាល់ឃើញថា មានបុគ្គលខិលខូចមួយចំនួនបាន អូសទាញបោកបញ្ឆោតបុគ្គលផ្សេងទៀតដែលមានការយល់ដឹងទាប ឱ្យឈរឈ្មោះជាម្ចាស់ភាគហ៊ុន និងជាអភិបាល និងចុះបញ្ជីនៅអគ្គនាយកដ្ឋានពន្ធដារដើម្បីទទួលបានវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ដើម្បីយកទៅប្រើប្រាស់ចេញវិក្កយបត្រក្លែងក្លាយទៅឱ្យក្រុមហ៊ុនមួយផ្សេងទៀត ក្នុងការបង្កើតក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម

បំណាងក្លែងបន្លំដាក់បញ្ចូលជាឥណទានអាករលើធាតុចូល សម្រាប់កាត់កងអាករលើធាតុចេញ និងបញ្ចូលជាបន្ទុកចំណាយដើម្បីកាត់បន្ថយពន្ធលើប្រាក់ចំណូល។

អំពើទាំងអស់ខាងលើនេះ ជាសកម្មភាពប្រព្រឹត្តបទល្មើសគេចវេះពន្ធ ដូចមានចែងក្នុងមាត្រា ១២៧ នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវរងការផ្តន្ទាទោសតាមមាត្រា ១៣៥ នៃច្បាប់ស្តីពីសារពើពន្ធ ដែលបានចែងថា៖ «ដោយមិនគិតដល់ទោសទណ្ឌផ្សេងទៀតអភិបាល បណ្ណាធិការ កម្មសិទ្ធិកររបស់សហគ្រាសណាមួយ ឬបុគ្គលទទួលខុសត្រូវឱ្យសហគ្រាសណាមួយ ដែលបានប្រព្រឹត្តអំពើគេចវេះពន្ធដូចមានចែងក្នុងមាត្រា១២៧ នៃច្បាប់នេះ ត្រូវរងនូវការផ្តន្ទាទោសពិន័យជាប្រាក់ពី១០ ០០០ ០០០ រៀល (ដប់លានរៀល ដល់ ២០ ០០០ ០០០ រៀល(ម្ភៃលានរៀល ឬជាប់ពន្ធនាគារពី១ ឆ្នាំ ដល់ ៥ ឆ្នាំ ឬទោសទាំងពីរនេះ»។

ការផាកពិន័យជាប្រាក់ចំពោះអំពើរាំងស្ទះ ការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារ (មាត្រា២៣៥) ផាកពិន័យជាប្រាក់ចំពោះអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារត្រូវបានកំណត់ដូចខាងក្រោម៖

១- ត្រូវផាកពិន័យជាប្រាក់ចំនួន ៥ ០០០ ០០០(ប្រាំលាន)រៀល ដោយរដ្ឋបាលសារពើពន្ធពុំទាន់គិតដល់ទណ្ឌកម្មរដ្ឋបាលផ្សេងទៀតចំពោះបុគ្គល ដែលធ្លាប់ត្រូវបានទទួលការព្រមាន ជាលាយលក្ខណ៍អក្សរពីរដ្ឋបាល សារពើពន្ធលើសពី ២លើក ហើយនៅតែប្រព្រឹត្តនូវអំពើរាំងស្ទះ ការអនុវត្តន៍បទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ មាត្រា២២៥នៃច្បាប់នេះ។

២- ត្រូវផាកពិន័យ ជាប្រាក់ចំនួន១០ ០០០ ០០០(ដប់លាន)រៀល ដោយរដ្ឋបាលសារពើពន្ធ ដោយពុំទាន់គិតដល់ទណ្ឌកម្មរដ្ឋបាលផ្សេងទៀតចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើរាំងស្ទះការអនុវត្តន៍ បទប្បញ្ញត្តិស្តីពីពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី៤ កថាខណ្ឌទី៥ កថាខណ្ឌទី៦ កថាខណ្ឌទី៧ និងកថាខណ្ឌទី៨នៃមាត្រា២២៥នៃច្បាប់នេះ។

៣- ករណីដែលបុគ្គលដែលត្រូវបានសម្រេចឱ្យបង់ប្រាក់ផាកពិន័យដូចមានចែងក្នុងកថាខណ្ឌទី១ ឬកថាខណ្ឌទី២នៃមាត្រានេះរួចហើយ ហើយបុគ្គលនោះបានប្រព្រឹត្តនូវអំពើរាំងស្ទះការអនុវត្តន៍បទប្បញ្ញត្តិស្តីពី ពន្ធដារណាមួយ ដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ កថាខណ្ឌទី៣ កថាខណ្ឌទី៤ កថាខណ្ឌទី៥ កថាខណ្ឌទី៦ កថាខណ្ឌទី៧ និងកថាខណ្ឌទី៨ តាមមាត្រា២២៥ នៃច្បាប់នេះម្តងទៀត បុគ្គលនោះត្រូវមាន ទោសព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា២៤៣ នៃច្បាប់នេះ។

**៣.៣.៥ វិធានការនៃការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ**

នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានពន្ធដារ លើការស៊ើបអង្កេតបទល្មើសពន្ធដារ។ នាយកដ្ឋាននេះមានភារកិច្ចដូចតទៅ៖

- ចូលរួមជាមួយនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ ក្នុងការងាររៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ នីតិវិធី កម្មវិធី និងស្តង់ដារការងារពាក់ព័ន្ធនឹងការងារប្រមូលព័ត៌មានអ្នកជាប់ពន្ធ និងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ

- គ្រប់គ្រង អនុវត្ត ត្រួតពិនិត្យ តាមដាន និងវាយតម្លៃគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ នីតិវិធី កម្មវិធី និងស្តង់ដារពាក់ព័ន្ធការងារប្រមូលព័ត៌មានអ្នកជាប់ពន្ធ និងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ
- សហការជាមួយនាយកដ្ឋាន អង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ និងស្ថាប័ននានា ក្នុងការរៀបចំការងារស៊ើបអង្កេត បទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ និងក្នុងការងារនានាពាក់ព័ន្ធនឹងពន្ធដារ
- កំណត់លក្ខណៈវិនិច្ឆ័យ និងវិភាគហានិភ័យអ្នកជាប់ពន្ធដែលជាកម្មវត្ថុ នៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ
- សហការ និងសម្របសម្រួលជាមួយស្ថាប័ន ឬអង្គភាពពាក់ព័ន្ធលើការងារប្រមូលព័ត៌មានអ្នកជាប់ពន្ធ ធ្វើការស៊ើបអង្កេត និងរៀបចំពាក្យបណ្តឹងទៅតុលាការពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ
- រៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាលពាក់ព័ន្ធការប្រមូលព័ត៌មានអ្នកជាប់ពន្ធ និងស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ
- បណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាពមន្ត្រីក្នុងនាយកដ្ឋាន
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងាររបស់នាយកដ្ឋាន ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំជូនថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ។

នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ មានការិយាល័យក្រោមឱវាទចំនួន ៤ ដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យប្រមូលព័ត៌មានអ្នកជាប់ពន្ធ
- ការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារទី១
- ការិយាល័យស៊ើបអង្កេតបទល្មើសពន្ធដារទី២។

### ១. អ្នកជាប់ពន្ធធំ

- រៀបចំយន្តការសម្រាប់គាំទ្រដល់ការផ្តល់សេវាដល់អ្នកជាប់ពន្ធ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព
- រៀបចំ និងអនុវត្តកម្មវិធីផ្តល់សេវាដល់អ្នកជាប់ពន្ធ ផ្អែកតាមភាពចាំបាច់របស់អ្នកជាប់ពន្ធ ធនធានមនុស្ស និងថវិកាដែលត្រូវបានផ្តល់ឱ្យ
- ផ្តល់សេវាពាក់ព័ន្ធកាតព្វកិច្ចពន្ធដារ ជូនអ្នកជាប់ពន្ធជាអាទិ៍ ការផ្តល់ប្រឹក្សា និងការផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធនឹងពន្ធដារ
- សហការរៀបចំសិក្ខាសាលា ការបណ្តុះបណ្តាល និងផ្សព្វផ្សាយជូនអ្នកជាប់ពន្ធ អំពីបទប្បញ្ញត្តិស្តីពីពន្ធដារ

- រៀបចំក្រុមពិភាក្សាជាមួយអ្នកជាប់ពន្ធតាមវិស័យសំខាន់ៗ ដើម្បីទទួលបាននូវសំណូមពរ និងសេចក្តីត្រូវការរបស់អ្នកជាប់ពន្ធ
- ប្រមូលពន្ធប្រថាប់ត្រាលើកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវាដែលប្រើប្រាស់ថវិការដ្ឋ និងលើការផ្ទេរភាគហ៊ុនពាក់ព័ន្ធអ្នកជាប់ពន្ធធំ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពរបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនប្រធាននាយកដ្ឋាន
- បំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ប្រធាននាយកដ្ឋាន។

**២. អ្នកជាប់ពន្ធតូច និងមធ្យម**

- រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ នីតិវិធី និងកម្មវិធី ផ្តល់សេវាដល់អ្នកជាប់ពន្ធតូចនិងមធ្យម
- រៀបចំទម្រង់ បែបបទ និងមធ្យោបាយទំនាក់ទំនង ក្នុងការផ្តល់សេវាដល់អ្នកជាប់ពន្ធតូចនិងមធ្យម
- គ្រប់គ្រង អនុវត្ត ត្រួតពិនិត្យតាមដាន និងវាយតម្លៃគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ នីតិវិធី និងកម្មវិធី ផ្តល់សេវាដល់អ្នកជាប់ពន្ធតូចនិងមធ្យម
- រៀបចំសិក្ខាសាលា អប់រំ ផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាលជាសាធារណៈ
- រៀបចំ និងថែរក្សា សៀវភៅណែនាំស្តីពីនីតិវិធីផ្ទៃក្នុង សម្រាប់ផ្តល់សេវាដល់អ្នកជាប់ពន្ធតូច និងមធ្យម
- រៀបចំ ផ្សព្វផ្សាយ និងធ្វើបច្ចុប្បន្នភាពនូវសៀវភៅណែនាំ និងព័ត៌មានផ្សេងៗ សម្រាប់អ្នកជាប់ពន្ធតូចនិងមធ្យម
- បង្កើតនូវគំរូចម្លើយជាលាយលក្ខណ៍អក្សរ តាមទូរស័ព្ទ និងមធ្យោបាយផ្សេងទៀត ក្នុងការឆ្លើយតបទៅនឹងសំណួររបស់អ្នកជាប់ពន្ធតូច និងមធ្យម
- ចងក្រងសំណួរដែលអ្នកជាប់ពន្ធសួរជាញឹកញាប់ និងបង្កើតជាតារាងទិន្នន័យសំណួរ ដើម្បីជួយមន្ត្រីក្នុងការរក្សានូវសន្តិភាព និងគុណភាពនៅទូទាំងប្រទេស នៅពេលដែលឆ្លើយតបទៅនឹងសំណួររបស់អ្នកជាប់ពន្ធតូច និងមធ្យម
- បង្កើតភាពជាដៃគូ និងសហការជាមួយផ្នែកឯកជន គណនេយ្យករ សវនករជំនាញ អ្នកច្បាប់ ភ្នាក់ងារសេវាកម្មពន្ធដារ ដើម្បីពង្រឹងការគោរពច្បាប់ និងស្វែងយល់ពីតម្រូវការរបស់អ្នកជាប់ពន្ធតូចនិងមធ្យម
- ធ្វើការស្រាវជ្រាវដោយរួមបញ្ចូលការស្ទង់មតិ ដើម្បីផ្តល់សេវាឱ្យបានល្អជូនអ្នកជាប់ពន្ធតូចនិងមធ្យម
- ចងក្រងព័ត៌មានប្រតិបត្តិពាក់ព័ន្ធនឹងការផ្តល់សេវាអ្នកជាប់ពន្ធ ដែលទទួលបានពីអង្គភាពប្រតិបត្តិ
- ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ការិយាល័យ ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ ជូនប្រធាននាយកដ្ឋានបំពេញភារកិច្ចផ្សេងៗទៀតតាមការកំណត់របស់ប្រធាននាយកដ្ឋាន។

# ជំពូកទី៤
# ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី នីតិវិធីក្នុងការទប់ស្កាត់បទល្មើសអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារួចមក យើងបានរកឃើញនូវចំណុចខ្លាំងមួយចំនួនដូចជា៖

- អគ្គនាយកដ្ឋានពន្ធដារ បានចាត់វិធានការពង្រឹងការអនុវត្តន៍ច្បាប់ កាត់បន្ថយនូវការគេចវេះពន្ធឱ្យបានជាអតិបរមា។
- អគ្គនាយកដ្ឋានពន្ធដារ សហការជាមួយអង្គភាពក្រោមឱវាទ និងស្ថាប័ននានា ដើម្បីធ្វើការរៀបចំ និងអនុវត្តកម្មវិធីបណ្តុះបណ្តាល ដែលជម្រុញដល់ការអភិវឌ្ឍន៍សមត្ថភាពមន្ត្រី ក្នុងការប្រមូលព័ត៌មានអ្នកជាប់ពន្ធ
- ធ្វើការស៊ើបអង្កេត ឆែកឆេរ រឹបអូសវត្ថុតាង ឃុំគ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធដែលព្យាយាមគេចវេះនៅក្នុងដំណាក់កាល និងក្រោយដំណាក់កាលស៊ើបអង្កេត និងរៀបចំពាក្យបណ្តឹងទៅតុលាការពាក់ព័ន្ធនឹងបទល្មើស
- ការអនុវត្តន៍កម្មវិធីចាប់បង្ខំគោលការណ៍យុត្តិធម៌ និងបទប្បញ្ញត្តិនានា ដោយមានប្រសិទ្ធភាព និងមានភាពស្មើរគ្នា ចំពោះអ្នកជាប់ពន្ធអ្នកប្រព្រឹត្តបទល្មើសពន្ធដារត្រូវទទួលរងទោសទណ្ឌ ដោយពិន័យជាប្រាក់ ឬជាប់ពន្ធនាគារ ឬទោសទាំងពីរ ដោយមិនគិតពីទោសទណ្ឌផ្សេងទៀត
- បានផ្តល់ជូននូវសេវាសមស្របដល់អ្នកជាប់ពន្ធរួមមាន ការផ្តល់ព័ត៌មានអប់រំចំណេះដឹង ការពន្យល់ណែនាំដែលទាក់ទងនឹងការបង់ពន្ធផ្សេងៗ ដែលធ្វើឱ្យអ្នកជាប់ពន្ធយល់កាន់តែច្បាស់ និងពេញចិត្តបង់ពន្ធដោយភាពស្មោះត្រង់
- កែលម្អសេវាអ្នកជាប់ពន្ធ ដើម្បីលើកកម្ពស់វប្បធម៌បង់ពន្ធ ពង្រឹងអនុលោមភាពសារពើពន្ធ ដែលនឹងធានាបាននូវចីរភាពចំណូល និងលើកកម្ពស់ការប្រកួតប្រជែងដោយស្មើភាពជូនវិស័យឯកជន ស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល។

## ៤.២ វិភាគលើចំណុចខ្សោយ

ទន្ទឹមនឹងរកឃើញ នូវចំណុចខ្លាំងមួយចំនួនទៅលើនីតិវិធី ក្នុងការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធ យើងបានរកឃើញនូវចំណុចអសកម្មមួយចំនួនផងដែរ ដែលបានរាំងដល់ការប្រមូលពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ។ ចំណុចខ្សោយទាំងនោះគឺមានដូចខាងក្រោម ៖

- ពន្ធដារមិនបានត្រួតពិនិត្យគ្រប់ជ្រុងជ្រោយលើពាក្យតវ៉ារបស់អ្នកជាប់ពន្ធមួយចំនួនតូច ហេតុនេះហើយវាធ្វើឱ្យមានភាពយឺតយ៉ាវក្នុងការបង់ពន្ធ រហូតអាចឈានដល់មានការដាក់ពាក្យបណ្តឹងតវ៉ាតាមផ្លូវច្បាប់

- ចំនួនមន្ត្រីមានតិចធៀបទៅនឹងសហគ្រាសដែលមានច្រើន និងកំពុងតែបង្កើតថ្មីបន្ថែមជារៀងរាល់ថ្ងៃពន្ធដារខិតខំរឹតបន្តឹងទប់ស្កាត់ទៅលើការគេចវេះពន្ធយ៉ាងណាក៏ដោយក៏នៅមានចំណុចធ្វេសប្រហែសមួយចំនួនដូចជា ការគេចវេះមិនបង់ពន្ធ ការពន្យាពេលការបង់ពន្ធ និងការបង់ពន្ធ មិនត្រឹមត្រូវតាមច្បាប់
- រយៈពេល នៃការចុះធ្វើសវនកម្មរបស់មន្ត្រីពន្ធដារមានរយៈពេលខ្លី មិនមានពេលគ្រប់គ្រាន់ក្នុងការចុះទៅក្រុមហ៊ុនផ្ទាល់ ហើយផ្តល់ពេលវេលាឱ្យក្រុមហ៊ុនក្នុងការរៀបចំឯកសារមានរយៈពេលខ្លី
- នីតិវិធីសវនកម្មមួយចំនួនមានលក្ខណៈសាំញ៉ាំ និងស្មុគស្មាញពេកដែលធ្វើឱ្យអ្នកជាប់ពន្ធ មួយចំនួនមិនសប្បាយចិត្ត មិនទាន់ទទួលបានកិច្ចសហការល្អពីស្ថាប័នពាក់ព័ន្ធផ្សេងៗ អ្នកជាប់ពន្ធមួយចំនួនមិនមានការយល់ដឹងពីច្បាប់ពន្ធ ជាហេតុធ្វើឱ្យពួកគាត់មិនបានផ្តល់កិច្ចសហការ ជាមួយមន្ត្រីសវនកម្ម
- កង្វះព័ត៌មាន ឬទិន្នន័យគ្រប់ជ្រុងជ្រោយក្នុងការប្រមូលចំណូលពន្ធ ដោយសារការចែករំលែកទិន្នន័យពីក្រសួង-ស្ថាប័នមួយចំនួននៅមានកម្រិត កង្វះព័ត៌មាន ឬទិន្នន័យគ្រប់ជ្រុងជ្រោយ ស្តីពីការអនុវត្តន៍កាតព្វកិច្ច និងសិទ្ធរបស់អ្នកជាប់ពន្ធ
- ការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តិ មិនសូវទូលំទូលាយ សាធារណៈជនមិនសូវយល់ដឹងពីវិធានការទប់ស្កាត់ ការគេចវេះពន្ធ និងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទបទប្បញ្ញ ស្តីពីពន្ធដារ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាស្រាវជ្រាវ ទៅលើប្រធានបទនីតិវិធីក្នុងការទប់ស្កាត់បទល្មើស អ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ធ្វើឱ្យយើងអាចសន្និដ្ឋានបានថាដំណើរការនៃការទប់ស្កាត់បទល្មើសរបស់អ្នកជាប់ពន្ធជាចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិតាមរយការចូលរួមបង់ពន្ធ។ តាមការពិតការបង់ពន្ធ វាគឺជាការចូលរួមចំណែកក្នុងថវិកាជាតិ ដើម្បីឱ្យរដ្ឋមានថវិកាយក ទៅចំណាយដោយមិនចាំបាច់បោះពុម្ពថវិកាដែលអាចបង្កឱ្យមានបញ្ហាអតិផរណា។ សម្រាប់ប្រទេសកម្ពុជាការបង្កើនចំណូលពីការបង់ពន្ធ គឺជាគន្លឹះដ៏សំខាន់មួយដើម្បីឈានទៅបញ្ឈប់ការពឹងផ្អែកលើជំនួយពីបរទេស។ សម្រាប់អ្នកបង់ពន្ធ ថ្វីដ្បិតតែពន្ធនេះមិនមានការកំណត់អំពីសេវាណាមួយជាថ្នូរមកវិញជាក់ លាក់ក៏ពិតមែន ក៏ប៉ុន្តែ គេអាចទទួលបានផលប្រយោជន៍ជាច្រើន ដោយផ្ទាល់ ឬដោយប្រយោលពីការបង់ពន្ធនេះ ពីព្រោះថាថវិកាដែលបានពីការបង់ពន្ធនេះនឹងត្រូវយកទៅចំណាយទៅលើ ការបើកប្រាក់បៀវត្សដល់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធដែលជាអ្នកទទួលបន្ទុកផ្តល់សេវារដ្ឋបាលការពារសន្តិសុខសណ្តាប់ធ្នាប់ និងការពារអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់ប្រទេស។

## ៥.២ ការផ្តល់អនុសាសន៍

តាមរយៈការសិក្សាស្រាវជ្រាវបានផ្តល់លទ្ធភាពឱ្យមានការលើកឡើងនូវសំណូមពរមួយចំនួនដើម្បីចូលរួមចំណែកជំរុញការប្រមូលពន្ធ ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀតដូចជា៖

- អគ្គនាយកដ្ឋានពន្ធដារ គួរតែបន្ថែមចំនួនមន្ត្រីពន្ធ ដើម្បីឱ្យការទទួលលិខិតប្រកាសពន្ធប្រកប ដោយភាពរលូត និងរហ័សទាន់ចិត្តសម្រាប់អ្នកជាប់ពន្ធ។ ក្នុងនោះដែរអ្នកជាប់ពន្ធទាំងឡាយក៏គួរតែចូលរួមសហការ និងមានមនសិកាដាស់តឿនខ្លួនឯងពីភារកិច្ចដែលខ្លួនត្រូវបំពេញ ដើម្បីឆ្លើយតបទៅនឹងការខិតខំប្រឹងប្រែងរបស់ខាងពន្ធដាររដូចគ្នា។
- សិក្សារៀបចំបន្ថែម នូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងការលើកទឹកចិត្តសហគ្រាសធុនតូច និងមធ្យមក្នុងគោលដៅពង្រឹងប្រសិទ្ធភាព នៃការអនុវត្តន៍អនុក្រឹត្យនៃការលើកទឹកចិត្តផ្នែកពន្ធដារ ជំរុញកំណើនសកម្មភាពសេដ្ឋកិច្ចពង្រឹង និងជំរុញការកាន់បញ្ជិការគណនេយ្យព្រមទាំងបន្តផ្សព្វផ្សាយ ឱ្យបានជ្រួតជ្រាបដល់អ្នកជាប់ពន្ធ អំពីកាតព្វកិច្ចរបស់ខ្លួន។
- អគ្គនាយកដ្ឋានពន្ធដារ គួរតែបង្ហាញនូវទិន្នន័យនៃការប្រមូលប្រាក់ពន្ធធៀបនឹងចំណាយផ្សេងៗប្រចាំឆ្នាំ ដើម្បីផ្តល់ជាទំនុកចិត្តដល់អ្នកជាប់ពន្ធ ដើម្បីជៀសវាងការយល់ច្រឡំនិងមានគំនិតក្នុងការគេចពន្ធដែលនាំឱ្យមានការខាតបង់ដល់ចំណូលជាតិទាំងមូល។
- អគ្គនាយកដ្ឋានពន្ធដារគួរតែការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋាន គតិយុត្ត មិនសូវទូលំទូលាយបន្ថែមទៀត ដើម្បីឱ្យសាធារណៈបានយល់ដឹងកាន់តែច្បាស់លើបទបទប្បញ្ញស្តីពីពន្ធដារ។
- អគ្គនាយកដ្ឋានពន្ធដារគួរតែធ្វើសិក្ខាសិលា ដើម្បីផ្តល់ចំណេះដឹងដល់អ្នកជាប់ពន្ធឱ្យបានច្រើនឱ្យពួកគេយល់ច្បាស់ពីដំណើរការនៃការបង់ពន្ធ និងវិធីសាស្រ្ត នៃការគណនាពន្ធឱ្យបានត្រឹមត្រូវជូន

រដ្ឋជៀសវាង ពេលដាក់លិខិតប្រកាសមិនត្រឹមត្រូវ ជាហេតុនាំឱ្យខាតពេលវេលាទាំងមន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធក្នុងការកែប្រែលិខិតប្រកាស។

- បណ្តុះគំនិតដល់ក្មេងជំនាន់ក្រោយ ខាងអគ្គនាយកដ្ឋានពន្ធដារគួរតែស្នើសុំដល់ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការដាក់បញ្ចូលនូវមុខវិជ្ជាពន្ធដារនេះ ទៅក្នុងកម្មវិធីសិក្សា ដើម្បីឱ្យពួកគេមានការយល់ដឹងពីពន្ធដារពិសេស គឺដឹងពីគោលបំណង និងសារៈប្រយោជន៍នៃការប្រមូលពន្ធ ព្រមទាំងភាពជាពលរដ្ឋ ក្នុងការចូលរួមគោរពច្បាប់ទាក់ទង នឹងការបង្កើតអាជីវកម្មផ្សេងៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ឯកសារយោង

# ឯកសារយោង


1. វិទ្យាស្ថានវ៉ាន់ដា សេចក្ដីផ្ដើមនៃនីតិ បោះពុម្ពលើកទី៨(២០១៩) ទំព័រ ៥៦ មាន ១០១ទំព័រ
2. គណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់«សន្ទានុក្រមពាក្យច្បាប់ ខ្មែរ~អង់គ្លេស~បារាំង ផ្នែករដ្ឋប្បវេណី និង នីតិវិធីរដ្ឋប្បវេណី» ទំព័រទី១ ឆ្នាំ២០០៧ មាន ១៨ទំព័រ។
3. ផេង វិច្ឆ័យ «សន្ទានុក្រម ច្បាប់ ភូមិបាល» ទំព័រទី១ ឆ្នាំ២០០១ មាន ៩ទំព័រ។
4. អង្គការមូលនិធិអាស៊ី «វចនានុក្រមច្បាប់ ASIA FOUNDATION»
5. https://www.tax.gov.kh/en/
6. https://www.kakcent.com/classification%E2%80%8B-o%E2%80%8Bf%E2%80%8B-%E2%80%8Btaxpayer%E2%80%8Bs/
7. https://www.tax.gov.kh/en/glossary
8. https://en.wikipedia.org/wiki/Taxpayer
9. https://www.investopedia.com/terms/t/taxpayer.asp
10. https://ticambodia.org/library/wpcontent/files_mf/1536811335FINAL_Khm_CaseStudyonTaxSystem_FINALReport18Oct2017.pdf
11. https://www.khsearch.com/qna/25576
12. https://chuonviraklaw.files.wordpress.com/2015/12/e19e94e19e91e19e9be19f92e19e98e19ebee19e9fe19e9fe19e89e19f92e19e89e19eb6e19e8ee19e93e19eb7e19e84e19e85e19e9ae19eb7e19e8fe19e9b.pdf
13. https://www.facebook.com/345437756647388/posts/
14. https://web.facebook.com/1482208281916621/posts/
15. https://www.tnaot.com/km/m/detail/article/2127308

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ


បាត់ដំបង
ភ្នំពេញ
សៀមរាប
វិទ្យាស្ថាន វ៉ាន់ដា
VANDA INSTITUTE
សេចក្តីផ្តើមនៃនីតិ
INTRODUCTION TO LAW
រក្សាសិទ្ធគ្រប់យ៉ាងដោយវិទ្យាស្ថាន វ៉ាន់ដា
បោះពុម្ពលើកទី៨(២០១៩)
សម្រាប់ប្រើផ្ទៃក្នុង

អគ្គនាយកដ្ឋានពន្ធដារ

GENERAL DEPARTMENT OF TAXATION

សៀវភៅណែនាំ ស្តីពី

# ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ
# លើបទប្បញ្ញត្តិស្តីពីពន្ធដារ

សម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ភាតព្វកិច្ច និង សិទ្ធិ
# របស់អ្នកជាប់ពន្ធ



ឆ្នាំ ២០១០

រៀបចំ និង បោះពុម្ពផ្សាយដោយ
អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ០៤៦១៨ អពដ

L20190607002 | TD1908

ថ្ងៃអង្គារ ៧កើត ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ កក្កដា ឆ្នាំ២០១៩

# សេចក្ដីជូនដំណឹង
## ស្ដីពី
## វិធានការទប់ស្កាត់ការគេចវេះពន្ធ និងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន លោក -លោកស្រីជាប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ឬជាកម្មសិទ្ធិករនៃសហគ្រាសទាំងអស់ឱ្យបានជ្រាបថា កន្លងមកអគ្គនាយកដ្ឋានពន្ធដារបានកត់សម្គាល់ឃើញថា មានបុគ្គលទុច្ចរិតមួយចំនួនបានអូសទាញ បោកបញ្ឆោតបុគ្គលផ្សេងទៀតដែលមានការយល់ដឹងទាប ឱ្យឈរឈ្មោះជាម្ចាស់ភាគហ៊ុន និងជាអភិបាលបង្កើតក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម និងចុះបញ្ជីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារដើម្បីទទួលបានវិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម ដើម្បីយកទៅប្រើប្រាស់ចេញវិក្កយបត្រក្លែងក្លាយទៅឱ្យក្រុមហ៊ុនមួយផ្សេងទៀតក្នុងគោលបំណងក្លែងបន្លំដាក់បញ្ចូលជាឥណទានអាករលើធាតុចូលសម្រាប់កាត់កងអាករលើធាតុចេញ និងបញ្ចូលជាបន្ទុកចំណាយដើម្បីកាត់បន្ថយពន្ធលើប្រាក់ចំណូល។

អំពើទាំងអស់ខាងលើនេះ ជាសកម្មភាពប្រព្រឹត្តបទល្មើសគេចវេះពន្ធ ដូចមានចែងក្នុងមាត្រា ១២៧ នៃច្បាប់ស្ដីពីសារពើពន្ធ ដែលត្រូវរងការផ្ដន្ទាទោសតាមមាត្រា ១៣៥ នៃច្បាប់ស្ដីពីសារពើពន្ធដែលបានចែងថា÷

*"ដោយមិនគិតដល់ទោសទណ្ឌផ្សេងទៀត អភិបាល បណ្ណាធិការ កម្មសិទ្ធិកររបស់សហគ្រាសណាមួយ ឬបុគ្គលទទួលខុសត្រូវឱ្យសហគ្រាសណាមួយដែលបានប្រព្រឹត្តអំពើគេចវេះពន្ធដូចមានចែងក្នុងមាត្រា ១២៧ នៃច្បាប់នេះ ត្រូវរងនូវការផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០ រៀល(ដប់លានរៀល) ដល់ ២០ ០០០ ០០០ រៀល(ម្ភៃលានរៀល) ឬជាប់ពន្ធនាគារពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ ឬទោសទាំងពីរនេះ"។*

និងជាបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារដូចមានចែងក្នុងមាត្រា ១២៨ និង ១២៩ នៃច្បាប់ស្ដីពីសារពើពន្ធ ដែលត្រូវរងការផ្ដន្ទាទោសតាមមាត្រា ១៣៦ នៃច្បាប់ស្ដីពីសារពើពន្ធដែលបានចែងថា÷

*"ដោយមិនគិតដល់ទោសទណ្ឌផ្សេងទៀត បុគ្គលណាមួយដែលបានប្រព្រឹត្តអំពើរំលោភ ដល់ការអនុវត្តបទប្បញ្ញត្តិស្ដីពីពន្ធដារ ដូចមានចែងក្នុងមាត្រា ១២៨ នៃច្បាប់នេះ ត្រូវរងការផ្ដន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០ រៀល(ប្រាំលានរៀល) ដល់ ១០ ០០០ ០០០ រៀល(ដប់លានរៀល) ឬជាប់ពន្ធនាគារពី ១ ខែ ដល់ ១ ឆ្នាំ ឬទោសទាំងពីរនេះ។"*



អាគារលេខ ៣ ផ្លូវ សហព័ន្ធរុស្ស៊ី (១១០) និង ផ្លូវលេខ (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

L20190607002 | TD1908

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងចាត់វិធានការចាំបាច់នានាតាមច្បាប់ជាធរមាន ដើម្បីស្វែងរកបុគ្គលដែលបានប្រព្រឹត្តបទល្មើសមកផ្ដន្ទាទោសតាមច្បាប់។

ដើម្បីពង្រឹងនូវការអនុវត្តច្បាប់ និងធានានូវតម្លាភាពនៃការប្រកួតប្រជែងក្នុងកិច្ចការធុរកិច្ច អគ្គនាយកដ្ឋានពន្ធដារ សូមស្នើសាធារណជន និងធុរជនទាំងអស់ រួមទាំងបុគ្គលដែលត្រូវបានគេជួលឱ្យឈរឈ្មោះជំនួស សហការផ្ដល់ព័ត៌មានអំពីសកម្មភាពប្រព្រឹត្តបទល្មើសគេចវេះពន្ធ និងបទល្មើសផ្នែកព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារមកនាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ តាមរយៈលេខទូរស័ព្ទ÷ ០២៣ ៨៨៤ ៧១៤ អ៊ីម៉ែល÷ dtci@tax.gov.kh ដើម្បីអគ្គនាយកដ្ឋានពន្ធដារចាត់វិធានការពង្រឹងការអនុវត្តច្បាប់ កាត់បន្ថយនូវការគេចវេះពន្ធឱ្យបានជាអតិបរមា។

ដូច្នេះដើម្បីជៀសវាងនូវទោសទណ្ឌដែលអាចកើតមានឡើងពីការប្រព្រឹត្តបទល្មើសទាំងនេះ អគ្គនាយកដ្ឋានពន្ធដារ សូមស្នើសាធារណជន និងធុរជនទាំងអស់ជៀសវាងនូវការប្រព្រឹត្តបទល្មើសខាងលើ និងអនុវត្តច្បាប់ស្ដីពីសារពើពន្ធឱ្យបានត្រឹមត្រូវ។

អគ្គនាយកដ្ឋានពន្ធដារ សង្ឃឹមយ៉ាងមុតមាំថា សាធារណជន លោក -លោកស្រីជាប្រធានក្រុមប្រឹក្សាភិបាល អភិបាល បណ្ណាធិការ ឬជាកម្មសិទ្ធិករនៃសហគ្រាសទាំងអស់ ពិតជាយកចិត្តទុកដាក់ និងសហការអនុវត្តតាមខ្លឹមសារនៃសេចក្ដីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

ព្រះរាជក្រម

នស/រកម/០៥២៣/០០៤

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឱ្យប្រើ**

ច្បាប់ស្តីពីសារពើពន្ធ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភា លើកទី៩ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០២៣ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



# ច្បាប់
# ស្តីពី
# សារពើពន្ធ



## ជំពូកទី២០
## អវសានប្បញ្ញត្តិ

**មាត្រា២៥៤ .-** និរាករណ៍

ច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៥៥ .-** ការប្រកាសឱ្យប្រើច្បាប់

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ *អង្គារ ១២កើត* ខែ *ពិសាខ* ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី *១៦* ខែ *ឧសភា* ឆ្នាំ២០២៣

*លេខ ២០០៥.៥៨៤*

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន



**មាត្រា២៨ .-** ប្រាក់រំដោះពន្ធលើប្រាក់ចំណូល

សហគ្រាសដែលជាប់ពន្ធលើប្រាក់ចំណូលតាមរបបស្វ័យប្រកាស រួមទាំងគម្រោងវិនិយោគមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលផុតរយៈពេលលើកលែងពន្ធលើប្រាក់ចំណូល មានកាតព្វកិច្ចបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណូលប្រចាំខែតាមអត្រា១(មួយ)ភាគរយនៃផលរបរ រួមបញ្ចូលទាំងពន្ធអាករនានា វៀរលែងតែអាករលើតម្លៃបន្ថែមដែលសម្រេចបានក្នុងខែមុន។ ប្រាក់រំដោះពន្ធលើប្រាក់ចំណូលនឹងត្រូវបានយកមកកាត់កងពីពន្ធលើប្រាក់ចំណូលនៅពេលធ្វើការទូទាត់ប្រចាំឆ្នាំ។

### ផ្នែកទី៧
### កាតព្វកិច្ចរបស់អ្នកជាប់ពន្ធ

**មាត្រា២៩ .-** កាតព្វកិច្ចរបស់អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំ

អ្នកជាប់ពន្ធមធ្យមនិងអ្នកជាប់ពន្ធធំត្រូវមានកាតព្វកិច្ចដូចខាងក្រោម៖

១- អនុវត្តកាតព្វកិច្ចបញ្ជិកាគណនេយ្យដូចមានចែងក្នុងកថាខណ្ឌទី២នៃមាត្រា៦នៃច្បាប់នេះ និងត្រូវដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំជូនរដ្ឋបាលសារពើពន្ធតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ក្នុងរយៈពេល៣(បី)ខែ ក្រោយពីដំណាច់ឆ្នាំជាប់ពន្ធនីមួយៗ ដោយភ្ជាប់ជាមួយនូវតារាងតុល្យការគណនីលទ្ធផល និងព័ត៌មានបន្ថែម។

២- ចំពោះសហគ្រាសដែលមានការខាតបង់ ក៏ត្រូវដាក់លិខិតប្រកាសសារពើពន្ធតាមបែបបទនិងក្នុងរយៈពេលដូចគ្នាដែរ។

**មាត្រា៣០ .-** កាតព្វកិច្ចរបស់អ្នកជាប់ពន្ធតូច

អ្នកជាប់ពន្ធតូចមានកាតព្វកិច្ចដូចខាងក្រោម៖

១- ត្រូវដាក់លិខិតប្រកាសនិងបង់ពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ ជូនរដ្ឋបាលសារពើពន្ធជារៀងរាល់ឆ្នាំក្នុងរយៈពេល៣(បី)ខែ ក្រោយដំណាច់ឆ្នាំប្រតិទិននីមួយៗតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់។

២- ក្នុងករណីមិនបានកាន់កត់ត្រាបញ្ជីចំណូលចំណាយតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ ចំនួនប្រាក់ចំណូលជាប់ពន្ធត្រូវកំណត់ដោយរដ្ឋបាលសារពើពន្ធ បន្ទាប់ពីបានត្រួតពិនិត្យនិងគណនាតាមអត្រាចំណូលទៅតាមមុខរបរអាជីវកម្ម ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៣១ .-** កាតព្វកិច្ចរបស់ភ្នាក់ងារកាត់ទុក

១- បុគ្គលឬអ្នកទទួលភារៈបើកប្រាក់ដែលកាត់ទុកប្រាក់ពន្ធតាមមាត្រា២៥និងមាត្រា២៦នៃច្បាប់នេះ ត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធដែលបានកាត់ទុកជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ [illegible]សារពើពន្ធបានកំណត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលបានធ្វើការទូទាត់។

២- [illegible]គ្រាសត្រូវដាក់លិខិតប្រកាសពន្ធបង់មុនលើការបែងចែកភាគលាភ ដូចមានចែងក្នុងមាត្រា [illegible] និងបង់ពន្ធជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលរដ្ឋបាលសារពើពន្ធបានកំណត់ [illegible]ត្រឹមថ្ងៃទី២០នៃខែបន្ទាប់ពីខែដែលការបែងចែកត្រូវបានទូទាត់។